# កំណត់ចំណាំរបស់ UNCITRAL ស្តីពីការរៀបចំដំណើរការមជ្ឈត្តការ

(ញូវយ៉ក ឆ្នាំ២០១៦)

បកប្រែក្រៅផ្លូវការជាភាសាខ្មែរ

២០២៣

WELCOME



# SOLVE
# BUSINESS PROBLEMS

PHILOSOPHY Making positive impacts

UNCITRAL

គណៈកម្មការស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ

# កំណត់ចំណាំរបស់ UNCITRAL
# ស្តីពីការរៀបចំដំណើរការមជ្ឈត្តការ



អង្គការសហប្រជាជាតិ

ព័ត៌មានបន្ថែមអាចទទួលបានពី៖
លេខាធិការដ្ឋាន UNCITRAL មជ្ឈមណ្ឌលអន្តរជាតិទីក្រុងវីយែន
ប្រអប់សំបុត្រលេខ ៥០០,១៤០០ ទីក្រុងវីយែន ប្រទេសអូទ្រីស

ទូរស័ព្ទ៖ (+៤៣-១) ២៦០៦០-៤០៦០ ទូរសារ៖ (+៤៣-១) ២៦០៦០-៥៨១៣
គេហទំព័រ៖ www.uncitral.org អ៊ីមែល៖ uncitral@uncitral.org

គណៈកម្មការស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ

# កំណត់ចំណាំរបស់ UNCITRAL
# ស្តីពីការរៀបចំដំណើរការមជ្ឈត្តការ

អង្គការសហប្រជាជាតិ
ញូវយ៉ក ឆ្នាំ២០១៦



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352 | Tel: +855 (0) 86 56 9666 | Email: services@din-co.com | Website: www.din-co.com
Project No. 5992983 | Translation: English to Khmer | Types: Legal document | Verified by: Panha NORN | Version: 01 | Date: 19 February 2023

© អង្គការសហប្រជាជាតិៈ គណៈកម្មការស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ ខែតុលា ឆ្នាំ២០១៦។ រក្សាសិទ្ធិគ្រប់យ៉ាង ទូទាំងសកលលោក។

ការបោះពុម្ពនេះមិនទាន់ត្រូវបានកែសម្រួលជាផ្លូវការទេ។

ការបោះពុម្ពៈ ជាភាសាអង់គ្លេស ដោយផ្នែកបោះពុម្ព និងបណ្ណាល័យនៃការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងវីយែន។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com

# បុព្វកថា

គណៈកម្មការស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ (UNCITRAL) បានអនុម័តការបោះពុម្ពផ្សាយលើកទីមួយនៃកំណត់ចំណាំស្ដីពីការរៀបចំដំណើរការមជ្ឈត្តការសម័យប្រជុំលើកទីម្ភៃប្រាំបួនរបស់ខ្លួននៅឆ្នាំ១៩៩៦។[១]

UNCITRAL បានបញ្ចប់ការបោះពុម្ពផ្សាយលើកទី ២ នៃកំណត់ចំណាំនេះនៅសម័យប្រជុំលើកទីសែសិបប្រាំបួនរបស់ខ្លួននៅឆ្នាំ២០១៦។[២]

បន្ថែមលើអ្នកតំណាងនៃរដ្ឋសមាជិកទាំង ៦០ នៃ UNCITRAL អ្នកតំណាងនៃរដ្ឋជាច្រើនផ្សេងទៀត និងអង្គការអន្តរជាតិបានចូលរួមក្នុងកិច្ចពិភាក្សានេះ។ ក្នុងការរៀបចំការបោះពុម្ពផ្សាយកំណត់ចំណាំលើកទី ២ លេខាធិការដ្ឋានបានពិគ្រោះយោបល់ជាមួយអ្នកជំនាញមកពីបណ្ដាប្រព័ន្ធច្បាប់ផ្សេងៗគ្នា ស្ថាប័នមជ្ឈត្តការជាតិ និងអន្តរជាតិព្រមទាំងសមាគមវិជ្ជាជីវៈអន្តរជាតិផងដែរ។

[១] សៀវភៅប្រចាំឆ្នាំ UNCITRAL វ៉ុល XXVII ឆ្នាំ ១៩៩៦ ផ្នែកទីបី ឧបសម្ព័ន្ធទី II ។

[២] ការរៀបចំបោះពុម្ពកំណត់ចំណាំលើកទី២ មាននៅក្នុងឯកសារដូចតទៅ៖ របាយការណ៍របស់គណៈកម្មការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ស្ដីពីកិច្ចការនៃសម័យប្រជុំលើកទីសែសិបប្រាំបីរបស់ខ្លួន (កំណត់ត្រាផ្លូវការនៃមហាសន្និបាត នាសម័យប្រជុំលើកទីចិតសិប សេចក្ដីបំពេញបន្ថែមលេខ ១៧ (A/៧០/១៧) កថាខណ្ឌទី ១៤-១៣៣) និងសម័យប្រជុំលើកទីសែសិបប្រាំបួន (កំណត់ត្រាផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី៧១ សេចក្ដីបំពេញបន្ថែមលេខ ១៧ (A/៧១/១៧) កថាខណ្ឌទី ១៣២–១៥៨); កំណត់ចំណាំដោយលេខាធិការដ្ឋានដែលត្រូវបានពិចារណាដោយគណៈកម្មការ៖ A/CN៩/៨៤៤ (សម័យប្រជុំលើកទីសែសិបប្រាំបី) និង A/CN៩/៨៧៩ (សម័យប្រជុំលើកទីសែសិបប្រាំបួន); របាយការណ៍របស់ក្រុមការងារទី ២ នៃ UNCITRAL (ការដោះស្រាយវិវាទ) ស្ដីពីកិច្ចការនៃសម័យប្រជុំលើកទីហុកសិបមួយរបស់ខ្លួន (A/CN.៩/៨២៦) សម័យប្រជុំលើកទីហុកសិបពីរ (A/CN.៩/៨៣២) និងសម័យប្រជុំលើកទីទីហុកសិបបួន (A/CN.៩/៨៦៧); កំណត់សម្គាល់ដោយលេខាធិការដ្ឋានដែលត្រូវបានពិចារណាដោយក្រុមការងារ៖ A/CN.៩/WG.II/WP.១៨៣ និង A/CN.៩/WG.II/WP១៨៤ (សម័យប្រជុំលើកទីហុកសិបមួយ); A/CN.៩/WG.II/WP.១៨៦ និង A/CN.៩/WG.II/WP.១៨៨ (សម័យប្រជុំលើកទីហុកសិបពីរ) និង A/CN.៩/WG.II/WP.១៩៤ (សម័យប្រជុំលើកទីហុកសិបបួន)។

# មាតិកា

*ទំព័រ*


បុព្វកថា ........ iv

សេចក្តីសម្រេចដោយគណៈកម្មការស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិអនុម័ត កំណត់ចំណាំឆ្នាំ២០១៦ ស្តីពីការរៀបចំដំណើរការមជ្ឈត្តការ ........ vi

**សេចក្តីផ្តើម** ........ ១

**បញ្ជីនៃចំណុចសំខាន់សម្រាប់លទ្ធភាពពិចារណាក្នុងការរៀបចំដំណើរការមជ្ឈត្តការ** ........ ៣

**ចំណារពន្យល់** ........ ៦




#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com

Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

# សេចក្ដីសម្រេចដោយគណៈកម្មការស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ អនុម័តកំណត់ចំណាំឆ្នាំ២០១៦ ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការ[៣]

*គណៈកម្មការស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ*

*រំលឹកឡើងវិញ* សេចក្ដីសម្រេចរបស់មហាសន្និបាតលេខ ២២០៥ (XXI) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៦៦ ដែលបានបង្កើតគណៈកម្មការស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិដែលមានកាតព្វកិច្ចក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខដុមនីយកម្ម និងការបង្រួបបង្រួមបន្ថែមទៀតនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិ ហើយពាក់ព័ន្ធនឹងចំណុចនេះត្រូវគិតគូរដល់ផលប្រយោជន៍របស់បុគ្គលទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍក្នុងការពង្រីកការអភិវឌ្ឍនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិបន្ថែមទៀត

*បញ្ជាក់ឡើងវិញ* ពីគុណតម្លៃ និងកំណើននៃការប្រើប្រាស់មជ្ឈត្តការជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ

*ទទួលស្គាល់* តម្រូវការក្នុងការកែសម្រួលកំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការ[៤] ដែលត្រូវបានអនុម័តជាលើកដំបូងក្នុងឆ្នាំ១៩៩៦ ដើម្បីអនុលោមតាមការអនុវត្តមជ្ឈត្តការនាពេលបច្ចុប្បន្ន

*កត់សម្គាល់* ថាគោលបំណងនៃកំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការគឺដើម្បីរៀបរាប់ និងពណ៌នាដោយសង្ខេបអំពីចំណុចសំខាន់ដែលទាក់ទងនឹងការរៀបចំដំណើរការមជ្ឈត្តការ ហើយកំណត់ចំណាំនេះ ត្រូវបានរៀបចំដោយផ្ដោតលើមជ្ឈត្តការអន្តរជាតិ ដោយមានបំណងប្រើប្រាស់ជាលក្ខណៈទូទៅ និងសកល មិនថាមជ្ឈត្តការត្រូវបានគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តការ ឬអត់នោះទេ

*កត់សម្គាល់* ថាកំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការ មិនព្យាយាមលើកកម្ពស់ការអនុវត្តណាមួយជាឧត្តមានុវត្តនោះទេ ដោយហេតុថាបែបបទនីតិវិធី និងការអនុវត្តក្នុងមជ្ឈត្តការមានភាពខុសប្លែកគ្នា ហើយមានគុណសម្បត្តិរៀងៗខ្លួន

*កត់សម្គាល់បន្ថែម* ថាការកែសម្រួលកំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការទទួលបានអត្ថប្រយោជន៍ជាច្រើនពីការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិពាក់ព័ន្ធ ដែលសកម្មក្នុងវិស័យមជ្ឈត្តការ រួមទាំងស្ថាប័នមជ្ឈត្តការ ក៏ដូចជាអ្នកជំនាញផងដែរ

១. អនុម័ត កំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការ ឆ្នាំ២០១៦ និងផ្ដល់សិទ្ធិឱ្យលេខាធិការដ្ឋានកែសម្រួល និងបញ្ចប់អត្ថបទនៃកំណត់ចំណាំនេះដោយអនុលោមតាមការពិភាក្សារបស់គណៈកម្មការនាសម័យប្រជុំលើកទីសែសិបប្រាំបួនរបស់ខ្លួន

២. ផ្ដល់អនុសាសន៍ អំពីការប្រើប្រាស់កំណត់ចំណាំ រួមទាំងដោយគូភាគីនៃមជ្ឈត្តការ វេទិកាមជ្ឈត្តកម្ម ស្ថាប័នមជ្ឈត្តការព្រមទាំងសម្រាប់គោលបំណងនៃការសិក្សា និងការបណ្ដុះបណ្ដាលទាក់ទងនឹងការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ

៣. ស្នើសុំ អគ្គលេខាធិការបោះពុម្ពកំណត់ចំណាំរបស់ UNCITRAL ស្ដីពីការរៀបចំដំណើរការមជ្ឈត្តការ ឆ្នាំ២០១៦ រួមទាំងក្នុងទម្រង់អេឡិចត្រូនិក និងជាភាសាផ្លូវការទាំងប្រាំមួយរបស់អង្គការសហប្រជាជាតិ និងខិតខំប្រឹងប្រែងធានាថាកំណត់ចំណាំនេះត្រូវបានស្គាល់ និងអាចទទួលបានជាទូទៅ។

---

[៣] កំណត់ត្រាផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៧១ សេចក្ដីបំពេញបន្ថែមលេខ ១៧ (A/៧១/១៧) កថាខណ្ឌទី ១៥៨។

[៤] សៀវភៅប្រចាំឆ្នាំ UNCITRAL វ៉ុល XXVII ឆ្នាំ១៩៩៦ ផ្នែកទីបី ឧបសម្ព័ន្ធទី II។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com

Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

# សេចក្តីផ្តើម

## *គោលបំណងនៃកំណត់ចំណាំ*

១. គោលបំណងនៃកំណត់ចំណាំនេះគឺដើម្បីរៀបរាប់ និងពណ៌នាដោយសង្ខេបអំពីចំណុចសំខាន់ដែលពាក់ព័ន្ធនឹងការរៀបចំដំណើរការមជ្ឈត្តការ។ កំណត់ចំណាំ ត្រូវបានរៀបចំដោយផ្តោតលើមជ្ឈត្តការអន្តរជាតិ ក្នុងគោលបំណងសម្រាប់ការប្រើប្រាស់ជាលក្ខណៈទូទាំងសកល មិនថាមជ្ឈត្តការត្រូវបានចាត់ចែងដោយស្ថាប័នមជ្ឈត្តការ ឬអត់នោះទេ។

២. ដោយយល់ឃើញថាទម្រង់បែបបទនីតិវិធី និងការអនុវត្តនៅក្នុងមជ្ឈត្តការមានភាពខុសប្លែកគ្នា ហើយមានគុណសម្បត្តិរៀងៗខ្លួន កំណត់ចំណាំនេះមិនព្យាយាមលើកកម្ពស់ការអនុវត្តណាមួយជាឧត្តមានុវត្តនោះទេ។

## *លក្ខណៈមិនចងកាតព្វកិច្ចនៃកំណត់ចំណាំ*

៣. កំណត់ចំណាំមិនដាក់នូវលក្ខខណ្ឌច្បាប់ណាមួយដែលចងកាតព្វកិច្ចគូភាគី ឬវេទិកាមជ្ឈត្តកម្មនោះទេ។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចប្រើប្រាស់ ឬយោងកំណត់ចំណាំតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងក្នុងកម្រិតដែលខ្លួនយល់ឃើញថាសាកសម និងមិនចាំបាច់ប្រើប្រាស់ ឬផ្តល់ហេតុផលដែលមិនប្រើប្រាស់នូវផ្នែកជាក់លាក់ណាមួយនៃកំណត់ចំណាំនេះទេ។

៤. កំណត់ចំណាំមិនសមស្របក្នុងការប្រើជាវិធានស្តីពីមជ្ឈត្តការទេ ព្រោះវាមិនមានកាតព្វកិច្ចឱ្យគូភាគី ឬវេទិកាមជ្ឈត្តកម្មធ្វើសកម្មភាពក្នុងលក្ខណៈជាក់លាក់ណាមួយឡើយ។ បញ្ហាផ្សេងៗដែលបានពិភាក្សានៅក្នុងកំណត់ចំណាំនេះអាចត្រូវបានគ្របដណ្តប់ដោយវិធានស្តីពីមជ្ឈត្តការជាធរមាន។ ការប្រើប្រាស់កំណត់ចំណាំមិនបង្ហាញពីការកែប្រែណាមួយលើវិធានស្តីពីមជ្ឈត្តការនោះទេ។

៥. កំណត់ចំណាំគ្របដណ្តប់លើ ទោះបីជាមិនទាំងអស់ ស្ថានភាពជាច្រើនដែលអាចកើតឡើងនៅក្នុងដំណើរការមជ្ឈត្តការ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងមជ្ឈត្តការជាច្រើន មានតែបញ្ហាដែលត្រូវបានលើកឡើងមួយចំនួនក្នុងកំណត់ចំណាំប៉ុណ្ណោះ នឹងកើតឡើង ឬចាំបាច់ត្រូវយកមកពិចារណា។ កាលៈទេសៈជាក់លាក់នៃមជ្ឈត្តការនឹងបង្ហាញថាតើបញ្ហាណាមួយដែលមានសារៈប្រយោជន៍ក្នុងការពិចារណា និងនៅដំណាក់កាលណានៃដំណើរការមជ្ឈត្តការដែលបញ្ហាទាំងនោះគួរត្រូវបានពិចារណា។ ដូច្នេះ មិនគួរលើកឡើងពីបញ្ហាណាមួយទេ លុះត្រាតែ និងរហូតដល់បញ្ហានោះមើលទៅនឹងចាំបាច់ត្រូវធ្វើការដោះស្រាយ។

## *លក្ខណៈនៃមជ្ឈត្តការ*

៦. មជ្ឈត្តការ គឺជាដំណើរការដែលមានភាពបត់បែនក្នុងការដោះស្រាយវិវាទ គូភាគីមានសេរីភាពក្នុងការព្រមព្រៀងលើនីតិវិធីដែលត្រូវគោរពតាមដោយវេទិកាមជ្ឈត្តកម្មក្នុងការប្រព្រឹត្តទៅនៃដំណើរការមជ្ឈត្តការ ដែលជាកម្មវត្ថុនៃបទប្បញ្ញត្តិអនុវត្តដោយបង្ខំនៃច្បាប់ស្តីពីមជ្ឈត្តការជាធរមាន។ ស្វ័យភាពរបស់គូភាគីក្នុងការកំណត់នីតិវិធីគឺមានលក្ខណៈពិសេសសំខាន់ក្នុងមជ្ឈត្តការអន្តរជាតិ។ ស្វ័យភាពនេះអនុញ្ញាតឱ្យគូភាគីជ្រើសរើស និងកែសម្រួលនីតិវិធីទៅតាមការចង់បាន និងភាពចាំបាច់របស់ពួកគេដោយមិនត្រូវបានរារាំងដោយ ភាពផ្ទុយគ្នានៃការអនុវត្ត និងទំនៀមទម្លាប់ច្បាប់ដែលអាចមាន។

៧. គូភាគីអនុវត្តស្វ័យភាពរបស់ពួកគេ ជាធម្មតាតាមរយៈការព្រមព្រៀងលើសំណុំនៃវិធានស្តីពីមជ្ឈត្តការក្នុងការគ្រប់គ្រងដំណើរការមជ្ឈត្តការ។ អត្ថប្រយោជន៍នៃការជ្រើសរើសសំណុំនៃវិធានស្តីពីមជ្ឈត្តការ

គឺថានីតិវិធីកាន់តែអាចព្យាករណ៍បាន ហើយគូភាគី និងវេទិកាមជ្ឈត្តកម្មអាចសន្សំសំចៃពេលវេលា និងកម្រៃដោយការប្រើប្រាស់សំណុំវិធានស្តីពីមជ្ឈត្តការដែលមានស្រាប់ដែលគូភាគីអាចស្គាល់ និងត្រូវបានព្រាងដោយការយកចិត្តទុកដាក់ដោយអ្នកប្រកបវិជ្ជាជីវៈដែលមានបទពិសោធន៍ ហើយជារឿយៗ ត្រូវបានអនុវត្ត និងបកស្រាយជាច្រើនដោយវេទិកាមជ្ឈត្តកម្ម និងតុលាការ ហើយត្រូវបានផ្តល់មតិយោបល់កែលម្អដោយអ្នកប្រកបវិជ្ជាជីវៈ និងបញ្ញាវ័ន្ត។ បន្ថែមពីនេះ សំណុំនៃវិធានស្តីពីមជ្ឈត្តការដែលបានជ្រើសរើស (ដែលបានកែប្រែដោយគូភាគីក្នុងវិសាលភាពដែលបានអនុញ្ញាត) ជាធម្មតាមានឧត្តមានុភាពលើបទប្បញ្ញត្តិស្ម័គ្រចិត្តនៃច្បាប់ស្តីពីមជ្ឈត្តការជាធរមាន ហើយប្រហែលជាឆ្លើយតបទៅនឹងកម្មវត្ថុរបស់គូភាគីប្រសើរជាងបទប្បញ្ញត្តិដើមនៃច្បាប់ស្តីពីមជ្ឈត្តការជាធរមាន។ ក្នុងករណីដែលគូភាគីមិនទាន់បានព្រមព្រៀងគ្នានៅដំណាក់កាលដំបូងពីសំណុំនៃវិធានស្តីពីមជ្ឈត្តការ ពួកគេនៅតែអាចព្រមព្រៀងលើសំណុំវិធាននេះ បន្ទាប់ពីមជ្ឈត្តការបានចាប់ផ្តើម (សូមមើលខាងក្រោមកថាខណ្ឌទី ១០)។

៨. ក្នុងវិសាលភាពដែលគូភាគីមិនបានព្រមព្រៀងលើនីតិវិធីដែលត្រូវគោរពតាមដោយវេទិកាមជ្ឈត្តកម្ម ឬលើសំណុំនៃវិធានស្តីពីមជ្ឈត្តការដើម្បីគ្រប់គ្រងដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មមានឆន្ទានុសិទ្ធិក្នុងការធ្វើដំណើរការនីតិវិធីនេះតាមលក្ខណៈដែលខ្លួនចាត់ទុកថាសមស្រប ស្របតាមវិធានស្តីពីមជ្ឈត្តការជាធរមាន។ ច្បាប់ស្តីពីមជ្ឈត្តការជាធម្មតាផ្តល់ឱ្យវេទិកាមជ្ឈត្តកម្មនូវឆន្ទានុសិទ្ធ និងភាពបត់បែនយ៉ាងទូលំទូលាយ ក្នុងការធ្វើដំណើរការមជ្ឈត្តការ ប្រសិនបើភាពយុត្តិធម៌ សមធម៌ និងប្រសិទ្ធភាពត្រូវបានឃ្លាំមើល។[៥] សំណុំនៃវិធានស្តីពីមជ្ឈត្តការដែលត្រូវបានជ្រើសរើសដោយគូភាគីក៏នឹងកំណត់ពីឆន្ទានុសិទ្ធិរបស់វេទិកាមជ្ឈត្តកម្មក្នុងការធ្វើដំណើរការមជ្ឈត្តការតាមរយៈការពង្រឹង ឬកម្រិតឆន្ទានុសិទ្ធិនោះ។ ឆន្ទានុសិទ្ធិ និងភាពបត់បែនមានសារៈប្រយោជន៍ ដោយសារតែឆន្ទានុសិទ្ធិ និងភាពបត់បែនអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មធ្វើការសម្រេចចិត្តលើការរៀបចំដំណើរការមជ្ឈត្តការដោយគិតគូរពីកាលៈទេសៈនៃសំណុំរឿង និងការរំពឹងទុករបស់គូភាគី ខណៈពេលដែលអនុលោមតាមលក្ខខណ្ឌដំណើរការនីតិវិធីត្រឹមត្រូវ។ ករណីដែលគូភាគីមិនបានព្រមព្រៀងលើនីតិវិធី ឬវិធានស្តីពីមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចទទួលយកការណែនាំពីសំណុំវិធានមជ្ឈត្តការ និងប្រើប្រាស់ជាឯកសារយោង។

[៥] ឧទាហរណ៍ មាត្រា ១៩ នៃច្បាប់គំរូរបស់ UNCITRAL ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ (ដោយមានការធ្វើវិសោធនកម្មដែលបានអនុម័តក្នុងឆ្នាំ២០០៦) ចែងដូចតទៅ៖ "(១) ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃច្បាប់នេះ ភាគីមានសេរីភាពក្នុងការព្រមព្រៀងលើនីតិវិធីដែលត្រូវគោរពតាមដោយវេទិកាមជ្ឈត្តកម្មក្នុងការធ្វើដំណើរការនីតិវិធី។ (២) ការខកខានក្នុងការព្រមព្រៀងនេះ វេទិកាមជ្ឈត្តកម្មអាច ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃច្បាប់នេះ ធ្វើដំណើរការមជ្ឈត្តការក្នុងលក្ខណៈដែលខ្លួនចាត់ទុកថាសមស្រប។ អំណាចដែលប្រគល់ឱ្យវេទិកាមជ្ឈត្តកម្មរួមមាន អំណាចក្នុងការកំណត់ពីការទទួលយកបាន ការពាក់ព័ន្ធ ភាពសំខាន់ និងទម្ងន់នៃភស្តុតាងណាមួយ"។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

# បញ្ជីនៃចំណុចសំខាន់សម្រាប់លទ្ធភាពពិចារណាក្នុងការរៀបចំដំណើរការមជ្ឈត្តការ

កថាខណ្ឌ


១. ការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំដំណើរការមជ្ឈត្តការ កិច្ចប្រជុំនីតិវិធី.................. ៩-១៩

(ក) គោលការណ៍ទូទៅនៃការពិគ្រោះយោបល់រវាងគូភាគី និងវេទិកាមជ្ឈត្តកម្ម................ ៩-១០

(ខ) កិច្ចប្រជុំនីតិវិធី........................................ ១១-១៩

(i) កិច្ចប្រជុំនីតិវិធីដំបូង........................................ ១១-១៣

(ii) កិច្ចប្រជុំនីតិវិធីបន្តបន្ទាប់........................................ ១៤

(iii) ការកែប្រែសេចក្តីសម្រេចស្តីពីការរៀបចំដំណើរការមជ្ឈត្តការ................................ ១៥

(iv) កំណត់ត្រាលទ្ធផលនៃកិច្ចប្រជុំនីតិវិធី........................................ ១៦

(v) វត្តមានរបស់គូភាគី........................................ ១៧-១៩

២. ភាសា ឬភាសានៃដំណើរការមជ្ឈត្តការ........................................ ២០-២៦

(ក) ការកំណត់ភាសា ........................................ ២០

(ខ) លទ្ធភាពនៃតម្រូវការក្នុងការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់.................... ២១-២៣

(គ) ពហុភាសា........................................ ២៤-២៥

(ឃ) កម្រៃសេវានៃការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់........................................ ២៦

៣. ទីកន្លែងធ្វើមជ្ឈត្តការ........................................ ២៧-៣១

(ក) ការកំណត់ទីកន្លែងធ្វើមជ្ឈត្តការ........................................ ២៧

(ខ) ផលវិបាកផ្នែកច្បាប់ និងផ្នែកផ្សេងទៀតនៃកន្លែងធ្វើមជ្ឈត្តការ............................. ២៨-៣០

(គ) លទ្ធភាពនៃការបើកសវនាការ និងកិច្ចប្រជុំនៅទីតាំងខុសពីកន្លែងធ្វើមជ្ឈត្តការ............... ៣១

៤. ជំនួយផ្នែករដ្ឋបាលសម្រាប់វេទិកាមជ្ឈត្តកម្ម........................................ ៣២-៣៨

(ក) ជំនួយផ្នែករដ្ឋបាល និងស្ថាប័នមជ្ឈត្តការ........................................ ៣២-៣៤

(ខ) លេខាធិការនៃវេទិកាមជ្ឈត្តកម្ម........................................ ៣៥-៣៨

៥. កម្រៃសេវាមជ្ឈត្តការ........................................ ៣៩-៤៩

(ក) ប្រភេទនៃកម្រៃសេវា........................................ ៣៩-៤២

(ខ) ការតម្កល់កម្រៃសេវា........................................ ៤៣-៤៦

(គ) ការកំណត់ និងការបែងចែកកម្រៃសេវា........................................ ៤៧-៤៩

៦. កិច្ចព្រមព្រៀងដែលអាចមានលើការរក្សាការសម្ងាត់ តម្លាភាពក្នុងធ្វើមជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋដោយផ្អែកលើសន្ធិសញ្ញា........................................ ៥០-៥៥

(ក) កិច្ចព្រមព្រៀងលើការរក្សាការសម្ងាត់........................................ ៥០-៥៤

(ខ) តម្លាភាពមជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋ ដោយផ្អែកលើសន្ធិសញ្ញា............................ ៥៥

៧. មធ្យោបាយទំនាក់ទំនង........................................ ៥៦-៥៩

(ក) ការកំណត់មធ្យោបាយទំនាក់ទំនង........................................ ៥៦-៥៧

(ខ) មធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក........................................ ៥៨

(គ) លំហូរនៃការទំនាក់ទំនង ........ ៥៩

៨. វិធានការបណ្ដោះអាសន្ន ........ ៦០-៦៤
(ក) ការផ្ដល់វិធានការបណ្ដោះអាសន្ន ........ ៦០-៦២
(ខ) កម្រៃសេវា និងការខូចខាតដែលកើតឡើងពីវិធានការបណ្ដោះអាសន្ន ប្រាតិភោគសម្រាប់កម្រៃសេវា និងការខូចខាត ........ ៦៣-៦៤

៩. សេចក្ដីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្ដីថ្លែងរបស់សាក្សី របាយការណ៍របស់អ្នកជំនាញ និងភស្តុតាងជាឯកសារ ........ ៦៥-៦៦

១០. ការអនុវត្តជាក់ស្ដែងលម្អិតពាក់ព័ន្ធនឹងទម្រង់ និងវិធីសាស្ត្រនៃការដាក់សេចក្ដីថ្លែង ........ ៦៧

១១. ចំណុចនៃវិវាទ និងការទាមទារ ឬការសង្គ្រោះដែលទាមទារ ........ ៦៨-៧១
(ក) ការរៀបចំបញ្ជីនៃចំណុចវិវាទ ........ ៦៨
(ខ) ការកំណត់លំដាប់នៃចំណុចវិវាទនឹងត្រូវសម្រេច លទ្ធភាពនៃការបំបែកដំណើរការនីតិវិធី ........ ៦៩-៧០
(គ) ការទាមទារ ឬការសង្គ្រោះដែលទាមទារ ........ ៧១

១២. ការសះជាដោយសន្តិវិធី ........ ៧២

១៣. ភស្តុតាងឯកសារ ........ ៧៣-៨៥
(ក) ការកំណត់ពេលវេលាសម្រាប់ការដាក់ភស្តុតាងជាឯកសារដោយគូភាគី ផលវិបាកនៃខកខានក្នុងការដាក់ភស្តុតាង ឬការដាក់ភស្តុតាងយឺតយ៉ាវ ........ ៧៣-៧៥
(ខ) សំណើសុំញ្ញើញឯកសារ ........ ៧៦-៧៨
(គ) ភស្តុតាងដែលទទួលបានដោយវេទិកាមជ្ឈត្តកម្មពីតតិយជន ........ ៧៩
(ឃ) ការអះអាងអំពីប្រភព និងភាពត្រឹមត្រូវនៃភស្តុតាងជាឯកសារ ........ ៨០-៨១
(ង) ការបង្ហាញភស្តុតាងជាឯកសារ ........ ៨២-៨៥

១៤. សាក្សីនៃអង្គហេតុ ........ ៨៦-៩១
(ក) ការកំណត់អត្តសញ្ញាណសាក្សីនៃអង្គហេតុ ទំនាក់ទំនងជាមួយគូភាគី និងអ្នកតំណាងរបស់ពួកគេ ........ ៨៦-៩០
(i) សេចក្ដីថ្លែងរបស់សាក្សី និងការជូនដំណឹងជាមុន ........ ៨៦-៨៨
(ii) ថាតើភាគីមួយ ឬបុគ្គលដែលទាក់ទងនឹងភាគីមួយអាចនឹងត្រូវបានស្ដាប់ក្នុងនាមជាសាក្សីឬទេ ........ ៨៩
(iii) លក្ខណៈនៃទំនាក់ទំនងរបស់ភាគី ឬអ្នកតំណាងរបស់ខ្លួនជាមួយសាក្សី ........ ៩០
(ខ) របៀបទទួលយកភស្តុតាងផ្ទាល់មាត់របស់សាក្សី ........ ៩១

១៥. អ្នកជំនាញ ........ ៩២-១០៧
(ក) ប្រភេទនៃអ្នកជំនាញ និងការជ្រើសរើស ........ ៩២-៩៣
(ខ) អ្នកជំនាញដែលតែងតាំងដោយភាគី សាក្សីជំនាញ ........ ៩៤-១០០
(គ) អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម ........ ១០១-១០៧
(i) មុខងាររបស់អ្នកជំនាញ ដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម ........ ១០១-១០៥
(ii) លក្ខខណ្ឌយោងរបស់អ្នកជំនាញដែលតែងតាំងដោយវេទិកាមជ្ឈត្តកម្ម ........ ១០៦-១០៧

១៦. ការត្រួតពិនិត្យទីតាំង ទ្រព្យសម្បត្តិ ឬទំនិញ........................................................ ១០៨-១១៣
(ក) ភស្តុតាងជាក់ស្ដែង........................................................................................ ១០៩
(ខ) ការត្រួតពិនិត្យទីតាំង ទ្រព្យសម្បត្តិ ឬទំនិញ................................................ ១១០-១១៣

១៧. សវនាការ................................................................................................... ១១៤-១៣៦
(ក) សេចក្ដីសម្រេចថាតើត្រូវបើកសវនាការ ឬទេ................................................. ១១៤-១១៥
(ខ) កាលវិភាគនៃសវនាការ................................................................................ ១១៦-១២០
(គ) របៀបនៃការធ្វើសវនាការ............................................................................. ១២១-១៣៣
(i) ការអនុវត្តផ្សេងៗគ្នា.......................................................................................... ១២១
(ii) ការធ្វើសវនាការដោយផ្ទាល់ ឬពីចម្ងាយ......................................................... ១២២
(iii) ការសម្រេចថាតើសាក្សីនៃអង្គហេតុ និងសាក្សីជំនាញ ("សាក្សី") មួយណានឹងផ្ដល់ សក្ខីកម្មផ្ទាល់មាត់........................................................................................ ១២៣
(iv) ការមិនចូលបង្ហាញខ្លួនរបស់សាក្សី................................................................ ១២៤
(v) ការអញ្ជើញសាក្សីដោយវេទិកាមជ្ឈត្តកម្ម........................................................ ១២៥
(vi) ថាតើសក្ខីកម្មផ្ទាល់មាត់នឹងត្រូវបានផ្ដល់ក្រោមសម្បថ ឬការអះអាងឬទេ ហើយ ប្រសិនបើដូច្នេះតើក្រោមទម្រង់បែបណា......................................................... ១២៦
(vii) លំដាប់នៃការធ្វើបទបង្ហាញនៅសវនាការ............................................. ១២៧-១២៨
(viii) របៀបដែលសាក្សីនៃអង្គហេតុ និងសាក្សីជំនាញ ("សាក្សី") នឹងត្រូវបានស្ដាប់....... ១២៩-១៣០
(ix) ថាតើសាក្សីនៃអង្គហេតុអាចស្ថិតនៅក្នុងបន្ទប់សវនាការនៅពេលដែលពួកគេ មិនផ្ដល់សក្ខីកម្មដែរ ឬទេ.................................................................. ១៣១-១៣២
(x) ការដាក់ភស្តុតាងថ្មី............................................................................................ ១៣៣
(ឃ) ការរៀបចំសម្រាប់កំណត់ហេតុនៃសវនាការ................................................... ១៣៤-១៣៥
(ង) ការដាក់ឯកសារក្រោយសវនាការ........................................................................ ១៣៦

១៨. មជ្ឈត្តការពហុភាគី................................................................................... ១៣៧-១៣៨

១៩. ការចូលរួមពីតតិយជន និងការរួមបញ្ចូលមជ្ឈត្តការ............................................. ១៣៩-១៤៣
(ក) ការចូលរួមពីតតិយជន.................................................................................. ១៣៩-១៤១
(ខ) ការរួមបញ្ចូលមជ្ឈត្តការ................................................................................ ១៤២-១៤៣

២០. តម្រូវការដែលអាចមានពាក់ព័ន្ធនឹងទម្រង់ ខ្លឹមសារ ការដាក់ឯកសារ ការចុះឈ្មោះ និងការប្រគល់មជ្ឈត្តវិនិច្ឆ័យ.................................................................... ១៤៤-១៤៦



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

# ចំណារពន្យល់

## ១. ការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំដំណើរការមជ្ឈត្តការ កិច្ចប្រជុំនីតិវិធី

### *(ក) គោលការណ៍ទូទៅនៃការពិគ្រោះយោបល់រវាងគូភាគី និងវេទិកាមជ្ឈត្តកម្ម*

៩. វេទិកាមជ្ឈត្តកម្មជាធម្មតាឱ្យគូភាគីចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើការរៀបចំដំណើរការមជ្ឈត្តការ ហើយប្រសិនបើអាចស្នើសុំការព្រមព្រៀងរបស់ពួកគេ។ ការពិគ្រោះយោបល់បែបនេះគឺមានសារៈសំខាន់ណាស់សម្រាប់លក្ខណៈនៃការព្រមព្រៀងរបស់មជ្ឈត្តការ ហើយជាទូទៅត្រូវបានធ្វើឡើងដោយគោរពតាមសេចក្តីសម្រេចរបស់ស្ថាប័នភាគច្រើនដែលត្រូវបានលើកឡើងនៅក្នុងកំណត់ចំណាំនេះ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីសង្ខេបឱ្យខ្លី ភាពចាំបាច់ក្នុងការពិគ្រោះយោបល់បែបនេះគឺមិនចាំបាច់ត្រូវបានលើកឡើងម្តងទៀតនៅក្នុងកំណត់ចំណាំរាល់ពេលដែលការពិគ្រោះយោបល់ត្រូវបានរំពឹងថានឹងមាននោះទេ។

១០. ដូចគ្នានេះដែរ គូភាគីជាធម្មតាពិគ្រោះយោបល់ជាមួយវេទិកាមជ្ឈត្តកម្ម នៅពេលដែលពួកគេយល់ព្រមក្នុងចំណោមខ្លួនពួកគេលើបញ្ហាណាមួយដែលអាចប៉ះពាល់ដល់ការរៀបចំដំណើរការរបស់វេទិកាមជ្ឈត្តកម្ម។ នៅពេលដែលការព្រមព្រៀងរបស់គូភាគីប៉ះពាល់ដល់គម្រោងរបស់មជ្ឈត្តករ គូភាគីជាធម្មតានឹងស្នើសុំការព្រមព្រៀងរបស់វេទិកាមជ្ឈត្តកម្មផងដែរ។ បន្ថែមពីលើនេះ ប្រសិនបើគូភាគីព្រមព្រៀងបន្ទាប់ពីវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើង ថាស្ថាប័នមជ្ឈត្តការមួយនឹងចាត់ចែងមជ្ឈត្តការ ជាធម្មតាគូភាគីនឹងធានាថាមានការព្រមព្រៀងរបស់វេទិកាមជ្ឈត្តកម្ម និងស្ថាប័ននោះ។

### *(ខ) កិច្ចប្រជុំនីតិវិធី*

(i) កិច្ចប្រជុំនីតិវិធីដំបូង

១១. វេទិកាមជ្ឈត្តកម្មគួរតែផ្តល់ឱ្យគូភាគីឱ្យបានឆាប់រហ័សនូវការចង្អុលបង្ហាញពីការរៀបចំដំណើរការមជ្ឈត្តការ និងរបៀបដែលវេទិកាមជ្ឈត្តកម្មចង់ដំណើរការបន្ត។ ជាពិសេស នៅក្នុងមជ្ឈត្តការអន្តរជាតិ គូភាគីអាចសុំនឹងបែបបទខុសគ្នានៃដំណើរការមជ្ឈត្តការ ហើយបើគ្មានការណែនាំបែបនេះទេ ពួកគេអាចនឹងជួបប្រទះទិដ្ឋភាពជាក់លាក់នៃដំណើរការមជ្ឈត្តការដែលមិនអាចព្យាករណ៍ទុកជាមុន និងពិបាកក្នុងការត្រៀមខ្លួន។

១២. តាមវិធីសាស្ត្រនៃការពិគ្រោះយោបល់ជាមួយគូភាគី វេទិកាមជ្ឈត្តកម្មអាចពិចារណា នៅពេលចាប់ផ្តើមនៃដំណើរការមជ្ឈត្តការ បើកកិច្ចប្រជុំ ឬសន្និសីទអំពីការគ្រប់គ្រងសំណុំរឿងដែលកំណត់ការរៀបចំនៃដំណើរការមជ្ឈត្តការ និងកាលវិភាគនៃនីតិវិធី។

១៣. បញ្ហាមួយចំនួនដែលត្រូវបានគ្របដណ្តប់ដោយកំណត់ចំណាំនេះ ជាធម្មតានឹងត្រូវបានដោះស្រាយនៅកិច្ចប្រជុំនីតិវិធីដំបូង ហើយដូច្នេះបង្កើតបានជាមូលដ្ឋានសម្រាប់ការយល់ដឹងរួមអំពីនីតិវិធីក្នុងចំណោមគូភាគី និងវេទិកាមជ្ឈត្តកម្ម។ ប្រសិនបើកាលវិភាគនៃនីតិវិធីត្រូវបានធ្វើឡើង ជាឧទាហរណ៍ កាលវិភាគនៃនីតិវិធីអាចចង្អុលបង្ហាញពីការកំណត់ពេលវេលាសម្រាប់ការទំនាក់ទំនងនៃសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្តីថ្លែងរបស់សាក្សី របាយការណ៍អ្នកជំនាញ និងភស្តុតាងជាឯកសារ ដូច្នេះគូភាគីអាចរៀបចំផែនការបានជាមុនក្នុងដំណើរការមជ្ឈត្តការ។ កាលវិភាគនៃនីតិវិធីអាចរួមបញ្ចូលកាលបរិច្ឆេទបណ្តោះអាសន្នសម្រាប់សវនាការ។ ក្នុងការរៀបចំកាលវិភាគនៃនីតិវិធី គូភាគី និងវេទិកាមជ្ឈត្តកម្មក៏អាចពិចារណាថាតើការកំណត់ពេលវេលាដោយច្បាប់ និង/ឬការកំណត់ពេលដោយបង្ខំ

ណាមួយលើអំឡុងពេលនៃដំណើរការមជ្ឈត្តការត្រូវបានចែងនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការ ឬវិធានស្តីពីមជ្ឈត្តការជាធរមាន ឬទេ។

(ii) កិច្ចប្រជុំនីតិវិធីបន្តបន្ទាប់

១៤. វេទិកាមជ្ឈត្តកម្មជាទូទៅបើកកិច្ចប្រជុំនីតិវិធីបន្ថែម (រួមទាំងកិច្ចប្រជុំផ្សេងទៀតដែលជួនកាលហៅថា "សន្និសីទត្រៀម" ឬ "សន្និសីទមុនសវនាការ") នៅដំណាក់កាលបន្តបន្ទាប់នៃដំណើរការមជ្ឈត្តការ។ កិច្ចប្រជុំនីតិវិធីមានសារៈសំខាន់ដោយសារតែកិច្ចប្រជុំទាំងនេះកំណត់ដំណាក់កាលសម្រាប់ដំណើរការមជ្ឈត្តការ និងមានគោលបំណងធានានូវប្រសិទ្ធភាពនៃដំណើរការ។ ជាឧទាហរណ៍ កិច្ចប្រជុំនីតិវិធីអាចត្រូវបានប្រើសម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការវាយតម្លៃឡើងវិញថាតើការដាក់សេចក្តីថ្លែងបន្ថែមត្រូវបានតម្រូវ ឬភស្តុតាងបន្ថែមគួរត្រូវបានបង្ហាញដែរទេ ក៏ដូចជាដើម្បីពិភាក្សាអំពីបញ្ហាទាក់ទងនឹងការរៀបចំសវនាការ។ កាលវិភាគនៃនីតិវិធីអាចត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមវឌ្ឍនភាពនៃដំណើរការមជ្ឈត្តការ។

(iii) ការកែប្រែសេចក្តីសម្រេចស្តីពីការរៀបចំដំណើរការមជ្ឈត្តការ

១៥. សេចក្តីសម្រេចស្តីពីការរៀបចំដំណើរការមជ្ឈត្តការអាចត្រូវបានពិនិត្យឡើងវិញ និងកែប្រែនៅដំណាក់កាលពាក់ព័ន្ធនៃដំណើរការមជ្ឈត្តការដោយវេទិកាមជ្ឈត្តកម្ម។ ទោះជាយ៉ាងណាក៏ដោយ វេទិកាមជ្ឈត្តកម្មគួរតែប្រុងប្រយ័ត្នក្នុងការកែប្រែការរៀបចំនីតិវិធី ជាពិសេសករណីដែលគូភាគីបានធ្វើសកម្មភាពដោយផ្អែកលើការរៀបចំទាំងនោះ។ បន្ថែមពីនេះទៀត វេទិកាមជ្ឈត្តកម្មប្រហែលជាមិនអាចកែប្រែការរៀបចំនីតិវិធីបានទេ ក្នុងវិសាលភាពដែលការរៀបចំទាំងនោះកើតចេញពីការព្រមព្រៀងរវាងគូភាគី។ ប្រសិនបើការកែប្រែមានភាពចាំបាច់ វេទិកាមជ្ឈត្តកម្មនឹងស្នើសុំការព្រមព្រៀងពីគូភាគី។

(iv) កំណត់ត្រាលទ្ធផលនៃកិច្ចប្រជុំនីតិវិធី

១៦. កំណត់ត្រាលទ្ធផលនៃកិច្ចប្រជុំនីតិវិធីអាចមានទម្រង់ផ្សេងៗគ្នាអាស្រ័យលើសារៈសំខាន់របស់កំណត់ត្រា ដូចជាសេចក្តីបង្គាប់នីតិវិធី កំណត់ហេតុសង្ខេប ឬការទំនាក់ទំនងធម្មតាក្នុងចំណោមគូភាគី និងវេទិកាមជ្ឈត្តកម្ម។ ជាធម្មតា វេទិកាមជ្ឈត្តកម្មកត់ត្រានូវវិធាននៃនីតិវិធីដែលត្រូវបានកំណត់ដើម្បីអនុវត្តក្នុងដំណើរការមជ្ឈត្តការតាមសេចក្តីបង្គាប់នីតិវិធី។ លទ្ធផលនៃកិច្ចប្រជុំនីតិវិធីអាចត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬធ្វើឡើងដោយផ្ទាល់មាត់ជាមុននិងកត់ត្រាជាលាយលក្ខណ៍អក្សរជាក្រោយបន្ទាប់ពីកិច្ចប្រជុំនីតិវិធី។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើត្រូវមានប្រតិចារិក ដែលអាចផ្តល់នូវកំណត់ត្រាច្បាស់លាស់នៃកិច្ចប្រជុំតាមនីតិវិធីឬទេ (សូមមើលខាងក្រោមកថាខណ្ឌទី ១៣៥)។

(v) វត្តមានរបស់គូភាគី

១៧. ជាទូទៅ គូភាគីគួរតែបង្ហាញខ្លួននៅក្នុងកិច្ចប្រជុំនីតិវិធី បន្ថែមលើអ្នកតំណាងដែលពួកគេបានតែងតាំង។

១៨. ប្រសិនបើភាគីណាម្ខាងមិនចូលរួម ឬត្រូវបានតំណាងនៅក្នុងកិច្ចប្រជុំនីតិវិធីនោះទេ វេទិកាមជ្ឈត្តកម្មគួរតែធានាថាភាគីដែលមិនចូលរួមមានឱកាសចូលរួមក្នុងដំណាក់កាលបន្តបន្ទាប់នៃដំណើរការមជ្ឈត្តការ និងបង្ហាញសំណុំរឿងរបស់ខ្លួន។ កាលវិភាគនៃនីតិវិធី ប្រសិនបើត្រូវបានបង្កើតឡើងគួរតែផ្តល់ឱកាសបែបនេះ។

១៩. កិច្ចប្រជុំនីតិវិធីអាចត្រូវបានធ្វើឡើងទាំង ដោយមានវត្តមានផ្ទាល់របស់អ្នកចូលរួមទាំងអស់ ឬពីចម្ងាយតាមរយៈមធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក។ វេទិកាមជ្ឈត្តកម្មអាចពិចារណា ក្នុងករណី



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com

Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

នីមួយៗ ថាតើគួររៀបចំកិច្ចប្រជុំដោយផ្ទាល់ ដែលអាចសម្រួលដល់ការទំនាក់ទំនងបុគ្គល ឬប្រើមធ្យោបាយពីចម្ងាយ ដែលអាចកាត់បន្ថយការចំណាយ (សូមមើលខាងក្រោមផងដែរ កថាខណ្ឌទី ១២២)។

## ២. ភាសា ឬភាសានៃដំណើរការមជ្ឈត្តការ

### *(ក) ការកំណត់ភាសា*

២០. គូភាគីអាចព្រមព្រៀងលើភាសាមួយ ឬច្រើនដែលដំណើរការមជ្ឈត្តការនឹងត្រូវបានធ្វើឡើង។ ការព្រមព្រៀងបែបនេះជានាទាថាគូភាគីមានសមត្ថភាពក្នុងការទំនាក់ទំនងនូវភាសាមួយ ឬច្រើននៃដំណើរការមជ្ឈត្តការ។ ក្នុងករណីដែលមិនមានការព្រមព្រៀងបែបនេះ វេទិកាមជ្ឈត្តកម្មនឹងកំណត់ភាសាមួយឬច្រើន។ លក្ខខណ្ឌទូទៅសម្រាប់ការកំណត់នោះគឺភាសាចម្បងនៃកិច្ចសន្យា ឬលិខិតតុបករណ៍គតិយុត្តផ្សេងទៀតដែលស្ថិតក្រោមវិវាទដែលបានកើតឡើង និងភាសាដែលត្រូវបានប្រើប្រាស់ជាទូទៅដោយគូភាគីក្នុងការទំនាក់ទំនងរបស់ពួកគេ។ គូភាគី និងវេទិកាមជ្ឈត្តកម្មជាធម្មតាជ្រើសរើសយកភាសាតែមួយក្នុងការដំណើរការនីតិវិធីមជ្ឈត្តការ (សូមមើលខាងក្រោមកថាខណ្ឌទី ២៤)។

### *(ខ) លទ្ធភាពនៃតម្រូវការសម្រាប់ការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់*

២១. គូភាគីអាចពឹងផ្អែកលើភស្តុតាងជាឯកសារ សេចក្តីសម្រេចរបស់តុលាការ និងសំណេរច្បាប់ ("អត្ថបទច្បាប់") ដែលមិនមែនជាភាសានៃដំណើរការមជ្ឈត្តការ។ ក្នុងការកំណត់ថាតើត្រូវធ្វើការបកប្រែឯកសារទាំងនោះទាំងស្រុង ឬដោយផ្នែក វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើគូភាគី និងវេទិកាមជ្ឈត្តកម្មអាចយល់ពីខ្លឹមសារនៃឯកសារទាំងនោះដោយគ្មានការបកប្រែ ឬទេ ហើយថាតើមានវិធានការសន្សំសំចៃប្រកបដោយប្រសិទ្ធិភាពក្នុងការជំនួសការបកប្រែនូវឯកសារទាំងស្រុងដែរឬទេ (ដូចជាការបកប្រែផ្នែកពាក់ព័ន្ធនៃឯកសារ ឬការបកប្រែគំរូតែមួយសម្រាប់ឯកសារដែលមានខ្លឹមសារស្រដៀងគ្នា ឬមានខ្លឹមសារស្តង់ដារ)។

២២. ការបកប្រែផ្ទាល់មាត់អាចជាការចាំបាច់ករណីដែលសាក្សី ឬអ្នកជំនាញដែលបង្ហាញខ្លួននៅក្នុងសវនាការមិនអាចផ្តល់សក្ខីកម្មជាភាសានៃដំណើរការមជ្ឈត្តការ។ សាក្សី និងអ្នកជំនាញដែលយល់ភាសានៃដំណើរការមជ្ឈត្តការអាចនៅតែត្រូវការការបកប្រែដោយផ្ទាល់មាត់ម្តងម្កាល ជាជាងការបកប្រែដោយផ្ទាល់មាត់ទាំងស្រុង។ ប្រសិនបើការបកប្រែផ្ទាល់មាត់ចាំបាច់ គួរតែពិចារណាថាតើការបកប្រែផ្ទាល់មាត់នឹងធ្វើក្នុងពេលដំណាលគ្នា ឬបន្ទាប់ពីនិយាយហើយ។ ខណៈពេលដែលការបកប្រែដោយផ្ទាល់មាត់ក្នុងពេលដំណាលគ្នាគឺចំណាយពេលតិច ការបកប្រែបន្ទាប់ពីការនិយាយអនុញ្ញាតឱ្យមានការត្រួតពិនិត្យកាន់តែជិតដល់អំពីភាពត្រឹមត្រូវនៃការបកប្រែ។

២៣. ទំនួលខុសត្រូវក្នុងការរៀបចំការបកប្រែឯកសារ និង/ឬការបកប្រែដោយផ្ទាល់មាត់ភាគច្រើនជាបន្ទុករបស់គូភាគី ទោះបីជានៅក្នុងមជ្ឈត្តការដែលគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តការក៏ដោយ។

### *(គ) ពហុភាសា*

២៤. ដោយសារតែការលំបាកពាក់ព័ន្ធនឹងការរៀបចំដំណើរការ និងកម្រៃបន្ថែមជាច្រើន ដែលជារឿយៗកើតឡើងពីការដំណើរការនីតិវិធីមជ្ឈត្តការច្រើនជាងមួយភាសា គូភាគី និងវេទិកាមជ្ឈត្តកម្មជាទូទៅជ្រើសរើសភាសាមួយប៉ុណ្ណោះក្នុងការដំណើរការនីតិវិធីមជ្ឈត្តការ លុះត្រាតែមានកាលៈទេសៈជាក់លាក់ដែលនឹងតម្រូវឱ្យប្រើប្រាស់ច្រើនជាងមួយភាសា។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

២៥. នៅពេលដែលពហុភាសានឹងត្រូវបានប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចនឹងចាំបាច់ត្រូវសម្រេចថាតើភាសានឹងត្រូវប្រើជំនួសគ្នាដោយគ្មានការបកប្រែឯកសារ ឬការបកប្រែផ្ទាល់មាត់ ឬថាតើរាល់ការទំនាក់ទំនង និងឯកសារទាំងអស់ចាំបាច់ត្រូវបកប្រែ ហើយភស្តុតាងផ្ទាល់មាត់ត្រូវបានបកប្រែផ្ទាល់មាត់ទៅគ្រប់ភាសានៃមជ្ឈត្តការដែរឬទេ។ ជាជម្រើសផ្សេង គូភាគី និងវេទិកាមជ្ឈត្តកម្មអាចសម្រេចថាភាសាមួយក្នុងចំណោមភាសាផ្សេងនឹងត្រូវបានជ្រើសរើសជាផ្លូវការសម្រាប់គោលបំណងនៃដំណើរការមជ្ឈត្តការ (ហើយភាសាណាមួយនៃពហុភាសាអាចត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលដំណើរការនីតិវិធី ប៉ុន្តែជាឧទាហរណ៍ សេចក្តីបង្គាប់នីតិវិធី និងមជ្ឈត្តវិនិច្ឆ័យនឹងត្រូវបានចេញជាភាសាផ្លូវការតែមួយគត់)។ ក្នុងករណីណាមួយ ករណីដែលតម្រូវឱ្យមានការបកប្រែ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចនឹងចាំបាច់ពិចារណាថាតើ ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច និងប្រសិទ្ធភាព អាចទទួលយកបានទេក្នុងការកម្រិតការបកប្រែទៅត្រឹមផ្នែកដែលពាក់ព័ន្ធនៃឯកសារ ឬលើកលែងប្រភេទឯកសារមួយចំនួនដូចជា ច្បាប់ ពីការបកប្រែ (សូមមើលខាងលើ កថាខណ្ឌទី ២១)។

### *(ឃ) កម្រៃសេវានៃការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់*

២៦. នៅពេលធ្វើការសម្រេចចិត្តអំពីការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្មគួរសម្រេចថាតើកម្រៃសេវាណាមួយ ឬទាំងអស់ត្រូវបង់ដោយគូភាគីនៅពេលដែលកម្រៃសេវាកើតមានដែរឬទេ។ ដោយមិនខ្វល់ថាតើអ្នកណាបង់កម្រៃសេវានៅពេលកម្រៃសេវាកើតមាន វេទិកាមជ្ឈត្តកម្មអាចត្រូវសម្រេចនាពេលក្រោយថាតើកម្រៃសេវាទាំងនេះ រួមជាមួយនឹងកម្រៃសេវាផ្សេងទៀតនឹងត្រូវបែងចែករវាងគូភាគីដោយរបៀបណា ប្រសិនបើវេទិកាមជ្ឈត្តកម្មពិចារណាថាកម្រៃសេវាទាំងនេះនឹងត្រូវបញ្ចូលទៅក្នុងកម្រៃសេវាមជ្ឈត្តកម្ម (សូមមើលខាងក្រោម កថាខណ្ឌទី ៣៩ និង ៤៧ ដល់ ៤៩)។

## ៣. ទីកន្លែងធ្វើមជ្ឈត្តការ

### *(ក) ការកំណត់ទីកន្លែងធ្វើមជ្ឈត្តការ*

២៧. គូភាគីអាចព្រមព្រៀងលើកន្លែង (ឬ "ទីតាំង") ធ្វើមជ្ឈត្តការបាន។ ប្រសិនបើកន្លែងធ្វើមជ្ឈត្តការមិនត្រូវបានព្រមព្រៀងដោយគូភាគី ជាធម្មតាវេទិកាមជ្ឈត្តកម្ម ឬស្ថាប័នមជ្ឈត្តការដែលចាត់ចែងមជ្ឈត្តការនឹងត្រូវកំណត់ទីកន្លែងធ្វើមជ្ឈត្តការនៅពេលចាប់ផ្តើមនៃដំណើរការមជ្ឈត្តការ។ វិធានស្តីពីមជ្ឈត្តការនៃស្ថាប័នមួយចំនួនមានកំណត់កន្លែងធ្វើមជ្ឈត្តការ ដែលអាចអនុវត្តបានក្នុងករណីដែលគូភាគីមិនបានជ្រើសរើស។

### *(ខ) ផលវិបាកផ្នែកច្បាប់ និងផ្នែកផ្សេងទៀតនៃកន្លែងធ្វើមជ្ឈត្តការ*

២៨. កន្លែងធ្វើមជ្ឈត្តការជាធម្មតាកំណត់ពីច្បាប់ស្តីពីមជ្ឈត្តការជាធរមាន។ ការកំណត់បែបនេះមានឥទ្ធិពលតាមផ្លូវច្បាប់លើបញ្ហាផ្សេងៗដូចជាលក្ខខណ្ឌពាក់ព័ន្ធនឹងការតែងតាំង និងការជំទាស់ទៅនឹងមជ្ឈត្តករ ថាតើ និងផ្អែកលើមូលដ្ឋានអ្វីដែលភាគីម្ខាងអាចស្នើសុំការពិនិត្យមើលឡើងវិញដោយតុលាការ ឬការជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដែលតុលាការមានសមត្ថកិច្ចពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ ក៏ដូចជាលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យនៅក្នុងយុត្តាធិការផ្សេងទៀត។ គូភាគី និងវេទិកាមជ្ឈត្តកម្មគួរយល់ដឹងពីច្បាប់ស្តីពីមជ្ឈត្តការ និងច្បាប់នីតិវិធីពាក់ព័ន្ធផ្សេងទៀតនៅកន្លែងធ្វើមជ្ឈត្តការ ជាពិសេសបទប្បញ្ញត្តិដោយបង្ខំ។

២៩. ការជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការត្រូវបានជះឥទ្ធិពលដោយកត្តាផ្លូវច្បាប់ផ្សេងៗ និងកត្តាផ្សេងទៀត សារៈសំខាន់របស់ទីកន្លែងធ្វើមជ្ឈត្តការខុសគ្នាពីសំណុំរឿងមួយទៅសំណុំរឿងមួយ។ ក្នុងចំណោម

កត្តាផ្នែកច្បាប់ដែលសំខាន់គឺ៖

(ក) ភាពសមស្របនៃច្បាប់ស្តីពីមជ្ឍត្តការនៅទីកន្លែងធ្វើមជ្ឍត្តការ

(ខ) ច្បាប់ យុត្តិសាស្ត្រ និងការអនុវត្តនៅទីកន្លែងធ្វើមជ្ឍត្តការទាក់ទងនឹង៖ (i) ការអន្តរាគមន៍របស់តុលាការក្នុងអំឡុងពេលនៃដំណើរការមជ្ឍត្តការ (ii) វិសាលភាពនៃការត្រួតពិនិត្យរបស់តុលាការ ឬមូលដ្ឋានសម្រាប់ការជំទាស់ទៅនឹងមជ្ឍត្តវិនិច្ឆ័យ និង (iii) លក្ខខណ្ឌគុណវុឌ្ឍិពាក់ព័ន្ធនឹងមជ្ឍត្តករ និងការតំណាងផ្នែកច្បាប់ និង

(គ) ថាតើរដ្ឋដែលមជ្ឍត្តការធ្វើឡើង និងដូច្នេះហើយជាកន្លែងដែលមជ្ឍត្តវិនិច្ឆ័យនឹងត្រូវបានធ្វើឡើង គឺជាភាគីនៃអនុសញ្ញាស្តីពីការទទួលស្គាល់ និងការអនុវត្តមជ្ឍត្តវិនិច្ឆ័យបរទេស (ទីក្រុងញូវយ៉ក ឆ្នាំ១៩៥៨) ("អនុសញ្ញាទីក្រុងញូវយ៉ក") និង/ឬ សន្ធិសញ្ញាពហុភាគី ឬទ្វេភាគីណាមួយផ្សេងទៀត ស្តីពីការអនុវត្តមជ្ឍត្តវិនិច្ឆ័យ។

៣០. នៅពេលដែលគេរំពឹងថាសវនាការនឹងត្រូវបានធ្វើឡើងនៅទីកន្លែងធ្វើមជ្ឍត្តការ កត្តាផ្សេងទៀតអាចមានភាពពាក់ព័ន្ធក្នុងការជ្រើសរើសទីកន្លែងធ្វើមជ្ឍត្តការរួមមាន៖

(ក) ភាពងាយស្រួលនៃទីតាំងសម្រាប់គូភាគី និងមជ្ឍត្តករ រួមទាំងការធ្វើដំណើរទៅកាន់ទីតាំង

(ខ) ភាពទំនេរ និងកម្រៃនៃសេវាកម្មផ្គត់ផ្គង់

(គ) ទីតាំងនៃកម្មវត្ថុនៃវិវាទ និងភាពកៀកជិតនឹងភស្តុតាង និង

(ឃ) ការកម្រិតគុណវុឌ្ឍិណាមួយទាក់ទងនឹងការតំណាងផ្នែកច្បាប់។

*(គ) លទ្ធភាពនៃការបើកសវនាការ និងកិច្ចប្រជុំនៅទីតាំងខុសពីទីកន្លែងធ្វើមជ្ឍត្តការ*

៣១. ទីកន្លែងធ្វើមជ្ឍត្តការគឺមិនចាំបាច់ជាកន្លែងដែលសវនាការ និង/ឬកិច្ចប្រជុំត្រូវបានធ្វើឡើងទេ ទោះបីជាជារឿយៗទីកន្លែងទាំងពីរដូចគ្នាក៏ដោយ។ នៅក្នុងកាលៈទេសៈជាក់លាក់ គូភាគី និងវេទិកាមជ្ឍត្តកម្មអាចរៀបចំសវនាការ និង/ឬកិច្ចប្រជុំនៅទីតាំងផ្សេងពីទីកន្លែងធ្វើមជ្ឍត្តការ ឬពីចម្ងាយតាមរយៈមធ្យោបាយទំនាក់ទំនងបច្ចេកវិទ្យាបានឆាប់រហ័សនិងមានភាពងាយស្រួលជាង។ច្បាប់ស្តីពីមជ្ឍត្តការ និងវិធានស្តីពីមជ្ឍត្តការជាច្រើនបានអនុញ្ញាតឱ្យវេទិកាមជ្ឍត្តកម្មបើកសវនាការ និងកិច្ចប្រជុំនៅកន្លែងផ្សេងពីទីកន្លែងធ្វើមជ្ឍត្តការ។[៦] ទោះជាយ៉ាងណាក៏ដោយ គូភាគី និងវេទិកាមជ្ឍត្តកម្មអាចចាំបាច់ត្រូវពិចារណាថាតើការបើកសវនាការទាំងអស់ខុសពីទីកន្លែងធ្វើមជ្ឍត្តការអាចបង្កើតជាការលំបាកក្នុងដំណាក់កាលនៃការពិនិត្យរបស់តុលាការ ការជំទាស់ ឬការអនុវត្តមជ្ឍត្តវិនិច្ឆ័យដែរ ឬទេ។

## ៤. ជំនួយផ្នែករដ្ឋបាលសម្រាប់វេទិកាមជ្ឍត្តកម្ម

*(ក) ជំនួយផ្នែករដ្ឋបាល និងស្ថាប័នមជ្ឍត្តការ*

៣២. វេទិកាមជ្ឍត្តកម្មអាចត្រូវការជំនួយផ្នែករដ្ឋបាល ដើម្បីអនុវត្តមុខងាររបស់ខ្លួន។ វេទិកាមជ្ឍត្តកម្ម និងគូភាគីគួរតែពិចារណាថាតើអ្នកណានឹងទទួលខុសត្រូវក្នុងការរៀបចំជំនួយទាំងនេះ។

៣៣. នៅពេលដែលសំណុំរឿងមួយត្រូវបានចាត់ចែងដោយស្ថាប័នមជ្ឍត្តការមួយ ស្ថាប័ននោះអាចផ្តល់ជំនួយផ្នែករដ្ឋបាលមួយចំនួនដល់វេទិកាមជ្ឍត្តកម្មបាន។ ការអាចទទួលបាន និងលក្ខណៈនៃជំនួយបែបនេះមានភាពខុសគ្នាយ៉ាងខ្លាំង អាស្រ័យលើស្ថាប័នមជ្ឍត្តការ។ ស្ថាប័នមជ្ឍត្តការមួយចំនួនផ្តល់ជំនួយ

[៦] សូមមើល ជាឧទាហរណ៍ មាត្រា ២០(២) នៃច្បាប់គំរូរបស់ UNCITRAL ស្តីពីមជ្ឍត្តការពាណិជ្ជកម្មអន្តរជាតិ (ជាមួយវិសោធនកម្មដែលបានអនុម័តក្នុងឆ្នាំ ២០០៦) និងមាត្រា ១៨ (២) នៃវិធានស្តីពីមជ្ឍត្តការរបស់ UNCITRAL (ដែលបានកែសម្រួលក្នុងឆ្នាំ ២០១០)។

ផ្នែករដ្ឋបាលដល់ សូម្បីតែដំណើរការមជ្ឈត្តការដែលមិនបានធ្វើឡើងក្រោមវិធានស្ថាប័នរបស់ពួកគេ។ ស្ថាប័នមជ្ឈត្តការមួយចំនួនបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងគោលបំណងផ្ដល់ជំនួយទៅវិញទៅមកក្នុងការគាំទ្រដល់ដំណើរការមជ្ឈត្តការ។

៣៤. លុះត្រាតែការរៀបចំរដ្ឋបាលសម្រាប់ដំណើរការនីតិវិធីត្រូវបានធ្វើឡើងដោយស្ថាប័នមជ្ឈត្តការ ជាធម្មតាការរៀបចំរដ្ឋបាលនឹងត្រូវបានធ្វើឡើងដោយគូភាគី ឬវេទិកាមជ្ឈត្តកម្ម។ គ្រឿងបរិក្ខារសវនាការរួមទាំងសេវាកម្មពាក់ព័ន្ធ អាចទទួលបានពីមជ្ឈមណ្ឌលឯកទេសសវនាការមជ្ឈត្តការ ដែលត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងមួយចំនួន ហើយជួនកាលត្រូវបានភ្ជាប់ជាមួយស្ថាប័នមជ្ឈត្តការ។ បើមិនដូច្នោះទេ គ្រឿងបរិក្ខារសវនាការ និងសេវាពាក់ព័ន្ធអាចត្រូវទទួលបានពីអង្គភាពផ្សេងទៀត ដូចជាសភាពាណិជ្ជកម្ម សណ្ឋាគារ ឬក្រុមហ៊ុនឯកទេសដែលផ្ដល់សេវាកម្មផ្គត់ផ្គង់បែបនេះ។ ក៏អាចធ្វើបានផងដែរក្នុងការទុកការរៀបចំមួយចំនួនទៅឱ្យភាគីម្ខាង ដែលជាកម្មវត្ថុនៃការព្រមព្រៀងរបស់ភាគីម្ខាងទៀត ឬគូភាគី។

## (ខ) *លេខារបស់វេទិកាមជ្ឈត្តកម្ម*

៣៥. ជំនួយផ្នែករដ្ឋបាលអាចទទួលបានដោយការចូលរួមរបស់លេខាក្នុងការអនុវត្តកិច្ចការក្រោមការណែនាំរបស់វេទិកាមជ្ឈត្តកម្ម។ សេវាកម្មបែបនេះក៏អាចត្រូវបានផ្ដល់ឱ្យដោយអ្នកចុះបញ្ជីស្មៀន ឬអ្នករដ្ឋបាលផងដែរ។ ស្ថាប័នមជ្ឈត្តការមួយចំនួនតែងតែចាត់តាំងលេខាឆ្លាស់គ្នាចំពោះសំណុំរឿងដែលចាត់ចែងដោយពួកគេ។ មិនមែនតែករណីនេះទេ មជ្ឈត្តករខ្លះជានិច្ចកាលបញ្ចូលលេខាក្នុងសំណុំរឿងជាពិសេសក្នុងសំណុំរឿងធំ ឬស្មុគស្មាញ ចំណែកឯមជ្ឈត្តករខ្លះវិញមិនត្រូវការលេខានោះទេ។

៣៦. មុខងារ និងកិច្ចការដែលត្រូវបានធ្វើដោយលេខាគឺមានលក្ខណៈទូលំទូលាយ។ លេខាអាចផ្ដល់ជំនួយលើការរៀបចំសុទ្ធសាធ ដូចជាការកក់បន្ទប់សវនាការ និងបន្ទប់ប្រជុំ និងផ្ដល់ ឬសម្របសម្រួលសេវាកម្មរដ្ឋបាល។ វេទិកាមជ្ឈត្តកម្មមួយចំនួនចង់ឱ្យលេខាអនុវត្តមុខងារសំខាន់ៗបន្ថែមទៀតរួមមានការស្រាវជ្រាវផ្នែកច្បាប់ និងជំនួយផ្នែកវិជ្ជាជីវៈផ្សេងទៀត ដូចជាការរៀបចំសេចក្ដីសង្ខេបនៃអង្គហេតុ ឬប្រវត្តិនៃនីតិវិធីនៃដំណើរការមជ្ឈត្តការ ប្រមូល ឬសង្ខេបយុត្តិសាស្ត្រ ឬបោះផ្សាយសេចក្ដីកំណត់លើបញ្ហាច្បាប់ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម និងរៀបចំសេចក្ដីព្រាងសេចក្ដីសម្រេចនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយ លេខាត្រូវបានគេទទួលស្គាល់ថាមិនជាប់ពាក់ព័ន្ធ និងមិនចូលរួមក្នុងការធ្វើសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មទេ លើកលែងតែក្នុងស្ថានភាពកម្រដូចជា ប្រភេទជាក់លាក់នៃមជ្ឈត្តការ (ឧទាហរណ៍ ករណីដែលវិធានស្ដីពីមជ្ឈត្តការជាក់លាក់ចែងថាលេខាត្រូវបានគេរំពឹងថានឹងផ្ដល់នូវការប្រឹក្សាយោបល់ផ្នែកច្បាប់ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មប្រសិនបើនិងនៅពេលដែលវេទិកាមជ្ឈត្តកម្មមានតែសមាសភាពក្រៅពីអ្នកច្បាប់ ដែលអ្នកជំនាញលើកម្មវត្ថុនៃវិវាទ)។

៣៧. លេខាត្រូវបានរំពឹងថាជាបុគ្គលមិនលម្អៀង និងឯករាជ្យ និងនៅតែមិនលម្អៀង និងឯករាជ្យក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ។ នេះគឺជាទំនួលខុសត្រូវរបស់វេទិកាមជ្ឈត្តកម្មក្នុងការធានារឿងនេះ។ វេទិកាមជ្ឈត្តកម្មខ្លះធានាបែបនេះដោយស្នើសុំលេខាចុះហត្ថលេខាលើសេចក្ដីប្រកាសពីឯករាជភាព និងភាពមិនលម្អៀង។

៣៨. ប្រសិនបើវេទិកាមជ្ឈត្តកម្មចង់តែងតាំងលេខាម្នាក់ វេទិកាមជ្ឈត្តកម្មនឹងត្រូវបង្ហាញអង្គហេតុនេះទៅដល់គូភាគី រួមជាមួយនឹងអត្តសញ្ញាណនៃលេខាដែលបានស្នើសុំ លក្ខណៈនៃកិច្ចការដែលត្រូវធ្វើដោយលេខា និងចំនួន និងប្រភពនៃប្រាក់ឈ្នួលណាមួយដែលបានស្នើ។ គូភាគីអាចយល់ព្រមលើតួនាទី និងការអនុវត្តដែលត្រូវគោរពតាមដោយលេខា ក៏ដូចជាលើលក្ខខណ្ឌផ្នែកហិរញ្ញវត្ថុដែល

អាចអនុវត្តបានចំពោះសេវាកម្មរបស់ពួកគេ។ គោលការណ៍ណែនាំរបស់ស្ថាប័នស្ដីពីលេខាអាចផ្ដល់ព័ត៌មានដែលមានប្រយោជន៍ដល់គូភាគី។

## ៥. កម្រៃសេវាមជ្ឈត្តការ

*(ក) ប្រភេទនៃកម្រៃសេវា*

៣៩. កម្រៃសេវាមជ្ឈត្តការជាធម្មតារួមមានៈ

(ក) កម្រៃសេវារបស់វេទិកាមជ្ឈត្តកម្ម

(ខ) ការចំណាយដែលកើតឡើងដោយវេទិកាមជ្ឈត្តកម្មមានដូចជាៈ (i) ការធ្វើដំណើរ និងការស្នាក់នៅ (ii) ជំនួយផ្នែករដ្ឋបាលប្រសិនបើមិនត្រូវបានរ៉ាប់រងការចំណាយដោយគូភាគីផ្ទាល់ និង (iii) អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម (រួមទាំងថ្លៃសេវាសោហ៊ុយធ្វើដំណើរ និងការស្នាក់នៅរបស់ពួកគេ) និងជំនួយ ផ្សេងទៀតដែលតម្រូវដោយវេទិកាមជ្ឈត្តកម្ម

(គ) កម្រៃសេវា និងការចំណាយរបស់ស្ថាប័នមជ្ឈត្តការ និង

(ឃ) កម្រៃសេវាដែលបានកើតឡើងដោយគូភាគីដូចជាៈ (i) កម្រៃសេវាផ្នែកច្បាប់ និងការចំណាយប្រាក់។ (ii) ការចំណាយទាក់ទងនឹងសាក្សី (រួមទាំងការធ្វើដំណើរ និងការស្នាក់នៅរបស់ពួកគេ) និងអ្នកជំនាញ (រួមទាំងថ្លៃសេវា សោហ៊ុយធ្វើដំណើរ និងការស្នាក់នៅរបស់ពួកគេ) និង(iii) កម្រៃសេវាលើការបកប្រែ និងការបកប្រែផ្ទាល់មាត់ (សូមមើលខាងលើកថាខណ្ឌទី ២៦)។

៤០. ខណៈពេលដែលកម្រៃសេវាដែលកើតឡើងដោយគូភាគីទាក់ទងនឹងការតំណាងផ្នែកច្បាប់ សាក្សី និងអ្នកជំនាញ អាចទទួលបានមកវិញត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ វិធានស្ដីពីមជ្ឈត្តការភាគច្រើនមិននិយាយពីកម្រៃសេវាច្បាប់ផ្ទៃក្នុង កម្រៃសេវាគ្រប់គ្រងផ្ទៃក្នុង និងកម្រៃសេវាផ្ទៃក្នុងផ្សេងទៀតទេ (ហៅថា "កម្រៃសេវាផ្ទៃក្នុង") ដែលគូភាគីអាចត្រូវរ៉ាប់រងក្នុងការទាមទារ ឬការពារការទាមទារនៅមជ្ឈត្តការ ដោយបន្សល់ទុកបញ្ហានៃលទ្ធភាពទទួលបានមកវិញក្រោមឆន្ទានុសិទ្ធរបស់វេទិកាមជ្ឈត្តកម្ម។ កម្រៃសេវាផ្ទៃក្នុងនេះអាចតំណាងឱ្យផ្នែកយ៉ាងធំនៃកម្រៃសេវាសរុបរបស់ភាគីម្ខាងនៅពេលដែលទីប្រឹក្សាផ្នែកច្បាប់ផ្ទៃក្នុង នាយកគ្រប់គ្រង អ្នកជំនាញ និងបុគ្គលិកផ្សេងទៀតដើរតួយ៉ាងសកម្មមុន និងក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ។ មិនមានគោលការណ៍ហាមឃាត់នូវការទទួលបានវិញនៃការចំណាយផ្ទៃក្នុងដែលកើតឡើងតាមរយៈទំនាក់ទំនងដោយផ្ទាល់ជាមួយមជ្ឈត្តការនោះទេ។ វេទិកាមជ្ឈត្តកម្មមួយចំនួនបានសម្រេចផ្ដល់ជូននូវកម្រៃសេវាបែបនេះដោយសារតែមានភាពចាំបាច់ មិនជាន់គ្នាជាមួយនឹងកម្រៃសេវាទីប្រឹក្សាខាងក្រៅមិនសមហេតុផលត្រូវបានបង្ហាញយ៉ាងលម្អិតគ្រប់គ្រាន់ដើម្បីបែងចែកពីការចំណាយលើបុគ្គលិកធម្មតា និងមានចំនួនសមរម្យ។

៤១. ប្រសិនបើមិនត្រូវបានលើកឡើងគ្រប់គ្រាន់ដោយកិច្ចព្រមព្រៀងរវាងគូភាគី ច្បាប់ស្ដីពីមជ្ឈត្តការ ឬវិធានស្ដីពីមជ្ឈត្តការជាធរមាននោះទេ វាអាចមានសារៈប្រយោជន៍សម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការកំណត់ថាតើកម្រៃសេវាផ្ទៃក្នុងដែលបង់ដោយគូភាគីនឹងអាចត្រូវទទួលបានមកវិញដែរឬទេ ហើយប្រសិនបើដូច្នេះ តើកំណត់ត្រាអ្វីខ្លះដែលនឹងត្រូវដាក់ជូន ដើម្បីបញ្ជាក់ពីការទាមទារកម្រៃសេវានេះ។

៤២. គូភាគី និងមជ្ឈត្តករអាចត្រូវពិចារណាពីរបៀបចាត់ចែងពន្ធលើសេវាកម្ម ជាពិសេសអាករតម្លៃបន្ថែមនៅពេលកំណត់កម្រៃសេវា។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352 | Tel: +855 (0) 86 56 9666 | Email: services@din-co.com | Website: www.din-co.com

Project No. 5992983 | Translation: English to Khmer | Types: Legal document | Verified by: Panha NORN | Version: 01 | Date: 19 February 2023

## *(ខ) ការតម្កល់កម្រៃសេវា*

៤៣. លុះត្រាតែបញ្ហានេះត្រូវបានដោះស្រាយដោយវេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មជាធម្មតាស្នើសុំឱ្យគូភាគីដាក់តម្កល់ប្រាក់ជាមុនសម្រាប់កម្រៃសេវាដែលយោងទៅតាមកថាខណ្ឌរង (ក) (ខ) និង (គ) នៃកថាខណ្ឌទី ៣៩។ ការបង់ប្រាក់តម្កល់ដោយភាគីមួយមិនមានន័យថាភាគីនោះបានបោះបង់សិទ្ធិក្នុងការជំទាស់ណាមួយដែលអាចមានចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្មនោះទេ។ ប្រសិនបើ ក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ ស្រាប់តែកម្រៃសេវានឹងឡើងខ្ពស់ជាងការរំពឹងទុក (ឧទាហរណ៍ ដោយសារតែការអូសបន្លាយនៃដំណើរការមជ្ឈត្តការ សវនាការបន្ថែម ការតែងតាំងអ្នកជំនាញដោយវេទិកាមជ្ឈត្តកម្ម) ប្រាក់តម្កល់បន្ថែមអាចត្រូវបានស្នើសុំ។ ប្រាក់តម្កល់អាចត្រូវបានបង់ពេញលេញ ឬជាការបង់រំលស់ ហើយការធានាពីធនាគារអាចជាមធ្យោបាយមួយដើម្បីធានាប្រាក់តម្កល់នេះ។

៤៤. វិធានស្តីពីមជ្ឈត្តការជាច្រើនមានបទប្បញ្ញត្តិទាក់ទងនឹងបញ្ហាទាំងនេះរួមមាន ថាតើការតម្កល់ប្រាក់គួរតែត្រូវបានធ្វើឡើងក្នុងចំនួនស្មើគ្នាដោយគូភាគីដែរឬទេ និងផលវិបាកនៃការខកខានរបស់ភាគីម្ខាងក្នុងការបង់ប្រាក់។[៧]

៤៥. ករណីដែលមជ្ឈត្តការត្រូវបានចាត់ចែងដោយស្ថាប័នមជ្ឈត្តការ សេវាកម្មរបស់ស្ថាប័នអាចរួមបញ្ចូលការកំណត់ចំនួននៃប្រាក់តម្កល់ ក៏ដូចជាការកាន់កាប់ ការគ្រប់គ្រង និងដាក់ប្រាក់តម្កល់ក្នុងគណនី។ ប្រសិនបើស្ថាប័នមជ្ឈត្តការមិនផ្តល់សេវាកម្មទាំងនេះ គូភាគី ឬវេទិកាមជ្ឈត្តកម្មនឹងត្រូវរៀបចំចាំបាច់ ឧទាហរណ៍ជាមួយធនាគារ ឬអ្នកផ្តល់សេវាខាងក្រៅផ្សេងទៀត។ ក្នុងករណីណាមួយវាមានប្រយោជន៍ក្នុងការបញ្ជាក់ពីចំនុចផ្សេងៗ ដូចជាប្រភេទ និងទីតាំងនៃគណនីដែលប្រាក់តម្កល់នឹងត្រូវបានរក្សាទុក របៀបនៃការគ្រប់គ្រងប្រាក់តម្កល់ និងថាតើការប្រាក់លើប្រាក់តម្កល់នឹងបង្គរដែរឬទេ។

៤៦. គូភាគី វេទិកាមជ្ឈត្តកម្ម និងស្ថាប័នមជ្ឈត្តការគួរតែយល់ដឹងពីការដាក់កម្រិតបទប្បញ្ញត្តិដែលអាចមានផលប៉ះពាល់ដល់ការចាត់ចែងប្រាក់តម្កល់នៃកម្រៃសេវា ដូចជាការដាក់កម្រិតនៅក្នុងបទប្បញ្ញត្តិគណៈមេធាវី បទប្បញ្ញត្តិហិរញ្ញវត្ថុទាក់ទងនឹងអត្តសញ្ញាណអ្នកទទួលផលប្រយោជន៍ និងការដាក់កម្រិតលើការជួញដូរ ឬការបង់ប្រាក់។

## *(គ) ការកំណត់ និងការបែងចែកកម្រៃសេវា*

៤៧. នៅវាល់ដំណាក់កាលនៃដំណើរការនីតិវិធី ជាធម្មតាវេទិកាមជ្ឈត្តកម្មធ្វើការពិចារណាទៅលើតម្រូវការក្នុងការគ្រប់គ្រងកម្រៃសេវា និងរក្សាប្រសិទ្ធភាពជាមួយនឹងការចំណាយអស់តិចនៃដំណើរការទាំងមូល។ ជាទូទៅ វេទិកាមជ្ឈត្តកម្មកំណត់ថាកម្រៃសេវាណា ដែលបានកកើតលើគូភាគីយោងតាមកថាខណ្ឌរង (ឃ) នៃកថាខណ្ឌទី ៣៩ និងការចំណាយផ្ទៃក្នុងដែលយោងតាមកថាខណ្ឌទី ៤០ និង ៤១ នឹងត្រូវទទួលបានមកវិញ។ ក្នុងការកំណត់កម្រៃសេវាដែលអាចទទួលបានមកវិញទាំងនេះ វេទិកាមជ្ឈត្តកម្មជាធម្មតាពិចារណាពីភាពសមហេតុផលនៃកម្រៃសេវា ហើយសម្រេចថាតើត្រូវតម្រូវភស្តុតាងដែលថាកម្រៃសេវាពិតជាបានកើតឡើងមែនឬទេ។ នៅក្នុងមជ្ឈត្តការដែលចាត់ចែងដោយស្ថាប័នមជ្ឈត្តការ កម្រៃសេវាមួយចំនួនផ្សេងទៀត យោងតាមកថាខណ្ឌទី ៣៩ អាចត្រូវបានកំណត់ដោយស្ថាប័នមជ្ឈត្តការ។

៤៨. បន្ទាប់ពីកំណត់កម្រៃសេវារបស់មជ្ឈត្តការ វេទិកាមជ្ឈត្តកម្មកំណត់ពីរបៀបក្នុងការបែងចែកកម្រៃសេវារវាងគូភាគី។ ក្នុងការធ្វើដូច្នេះ វេទិកាមជ្ឈត្តកម្មជាធម្មតាធ្វើការពិចារណាពីវិធីសាស្ត្របែងចែក

[៧] សូមមើល ឧទាហរណ៍ មាត្រា ៤៣ នៃវិធានស្តីពីមជ្ឈត្តការ UNCITRAL (ដែលបានកែសម្រួលក្នុងឆ្នាំ២០១០)។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

ដែលគូភាគីបានព្រមព្រៀងគ្នា ឬមានចែងនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការ ឬវិធានស្តីពីមជ្ឈត្តការជាធរមាន។ មានវិធីសាស្ត្រជាច្រើនផ្សេងៗគ្នាសម្រាប់ធ្វើការបែងចែកកម្រៃសេវា វិធានទូទៅគឺការចំណាយទៅតាមព្រឹត្តិការណ៍ ពោលគឺកម្រៃសេវាលើមជ្ឈត្តការគួរតែជាបន្ទុករបស់ភាគីចាញ់ក្តីឬគូភាគីទាំងអស់ ឬដោយផ្នែក។ ក្នុងការបែងចែកកម្រៃសេវា វេទិកាមជ្ឈត្តកម្មក៏អាចពិចារណាលើទង្វើជាក់លាក់របស់គូភាគីផងដែរ។ នេះអាចរួមមានទង្វើរបស់ភាគីដូចជា៖ (ក) ការខកខានក្នុងការអនុលោមតាមសេចក្តីបង្គាប់នីតិវិធីរបស់វេទិកាមជ្ឈត្តកម្ម ឬ (ខ) សំណើនីតិវិធី (ឧទាហរណ៍ សំណើសុំឯកសារ ពាក្យស្នើសុំពាក់ព័ន្ធនឹងនីតិវិធី និងសំណើសួរចម្លើយតទល់ទៅវិញទៅមក) ដែលមិនសមហេតុផល ក្នុងវិសាលភាពដែលទង្វើបែបនេះពិតជាមានផលប៉ះពាល់ដោយផ្ទាល់ទៅលើកម្រៃសេវាមជ្ឈត្តការ និង/ឬត្រូវបានកំណត់ដោយវេទិកាមជ្ឈត្តកម្មថាធ្វើឱ្យមានការពន្យារពេល ឬរាំងដំណើរការមជ្ឈត្តការដោយមិនចាំបាច់។

៤៩. នៅពេលវេលាសមស្របមួយក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចស្នើសុំគូភាគីដាក់សេចក្តីថ្លែងលើកម្រៃសេវា។ សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មលើកម្រៃសេវា និងការបែងចែកកម្រៃសេវារបស់ពួកគេ មិនចាំបាច់ត្រូវធ្វើឡើងជាមួយនឹងមជឈ្មត្តវិនិច្ឆ័យចុងក្រោយនោះទេ។ សេចក្តីសម្រេចលើកម្រៃសេវាអាចត្រូវបានធ្វើឡើងនៅពេលណាក៏បានក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ (ឧទាហរណ៍ នៅពេលមជ្ឈត្តវិនិច្ឆ័យដោយផ្នែក ឬសេចក្តីសម្រេចនីតិវិធីត្រូវបានចេញ) ក៏ដូចជាបន្ទាប់ពីមជ្ឈត្តវិនិច្ឆ័យលើអង្គសេចក្តីត្រូវបានចេញផងដែរ។

## ៦. កិច្ចព្រមព្រៀងដែលអាចមានលើការរក្សាការសម្ងាត់ តម្លាភាពក្នុងមជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋដោយផ្អែកលើសន្ធិសញ្ញា

### *(ក) កិច្ចព្រមព្រៀងលើការរក្សាការសម្ងាត់*

៥០. ទស្សនៈដែលគេប្រកាន់យកយ៉ាងទូលំទូលាយគឺថាមានលក្ខខណ្ឌស្នូលនៃការរក្សាការសម្ងាត់នៅក្នុងមជ្ឈត្តការពាណិជ្ជកម្ម ហើយការសម្ងាត់នោះគឺជាគុណសម្បត្តិ និងជាមុខងាររដែលមានសារៈប្រយោជន៍មួយរបស់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ មិនមានការប្រើវិធីសាស្ត្ររួមនៅក្នុងច្បាប់ក្នុងប្រទេស ឬវិធានស្តីពីមជ្ឈត្តការទាក់ទងនឹងវិសាលភាពដែលអ្នកចូលរួមនៅក្នុងមជ្ឈត្តការមានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់នៃព័ត៌មានដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការនោះទេ។

៥១. ប្រសិនបើការរក្សាការសម្ងាត់ជាការព្រួយបារម្ភ ឬជាអាទិភាព ហើយប្រសិនបើគូភាគីមិនពេញចិត្តដោយការចាត់ចែងទៅលើបញ្ហានោះនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការ ឬវិធានស្តីពីមជ្ឈត្តការជាធរមាន គូភាគីអាចយល់ព្រមលើរបបរក្សាការសម្ងាត់ដែលខ្លួនចង់បានក្នុងវិសាលភាពដែលមិនត្រូវបានហាមឃាត់ដោយវិធានស្តីពីមជ្ឈត្តការជាធរមាន។

៥២. កិច្ចព្រមព្រៀងស្តីពីការរក្សាការសម្ងាត់អាចគ្របដណ្តប់លើបញ្ហាមួយ ឬច្រើនដូចខាងក្រោម៖ (ក) ខ្លឹមសារ ឬព័ត៌មានដែលត្រូវរក្សាជាការសម្ងាត់ (ឧទាហរណ៍ អង្គហេតុដែលមជ្ឈត្តការកំពុងប្រព្រឹត្តទៅ អត្តសញ្ញាណរបស់គូភាគី និងមជ្ឈត្តករ ភស្តុតាង សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ខ្លឹមសារនៃមជ្ឈត្តវិនិច្ឆ័យ) (ខ) វិធានការសម្រាប់រក្សាការសម្ងាត់នៃព័ត៌មានទាំងនេះនិងនៃសវនាការ និងអំឡុងពេលនៃកាតព្វកិច្ចលើការរក្សាការសម្ងាត់ (គ) កាលៈទេសៈដែលព័ត៌មានសម្ងាត់អាចត្រូវបានបញ្ចេញទាំងស្រុង ឬដោយផ្នែកក្នុងវិសាលភាពចាំបាច់ដើម្បីការពារសិទ្ធិស្របច្បាប់ និង (ឃ) កាលៈទេសៈផ្សេងទៀតដែលការបញ្ចេញបែបនេះអាចត្រូវបានអនុញ្ញាត (ឧទាហរណ៍ ព័ត៌មានដែលមានជាសាធារណៈ ឬការបញ្ចេញដែលតម្រូវដោយច្បាប់ ឬស្ថាប័ននីតិកម្ម។ គូភាគីអាចមានបំណង

ពិចារណាពីរបៀបពង្រីកវិសាលភាពកាតព្វកិច្ចនៃការរក្សាសម្ងាត់លើសាក្សី និងអ្នកជំនាញ ព្រមទាំងបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធជាមួយភាគីក្នុងដំណើរការមជ្ឈត្តការ។

៥៣. ខណៈពេលដែលកាតព្វកិច្ចនៃការរក្សាការសម្ងាត់ត្រូវបានដាក់លើគូភាគី និងអ្នកតំណាងផ្នែកច្បាប់របស់ពួកគេអាចប្រែប្រួលទៅតាមកាលៈទេសៈនៃសំណុំរឿងក៏ដូចជាច្បាប់ស្តីពីមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការជាធរមាន មជ្ឈត្តករត្រូវបានរំពឹងថានឹងទុកដំណើរការមជ្ឈត្តការជាការសម្ងាត់ រួមទាំងព័ត៌មានដែលទាក់ទងនឹង ឬទទួលបានក្នុងអំឡុងពេលដំណើរការនីតិវិធីទាំងនោះ។

៥៤. ក៏មានកាលៈទេសៈដែលព័ត៌មាន ឬខ្លឹមសារមួយចំនួនត្រូវបានចាត់ទុកថាជាការសម្ងាត់ចំពោះភាគីមួយនៅក្នុងមជ្ឈត្តការផងដែរ (ឧទាហរណ៍ ការសម្ងាត់នៃពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា ឬព័ត៌មានទាក់ទងនឹងសន្តិសុខជាតិនៅក្នុងមជ្ឈត្តការដែលពាក់ព័ន្ធនឹងរដ្ឋ ឬអង្គភាពរដ្ឋាភិបាល)។ ការរៀបចំដើម្បីការពារព័ត៌មាន ឬខ្លឹមសារនេះអាចត្រូវបានធ្វើឡើងដោយគូភាគី ហើយក្នុងកាលៈទេសៈមួយចំនួនដោយវេទិកាមជ្ឈត្តកម្ម ឧទាហរណ៍ ដោយមានការកម្រិតការទទួលបានព័ត៌មាន ឬខ្លឹមសារទាំងនោះត្រឹមចំនួនបុគ្គលដែលបានជ្រើសតាំងពាក់ព័ន្ធនឹងមជ្ឈត្តការ។

*(ខ) តម្លាភាពក្នុងមជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋ ដោយផ្អែកលើសន្ធិសញ្ញា*

៥៥. លក្ខណៈជាក់លាក់នៃមជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋដែលកើតឡើងក្រោមសន្ធិសញ្ញាវិនិយោគបានធ្វើឱ្យមានការអភិវឌ្ឍន៍របបតម្លាភាពសម្រាប់មជ្ឈត្តការបែបនេះ។ សន្ធិសញ្ញាវិនិយោគដែលគ្របដណ្តប់មជ្ឈត្តការរវាងវិនិយោគិន និងរដ្ឋ អាចរួមបញ្ចូលបទប្បញ្ញត្តិជាក់លាក់ស្តីពីការបោះពុម្ពផ្សាយឯកសារសវនាការសាធារណៈ និងព័ត៌មានសម្ងាត់ ឬត្រូវការពារ។ បន្ថែមពីនេះ វិធានស្តីពីមជ្ឈត្តការជាធរមានដែលបានយោងក្នុងសន្ធិសញ្ញាវិនិយោគទាំងនោះអាចមានប្បញ្ញត្តិជាក់លាក់ស្តីពីតម្លាភាព។[៨] លើសពីនេះ គូភាគី មជ្ឈត្តការផ្អែកលើសន្ធិសញ្ញាអាចយល់ព្រមអនុវត្តប្បញ្ញត្តិតម្លាភាពជាក់លាក់។[៩]

## ៧. មធ្យោបាយទំនាក់ទំនង

### *(ក) ការកំណត់មធ្យោបាយទំនាក់ទំនង*

៥៦. វាមានសារៈប្រយោជន៍សម្រាប់គូភាគី និងវេទិកាមជ្ឈត្តកម្មក្នុងការកំណត់ពីដំបូងនូវមធ្យោបាយទំនាក់ទំនងដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ។កត្តាដែលអាចត្រូវបានពិចារណាក្នុងការជ្រើសរើសមធ្យោបាយទំនាក់ទំនង រួមមានការធានាថា៖

(ក) ឯកសារអាចទទួលបាន និងងាយស្រួលក្នុងការទទួលដោយគូភាគី និងវេទិកាមជ្ឈត្តកម្ម រួមទាំងតាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យសម្រាប់ការផ្ទុក និងការចែករំលែកឯកសារ។

(ខ) ការទទួលបានការទំនាក់ទំនងអាចត្រូវបានធានា

(គ) មធ្យោបាយទំនាក់ទំនងអាចទទួលយកបានក្រោមច្បាប់ស្តីពីមជ្ឈត្តការជាធរមាន និង

(ឃ) កម្រៃសេវាពាក់ព័ន្ធនឹងការប្រើប្រាស់នៃមធ្យោបាយទំនាក់ទំនងដែលបានជ្រើសរើសគឺសមហេតុផល។

---

[៨] សូមមើល ឧទាហរណ៍ វិធានរបស់ UNCITRAL ស្តីពីតម្លាភាពក្នុងមជ្ឈត្តការវិនិយោគរវាងវិនិយោគិន និងរដ្ឋ ដោយផ្អែកលើសន្ធិសញ្ញា ("វិធានស្តីពីតម្លាភាព") វិធានស្តីពីតម្លាភាពក៏អាចមានផលប៉ះពាល់លើទិដ្ឋភាពផ្សេងៗនៃដំណើរការមជ្ឈត្តការផងដែរ ឧទាហរណ៍ ទាក់ទងនឹងការដាក់សេចក្តីថ្លែងដោយតតិយជន និងការប្រព្រឹត្តទៅនៃសវនាការ។

[៩] ឧទាហរណ៍ ក្រោមមាត្រា ១(២)(ក) នៃវិធានស្តីពីតម្លាភាព។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

៥៧. ទោះបីជាមធ្យោបាយទំនាក់ទំនងច្រើនជាងមួយអាចត្រូវបានប្រើប្រាស់ (ឧទាហរណ៍ តាមលិខិតក៏ដូចជាមធ្យោបាយអេឡិចត្រូនិក) គូភាគីអាច ពិចារណាបញ្ហាដែលកើតឡើងពីការប្រើប្រាស់មធ្យោបាយទំនាក់ទំនងច្រើនរួមមាន មធ្យោបាយណាដែលអាចទុកចិត្តបាន និងករណីដែលមានពេលវេលាកំណត់សម្រាប់ការដាក់សេចក្តីថ្លែង សកម្មភាពអ្វីដែលនឹងបង្កើតបានជាការដាក់សេចក្តីថ្លែង។

*(ខ) មធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក*

៥៨. ការប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកអាចធ្វើឱ្យដំណើរការមជ្ឈត្តការកាន់តែឆាប់រហ័ស និងមានប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ គួរតែពិចារណាថាតើគូភាគីទាំងអស់អាចប្រើប្រាស់ ឬស៊ាំជាមួយមធ្យោបាយបែបនេះដែរឬទេ។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចចាំបាច់ត្រូវពិចារណាពីបញ្ហានៃសមិតភាព ទំហំផ្ទុក ការទទួលបាន សុវត្ថិភាពទិន្នន័យ ក៏ដូចជាការចំណាយពាក់ព័ន្ធនៅពេលជ្រើសរើសមធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក។

*(គ) លំហូរនៃការទំនាក់ទំនង*

៥៩. ការទំនាក់ទំនងជាធម្មតាត្រូវបានផ្លាស់ប្តូរដោយផ្ទាល់រវាងវេទិកាមជ្ឈត្តកម្ម និងគូភាគី លុះត្រាតែស្ថាប័នមជ្ឈត្តការដើរតួជាអន្តរការី។ វាជារឿងធម្មតាដែលគូភាគីទាំងអស់ត្រូវបានចម្លងជូននូវរាល់ការទំនាក់ទំនងទាំងអស់ទាំងទៅ និងមកពីវេទិកាមជ្ឈត្តកម្ម។

## ៨. វិធានការបណ្តោះអាសន្ន

*(ក) ការផ្តល់វិធានការបណ្តោះអាសន្ន*

៦០ ក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ អាចមានលទ្ធភាពដែលភាគីមួយ អាចនឹងចាំបាច់ស្នើសុំវិធាន ការបណ្តោះអាសន្ន ដែលមានលក្ខណៈបណ្តោះអាសន្ន ពីវេទិកាមជ្ឈត្តកម្ម ឬតុលាការជាតិ។ ច្បាប់ស្តីពីមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការភាគច្រើនចែងថា វេទិកាមជ្ឈត្តកម្មអាចផ្តល់វិធានការបណ្តោះអាសន្នតាមសំណើរបស់ភាគីបាន។[10] ច្បាប់ស្តីពីមជ្ឈត្តការក៏អាចចែងផងដែរថា តុលាការអាចផ្តល់វិធានការបណ្តោះអាសន្នពាក់ព័ន្ធនឹងមជ្ឈត្តការបានផងដែរ។ គោលការណ៍ដែលត្រូវបានបង្កើតឡើង គឺថាសំណើណាមួយដែលធ្វើឡើងដោយភាគីទៅតុលាការជាតិស្នើសុំវិធានការបណ្តោះអាសន្នមួយមុន ឬអំឡុងពេលដំណើរការមជ្ឈត្តការ គឺមិនត្រូវមានវិសមិតភាពជាមួយនឹងកិច្ចព្រមព្រៀងក្នុងការធ្វើមជ្ឈត្តការនោះទេ។

៦១. បញ្ហាដែលត្រូវពិចារណាដោយគូភាគី និងវេទិកាមជ្ឈត្តកម្មទាក់ទងនឹងការស្នើសុំវិធានការបណ្តោះអាសន្នរួមមាន៖

(ក) ច្បាប់ជាធរមានពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្ន រួមទាំងថាតើការផ្តល់វិធានការបណ្តោះអាសន្ននៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មដែរឬទេ

(ខ) ប្រភេទនៃវិធានការដែលវេទិកាមជ្ឈត្តកម្មអាចផ្តល់

(គ) លក្ខខណ្ឌសម្រាប់ការស្នើសុំ និងការផ្តល់វិធានការបណ្តោះអាសន្ន

(ឃ) យន្តការដែលមានសម្រាប់ការអនុវត្តវិធានការបណ្តោះអាសន្ន

[10] សូមមើល ឧទាហរណ៍ ជំពូកទី IV A នៃច្បាប់គំរូ UNCITRAL ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ (ជាមួយវិសោធនកម្មដែលបានអនុម័តក្នុងឆ្នាំ ២០០៦) និងមាត្រា ២៦ នៃវិធាន UNCITRAL ស្តីពីមជ្ឈត្តការ (ដែលបានកែសម្រួលក្នុងឆ្នាំ ២០១០)។

(ង) ការកម្រិតក្នុងការផ្តល់វិធានការបណ្តោះអាសន្ននៅពេលដែលតតិយជនអាចត្រូវបានរងផលប៉ះពាល់ដោយវិធានការ និង

(ច) ភាពផ្ទុយគ្នាដែលអាចកើតមានរវាងសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មលើវិធានការបណ្តោះអាសន្ន និងដីកាពីតុលាការលើវិធានការបណ្តោះអាសន្ន។

៦២. អាស្រ័យលើច្បាប់ស្តីពីមជ្ឈត្តការ ឬវិធានស្តីពីមជ្ឈត្តការជាធរមាន ភាគីមួយអាច ដោយមិនចាំបាច់មានភាគីម្ខាងទៀត (ពោលគឺដោយគ្មានការជូនដំណឹងទៅភាគីណាមួយផ្សេងទៀត) ស្នើសុំវិធានការបណ្តោះអាសន្ន និងក្នុងពេលជាមួយគ្នានេះស្នើសុំ ដែលជារឿយៗត្រូវបានគេហៅថា "សេចក្តីបង្គាប់បឋម" ពោលគឺជាធម្មតាសេចក្តីបង្គាប់បង្គាប់គូភាគីមិនឱ្យរារាំងគោលបំណងនៃវិធានការបណ្តោះអាសន្នដែលបានស្នើសុំ ខណៈពេលដែលវេទិកាមជ្ឈត្តកម្មសម្រេចថាតើត្រូវផ្តល់ ឬអត់។ ភាគីជាធម្មតានឹងធ្វើសំណើដោយមិនបញ្ជូនទៅភាគីម្ខាងទៀតក្នុងកាលៈទេសៈដែលការបង្ហាញសំណើសុំវិធានការបណ្តោះអាសន្ន (មុនពេលដែលវេទិកាមជ្ឈត្តកម្មចេញសេចក្តីបង្គាប់បឋមដែលធានារក្សានូវស្ថានភាពបច្ចុប្បន្ន) អាចធ្វើឱ្យភាគីប្រឆាំងនឹងអ្នកស្នើសុំវិធានការដែលនឹងត្រូវបានបង្គាប់ឱ្យធ្វើសកម្មភាព អាចរារាំងគោលបំណងនៃវិធានការនេះ (ឧទាហរណ៍ ការលាក់ទ្រព្យសម្បត្តិ ឬការយកទំនិញដែលមានវិវាទទៅកាន់យុត្តាធិការផ្សេងទៀត)។[១១]

*(ខ) កម្រៃសេវា និងការខូចខាតដែលកើតឡើងពីវិធានការបណ្តោះអាសន្ន ប្រាតិភោគសម្រាប់កម្រៃសេវា និងការខូចខាត*

៦៣. ភាគីដែលស្នើសុំវិធានការបណ្តោះអាសន្នអាចត្រូវទទួលខុសត្រូវក្រោមច្បាប់ជាធរមានចំពោះកម្រៃសេវា និងការខូចខាតដែលបណ្តាលមកពីវិធានការបណ្តោះអាសន្នប្រសិនបើវេទិកាមជ្ឈត្តកម្មកំណត់នៅពេលក្រោយថាវិធានការនេះមិនគួរត្រូវបានផ្តល់ឱ្យទេ ក្នុងស្ថានភាពនៅពេលវិធានការត្រូវបានចេញ។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចកំណត់នីតិវិធីសម្រាប់បង្ហាញការទាមទារលើកម្រៃសេវា និងការខូចខាតដែលកើតឡើងពីវិធានការបណ្តោះអាសន្ន ដោយចង្អុលបង្ហាញ ឧទាហរណ៍ នៅចំណុចណាមួយក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ ភាគីអាចធ្វើការទាមទារបែបនេះ ហើយវេទិកាមជ្ឈត្តកម្មអាចចេញសេចក្តីសម្រេចលើកម្រៃសេវា និងការខូចខាតបែបនេះ។

៦៤. ភាគីដែលស្នើសុំវិធានការបណ្តោះអាសន្នអាចត្រូវបានតម្រូវដោយវេទិកាមជ្ឈត្តកម្មក្នុងការផ្តល់ប្រាតិភោគសម្រាប់កម្រៃសេវា និងការខូចខាតដែលអាចកើតឡើង។

## ៩. សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្តីថ្លែងរបស់សាក្សី របាយការណ៍របស់អ្នកជំនាញ និងភស្តុតាងជាឯកសារ

៦៥. ក្នុងអំឡុងពេលដំណើរការមជ្ឈត្តការ គូភាគីជាធម្មតាដាក់ឯកសារជាច្រើនដូចជា សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្តីថ្លែងរបស់សាក្សី របាយការណ៍របស់អ្នកជំនាញ និងភស្តុតាងជាឯកសារ។ សេចក្តីថ្លែងជាលាយលក្ខណ៍អក្សររួមមាន សេចក្តីថ្លែងទាមទារ សេចក្តីថ្លែងដោះសារ ការដាក់សេចក្តីថ្លែងតវ៉ាជុំទីពីរ និងការដាក់សេចក្តីថ្លែងផ្សេងទៀតដែលគូភាគី និងវេទិកាមជ្ឈត្តកម្មអាចចាត់ទុកថាចាំបាច់។

៦៦. ការដាក់សេចក្តីថ្លែងអាចត្រូវបានធ្វើឡើងបន្តបន្ទាប់ៗគ្នា ពោលគឺនៅពេលដែលភាគីម្ខាង (ជាធម្មតាភាគីដែលធ្វើការស្នើសុំ ឬស្វែងរកការសង្គ្រោះ) ធ្វើការដាក់សេចក្តីថ្លែងរបស់ខ្លួន បន្ទាប់មកភាគីម្ខាងទៀត

[១១] សូមមើល ឧទាហរណ៍ ផ្នែកទី ២ នៃជំពូកទី IV A នៃច្បាប់គំរូរបស់ UNCITRAL ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ (ជាមួយនឹងវិសោធនកម្មដែលបានអនុម័តក្នុងឆ្នាំ ២០០៦)។

ឬគូភាគីផ្សេងទៀតធ្វើការដាក់សេចក្តីថ្លែងតប។ ម៉្យាងវិញទៀត គូភាគីទាំងអស់អាចត្រូវបានតម្រូវឱ្យធ្វើការដាក់សេចក្តីថ្លែងរបស់ពួកគេក្នុងពេលដំណាលគ្នា។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់អាចអាស្រ័យលើប្រភេទនៃវិវាទដែលត្រូវដោះស្រាយនៅក្នុងការដាក់សេចក្តីថ្លែង ដំណាក់កាលនៃដំណើរការមជ្ឈត្តការ និងពេលវេលាដែលបានផ្តល់ឱ្យគូភាគីក្នុងការរៀបចំការដាក់សេចក្តីថ្លែងរបស់ពួកគេ។ វិធានស្តីពីមជ្ឈត្តការភាគច្រើនលើកឡើងពីចំណុចនេះ ជួនកាលរៀបរាប់លម្អិតអំពីលំដាប់នៃការដាក់សេចក្តីថ្លែង និងខ្លឹមសារដែលតម្រូវ។

## ១០. ការអនុវត្តជាក់ស្តែងលម្អិតពាក់ព័ន្ធនឹងទម្រង់ និងវិធីសាស្ត្រនៃការដាក់សេចក្តីថ្លែង

៦៧. ទាក់ទងនឹងទម្រង់ និងវិធីសាស្ត្រនៃការដាក់សេចក្តីថ្លែង ការអនុវត្តជាក់ស្តែងលម្អិត រួមទាំងអ្វីដែលបានរៀបរាប់នៅក្នុងកំណត់ចំណាំទី ៧ ចាំបាច់ត្រូវធ្វើការពិចារណា។ វិធានស្តីពីមជ្ឈត្តការមួយចំនួនមានបទប្បញ្ញត្តិពាក់ព័ន្ធលើចំណុចនេះ។ អាស្រ័យលើបរិមាណ និងប្រភេទនៃការដាក់សេចក្តីថ្លែងដែលត្រូវដោះស្រាយ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើវានឹងមានសារៈប្រយោជន៍ក្នុងការយល់ព្រមលើការអនុវត្តជាក់ស្តែងលម្អិតទាក់ទងនឹងឧទាហរណ៍ចំនុចខាងក្រោមដែរ ឬទេ៖

(ក) ទម្រង់ដែលការដាក់សេចក្តីថ្លែងនឹងត្រូវបានធ្វើឡើង (ឧទាហរណ៍ ជាឯកសារសំណៅចម្លង ទម្រង់អេឡិចត្រូនិក ឬតាមរយៈប្រព័ន្ធចែករំលែករួម) រួមទាំងទម្រង់ឯកសាររបស់ពួកគេ (ឧទាហរណ៍ ទម្រង់ឯកសារអេឡិចត្រូនិកជាក់លាក់ ដូចជាទម្រង់ពីនាយ ឬទម្រង់ដើមដែលអាចប្រើបាន មានមុខងារស្វែងរក)

(ខ) លក្ខណៈជាក់លាក់នៃការគ្រប់គ្រងការដាក់ឯកសារប្រព័ន្ធសម្រាប់ការរៀបចំបិទស្លាកការកំណត់អត្តសញ្ញាណ និងការយោងការដាក់សេចក្តីថ្លែង រួមទាំង ថាតើវាអាចត្រូវបានបង្ហាញតាមរបៀបដែលអាចចូលយកបានដោយមានប្រសិទ្ធភាពឬទេ (ឧទាហរណ៍ ដោយប្រើតំណដើម្បីយោងភស្តុតាងជាឯកសារ ឬច្បាប់)

(គ) ការរៀបចំប្រភេទជាក់លាក់នៃការដាក់សេចក្តីថ្លែង (ឧទាហរណ៍ ថាតើសៀវភៅបញ្ជីធំ ឬដ្យាក្រាម ឬប្រភេទឯកសារផ្សេងទៀតគួរតែត្រូវបង្ហាញដាច់ដោយឡែកពីគ្នាឬទេ)

(ឃ) ការរក្សាទុក និងទំហំផ្ទុកនៃការដាក់សេចក្តីថ្លែងនៅក្នុងករណីមួយចំនួន ច្បាប់ជាធរមានអាចតម្រូវឱ្យមាននីតិវិធីជាក់លាក់មួយដើម្បីរក្សាភស្តុតាងជាឯកសារមុនពេលការចាប់ផ្តើមនៃមជ្ឈត្តការ និង

(ង) ការការពារទិន្នន័យជាក់លាក់ (ឧទាហរណ៍ ទាក់ទងនឹងព័ត៌មានអំពីសាក្សី)។

## ១១. ចំណុចនៃវិវាទ និងការសង្គ្រោះ ឬការសង្គ្រោះដែលត្រូវបានទាមទារ

### *(ក) ការរៀបចំបញ្ជីនៃចំណុចវិវាទ*

៦៨. ជារឿយៗ គេចាត់ទុកថាមានប្រយោជន៍សម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការរៀបចំ ដោយពិគ្រោះយោបល់ជាមួយគូភាគី បញ្ជីនៃចំណុចវិវាទ (ផ្ទុយទៅនឹងអ្វីដែលមិនមានវិវាទ) ដោយផ្អែកលើការដាក់សេចក្តីថ្លែងរបស់គូភាគី។ បញ្ជីបែបនេះ នៅពេលដែលត្រូវបានរៀបចំក្នុងដំណាក់កាលសមរម្យនៃដំណើរការមជ្ឈត្តការ និងធ្វើបច្ចុប្បន្នភាពតាមភាពចាំបាច់ អាចជួយគូភាគីក្នុងការផ្តោតលើទឡ្ហីករណ៍របស់ពួកគេលើវិវាទដែលបានកំណត់ថាសំខាន់ដោយវេទិកាមជ្ឈត្តកម្ម ដោយហេតុនេះធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការមជ្ឈត្តការ និងកាត់បន្ថយការចំណាយ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

*(ខ) ការកំណត់លំដាប់ចំណុចវិវាទនឹងត្រូវសម្រេច លទ្ធភាពនៃការបំបែកដំណើរការនីតិវិធី*

៦៩. ជាកម្មវត្ថុនៃការព្រមព្រៀងណាមួយរបស់គូភាគី វេទិកាមជ្ឈត្តកម្មមានភាពបត់បែន និងឆន្ទានុសិទ្ធិក្នុងការកំណត់លំដាប់លំដោយនៃដំណើរការមជ្ឈត្តការ ហើយអាចដោះស្រាយរាល់ចំណុចវិវាទជាសមូហភាព ឬតាមលំដាប់លំដោយអាស្រ័យលើកាលៈទេសៈនៃមជ្ឈត្តការ។

៧០. អាស្រ័យលើចំណុចវិវាទ វេទិកាមជ្ឈត្តកម្មអាចពិចារណាពីភាពសមស្របក្នុងការសម្រេចចិត្តលើការទាមទារ ឬវិវាទជាក់លាក់ (ដូចជាយុត្តាធិការ ការទទួលខុសត្រូវ ឬវិវាទដាច់ដោយឡែកផ្សេងទៀតដែលការសម្រេចនេះទំនងជានឹងជំរុញការដោះស្រាយសំណុំរឿង) មុនវិវាទផ្សេងទៀត។ ក្នុងការពិចារណាអំពីវិធីសាស្ត្របែបនេះ វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើក្រោមច្បាប់ស្តីពីមជ្ឈត្តការជាធរមានមជ្ឈត្តវិនិច្ឆ័យដោយផ្នែក ឬសេចក្តីសម្រេចលើការទាមទារ ឬវិវាទដែលមានអាទិភាពទាំងនោះជាកម្មវត្ថុនៃការត្រួតពិនិត្យតាមផ្លូវតុលាការមុនពេលមជ្ឈត្តវិនិច្ឆ័យជាស្ថាពរត្រូវបានចេញនោះទេ។ ករណីដែលវេទិកាមជ្ឈត្តកម្មសម្រេចអនុម័តវិធីសាស្ត្របំបែកដំណើរការនីតិវិធីក្នុងការដោះស្រាយវិវាទជាក់លាក់ ការដាក់សេចក្តីថ្លែងរបស់គូភាគី ហើយប្រសិនបើអាចអនុវត្តបាន ការបញ្ជូនឯកសាររបស់ពួកគេអាចត្រូវបានរៀបចំនៅដំណាក់កាលដាច់ដោយឡែកពីគ្នា ដើម្បីស្របតាមការរៀបចំនៃដំណើរការមជ្ឈត្តការដាច់ដោយឡែកនោះ។ វិធីសាស្ត្របែបនេះអាចជះឥទ្ធិពលដល់ដំណើរការវិនិច្ឆ័យដូច្នេះហើយ វេទិកាមជ្ឈត្តកម្មអាចពិចារណាយ៉ាងហ្មត់ចត់ថាតើដំណើរការដាច់ដោយឡែកបែបនេះទំនងជាជួយសន្សំសំចៃពេលវេលា និងការចំណាយនៃដំណើរការទាំងមូល ឬមានឥទ្ធិពលអវិជ្ជមានដែរឬទេ។

*(គ) ការទាមទារ ឬការសង្គ្រោះដែលទាមទារ*

៧១. ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាការទាមទារ ឬការសង្គ្រោះដែលទាមទារដោយភាគីមួយមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ ឧទាហរណ៍ ដើម្បីធានាបាននូវការអនុវត្តនៃមជ្ឈត្តវិនិច្ឆ័យដែលអាចផ្តល់ការទាមទារ ឬការសង្គ្រោះនោះ វេទិកាមជ្ឈត្តកម្មអាចពិចារណាក្នុងការផ្តល់ព័ត៌មានដល់គូភាគីអំពីកង្វល់របស់ខ្លួន ដោយចងចាំក្នុងចិត្តថាវេទិកាមជ្ឈត្តកម្មនឹងជាទូទៅជៀសវាងការផ្តល់យោបល់អំពីគំនិតផ្តួចផ្តើមរបស់ខ្លួនលើការស្នើសុំការសង្គ្រោះថ្មី។

## ១២. ការសះជាដោយសន្តិវិធី

៧២. ក្នុងកាលៈទេសៈសមស្រប វេទិកាមជ្ឈត្តកម្មអាចលើកឡើងពីលទ្ធភាពនៃការសះជារវាងគូភាគីបាន។ នៅក្នុងយុត្តាធិការមួយចំនួន ច្បាប់ស្តីពីមជ្ឈត្តការអនុញ្ញាតឱ្យមានការសម្របសម្រួលលើការសះជាដោយវេទិកាមជ្ឈត្តកម្មជាមួយនឹងការព្រមព្រៀងរបស់គូភាគី។ នៅក្នុងយុត្តាធិការផ្សេងទៀត គឺមិនអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មធ្វើលើសពីការលើកឡើងពីលទ្ធភាពនៃការសះជាដែលនឹងមិនពាក់ព័ន្ធនឹងវេទិកាមជ្ឈត្តកម្មនោះទេ។ ករណីដែលច្បាប់ស្តីពីមជ្ឈត្តការជាធរមានអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មសម្របសម្រួលដល់ការសះជា ព្រោះវេទិកាមជ្ឈត្តកម្មអាច ប្រសិនបើមានការស្នើសុំពីគូភាគី ណែនាំ ឬជួយគូភាគីក្នុងការចរចាររបស់ពួកគេ។ បណ្តុំវិធានស្តីពីមជ្ឈត្តការមួយចំនួនចែងពីការសម្របសម្រួលនៃការសះជាដោយវេទិកាមជ្ឈត្តកម្ម។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

## ១៣. ភស្តុតាងឯកសារ

*(ក) ការកំណត់ពេលវេលាសម្រាប់ការដាក់ភស្តុតាងជាឯកសារដោយគូភាគី ផលវិបាកនៃការខកខានក្នុងការដាក់ភស្តុតាង ឬការដាក់ភស្តុតាងយឺតយ៉ាវ*

៧៣. វេទិកាមជ្ឈត្តកម្មជាធម្មតា កំណត់អំឡុងពេលសម្រាប់ការដាក់ភស្តុតាងជាឯកសារនៅដើមដំបូងនៃដំណើរការមជ្ឈត្តការ។ វេទិកាមជ្ឈត្តកម្មអាចណែនាំគូភាគីឱ្យដាក់ភស្តុតាងជាមួយការដាក់សេចក្តីថ្លែងជាលាយលក្ខណ៍អក្សររបស់ពួកគេ ឬមិនលើសពីរយៈពេលដែលបានកំណត់ជាក់លាក់។

៧៤. វេទិកាមជ្ឈត្តកម្មអាចបញ្ជាក់ពីផលវិបាកនៃការដាក់ភស្តុតាងយឺតយ៉ាវ និងរបៀបដែលវេទិកាមជ្ឈត្តកម្មនឹងដោះស្រាយជាមួយនឹងសំណើសុំទទួលយកការដាក់ភស្តុតាងយឺតយ៉ាវ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីដែលស្នើសុំការដាក់ភស្តុតាងបន្ទាប់ពីរយៈពេលកំណត់ ផ្តល់ហេតុផលសម្រាប់ការពន្យារពេល។ វេទិកាមជ្ឈត្តកម្ម ក្នុងការសម្រេចចិត្តថាតើត្រូវទទួលយកការដាក់ភស្តុតាងយឺតយ៉ាវឬទេ នឹងត្រូវពិចារណាអំពីប្រសិទ្ធភាពនីតិវិធីដែលសម្រេចបានដោយការបដិសេធការដាក់ភស្តុតាងយឺតយ៉ាវ អត្ថប្រយោជន៍ដែលអាចមានពីការទទួលយក និងផលប្រយោជន៍របស់គូភាគី (ឧទាហរណ៍ ផ្តល់ឱកាសឱ្យភាគីម្ខាងទៀតក្នុងការបញ្ចេញមតិ ឬដាក់ភស្តុតាងបន្ថែម ដើម្បីឆ្លើយតបទៅនឹងការដាក់ភស្តុតាងយឺតយ៉ាវ)។

៧៥. វេទិកាមជ្ឈត្តកម្មអាចរំលឹកគូភាគីថា ប្រសិនបើភាគីណាមួយធ្វើការដាក់ភស្តុតាងដែលមិនស្របទៅតាមកាលវិភាគ វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើត្រូវទទួលយកការដាក់ភស្តុតាងនោះ ឬទេ។ ក្នុងនោះដែរ ប្រសិនបើភាគីមួយត្រូវបានស្នើសុំឱ្យដាក់ភស្តុតាងដើម្បីគាំទ្រសំណុំរឿងរបស់ខ្លួន ប៉ុន្តែខកខានក្នុងការដាក់ភស្តុតាងតាមរយៈពេលកំណត់ដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់សម្រាប់ការខកខាននោះ វេទិកាមជ្ឈត្តកម្មអាចធ្វើមជ្ឈត្តវិនិច្ឆ័យផ្អែកលើត្រឹមភស្តុតាងដែលមានចំពោះមុខតែប៉ុណ្ណោះ។

*(ខ) សំណើសុំបញ្ចេញឯកសារ*

៧៦. វិធីសាស្ត្រនៃច្បាប់ស្តីពីមជ្ឈត្តការ និងការអនុវត្តមានភាពខុសប្លែកគ្នាត្រង់ថាតើភាគីមួយអាចស្នើសុំភាគីម្ខាងទៀត ឬគូភាគីឱ្យបញ្ចេញឯកសារជាក់លាក់ និងក្នុងវិសាលភាពកម្រិតណាដែលវេទិកាមជ្ឈត្តកម្មគួរតែបង្គាប់ឱ្យបញ្ចេញបែបនេះ (សម្រាប់លទ្ធភាពនៃការដាក់ឯកសារជាភស្តុតាង) នៅពេលដែលភាគីត្រូវបានស្នើសុំបដិសេធមិនបញ្ចេញដោយស្ម័គ្រចិត្ត។ ដូច្នេះ វាអាចមានសារៈប្រយោជន៍សម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការបញ្ជាក់ជាមួយនឹងគូភាគីនៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ថាតើភាគីមួយអាចស្នើសុំឱ្យភាគីម្ខាងទៀតបញ្ចេញឯកសារបានដែរឬទេ ហើយប្រសិនបើបាន ចង្អុលបង្ហាញពីវិសាលភាពនៃការបញ្ចេញឯកសារ និងកំណត់រយៈពេលកំណត់ដែលពាក់ព័ន្ធ ទម្រង់នៃសំណើបញ្ចេញឯកសារ និងនីតិវិធីសម្រាប់សំណើតវ៉ា ប្រសិនបើពាក់ព័ន្ធ។

៧៧. សំណើសុំបញ្ចេញឯកសារអាចត្រូវបានធ្វើឡើងតាមវិធីសាស្ត្រផ្សេងៗ ប៉ុន្តែភាគច្រើនត្រូវបានកត់ត្រាក្នុងកាលវិភាគដែលត្រូវបានផ្តល់ឱ្យភាគីម្ខាងទៀត និងកំណត់មិនត្រឹមតែឯកសារដែលត្រូវបានស្នើសុំប៉ុណ្ណោះទេ ប៉ុន្តែក៏មានហេតុផលសម្រាប់ការស្នើសុំ ហើយជានិច្ចកាលក៏មានសេចក្តីថ្លែងអំពីមូលហេតុដែលឯកសារដែលត្រូវបានស្នើសុំត្រូវបានគេជឿថាស្ថិតក្រោមការកាន់កាប់របស់ភាគីម្ខាងទៀត ហើយភាគីដែលស្នើសុំមិនមានផងដែរ។ ក្រោយមក ភាគីម្ខាងទៀតអាចចែងនៅក្នុងកាលវិភាគថាតើខ្លួនយល់ព្រមនឹងសំណើនេះឬទេ បើមិនយល់ព្រមត្រូវចែងពីហេតុផល។ ជាធម្មតា



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

គូភាគីដំបូងត្រូវដោះដូរឯកសារដែលត្រូវបញ្ចេញតែក្នុងចំណោមពួកគេប៉ុណ្ណោះ ហើយបន្ទាប់មកពួកគេកំណត់ថាតើឯកសារដែលត្រូវបញ្ចេញណាដែលត្រូវដាក់ជាភស្តុតាង។

៧៨. ករណីដែលសំណើសុំបញ្ចេញឯកសារត្រូវបានជំទាស់ ភាគីស្នើសុំអាចសម្រេចចិត្តដាក់សំណើតវ៉ាទៅវេទិកាមជ្ឈត្តកម្មសម្រាប់ការកំណត់ថាតើត្រូវបង្គាប់ឱ្យភាគីណាមួយ ឬភាគីទាំងពីរបញ្ចេញឯកសារនោះទេ។ វេទិកាមជ្ឈត្តកម្មជារឿយៗនឹងបន្ថែមកាលវិភាគនូវកំណត់ត្រានៃសេចក្តីសម្រេចរបស់ខ្លួនថាតើត្រូវបង្គាប់ឱ្យបញ្ចេញសំណើដែលត្រូវបានតវ៉ាណាមួយ ឬទេ។

*(គ) ភស្តុតាងដែលទទួលបានដោយវេទិកាមជ្ឈត្តកម្មពីតតិយជន*

៧៩. ក្នុងករណីចាំបាច់ និងអនុញ្ញាតដោយច្បាប់ស្តីពីមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការជាធរមាន វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការសមស្របដោយខ្លួនឯងដើម្បីទទួលបានភស្តុតាងពីតតិយជនបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគូភាគី។ ចំណុចនេះពាក់ព័ន្ធនឹងភស្តុតាងជាឯកសារ ក៏ដូចជាភស្តុតាងផ្សេងទៀត (សូមមើលខាងក្រោម កំណត់ចំណាំលេខ ១៦)។

*(ឃ) ការអះអាងអំពីប្រភព និងភាពត្រឹមត្រូវនៃភស្តុតាងជាឯកសារ*

៨០. នៅដំណាក់កាលដំបូងនៃដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មនឹងជានិច្ចកាលបញ្ជាក់ថា លុះត្រាតែភាគីមួយលើកការជំទាស់នឹងការសន្និដ្ឋានខាងក្រោមនេះណាមួយក្នុងអំឡុងពេលជាក់លាក់មួយ វេទិកាមជ្ឈត្តកម្មនឹងយល់ថា៖ (ក) ភស្តុតាងជាឯកសារត្រូវបានទទួលយកថាមានប្រភពដើមមកពីប្រភពដែលបានបង្ហាញនៅក្នុងឯកសារ (ខ) ទំនាក់ទំនងដែលបានបញ្ជូនត្រូវបានទទួលយកដោយមិនចាំបាច់មានភស្តុតាងបន្ថែមថាវាត្រូវបានទទួលដោយអ្នកទទួល និង (គ) សំណៅចម្លងត្រូវបានទទួលយកថាជាការធ្វើឡើងវិញត្រឹមត្រូវតាមច្បាប់ដើម។ សេចក្តីថ្លែងដោយវេទិកាមជ្ឈត្តកម្មអំពីអានុភាពនេះអាចសម្រួលដល់ការដាក់ភស្តុតាង និងមិនលើកទឹកចិត្តការជំទាស់ដែលមិនមានមូលដ្ឋាន និងពន្យារពេល។

៨១. ប្រសិនបើមានបញ្ហាទាក់ទងនឹងប្រភព ភាពត្រឹមត្រូវ ឬភាពពេញលេញនៃភស្តុតាងជាឯកសារ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យមានការផ្ទៀងផ្ទាត់បាន។ វេទិកាមជ្ឈត្តកម្មអាចតម្រូវបន្ថែមទៀតថា ភស្តុតាងនៅក្នុងទម្រង់ដើមនៅតែអាចទទួលបានដោយគូភាគី និងវេទិកាមជ្ឈត្តកម្ម។

*(ង) ការបង្ហាញភស្តុតាងជាឯកសារ*

៨២. ដើម្បីជៀសវាងការដាក់ភស្តុតាងស្ទួនគ្នា ជាធម្មតាសម្រាប់គូភាគីក្នុងការព្រមព្រៀង ឬសម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការណែនាំថា នៅពេលដែលភស្តុតាងជាឯកសារត្រូវបានដាក់ក្នុងកំណត់ត្រាដោយភាគីម្ខាង វាមិនចាំបាច់ត្រូវដាក់ម្តងទៀតដោយភាគីម្ខាងទៀតឡើយ។

៨៣. បន្ទាប់ពីភាគីនីមួយៗបានដាក់ភស្តុតាងជាឯកសាររបស់ខ្លួន វេទិកាមជ្ឈត្តកម្មអាចជំរុញគូភាគីក្នុងការរៀបចំសំណុំភស្តុតាងរួមមុនពេលសវនាការ។ វាក៏អាចអនុវត្តបានផងដែរសម្រាប់គូភាគី និង/ឬវេទិកាមជ្ឈត្តកម្មក្នុងការជ្រើសរើសភស្តុតាងដែលត្រូវបានប្រើជាញឹកញាប់ ហើយបង្កើតសំណុំនៃឯកសារ "ការងារ" ឬ "ស្នូល" ដោយមិនគិតថាតើឯកសារទាំងនេះត្រូវបានដាក់រួមគ្នា ឬផ្សេងគ្នាក៏ដោយ។

៨៤. ការបង្ហាញភស្តុតាងជាក់លាក់អាចត្រូវបានសម្របសម្រួលផ្អែកលើបរិមាណ ឬលក្ខណៈរបស់ភស្តុតាង ប្រសិនបើខ្លឹមសាររបស់ភស្តុតាងត្រូវបានសង្ខេបតាមរយៈរបាយការណ៍ពីអ្នកតំណាងផ្នែកច្បាប់ ឬអ្នកជំនាញ (ឧទាហរណ៍ គណនេយ្យករសាធារណៈ ឬវិស្វករពិគ្រោះយោបល់)។ របាយការណ៍អាច

បង្ហាញព័ត៌មានជាទម្រង់សង្ខេប ការរៀបចំជាតារាង ឬគំនូសតាង។ ការបង្ហាញបែបនេះអាចត្រូវបានដាក់បញ្ចូលគ្នាជាមួយនឹងការរៀបចំដែលផ្តល់ឱ្យគូភាគី និងវេទិកាមជ្ឈត្តកម្មនូវឱកាសក្នុងការពិនិត្យមើលទិន្នន័យមូលដ្ឋាន និងវិធីសាស្ត្រដែលត្រូវបានប្រើសម្រាប់ការរៀបចំរបាយការណ៍ ក៏ដូចជាដើម្បីផ្ទៀងផ្ទាត់ការសន្និដ្ឋានណាមួយដែលត្រូវបានធ្វើឡើងក្នុងការរៀបចំរបស់ខ្លួន។

៨៥ កំណត់ចំណាំទី ៧ និងទី១០ លើកឡើងអំពីការអនុវត្តជាក់ស្តែងលម្អិតផ្សេងទៀតដែលគូភាគី និងវេទិកាមជ្ឈត្តកម្មអាចធ្វើការពិចារណាទាក់ទងនឹងការបង្ហាញភស្តុតាងជាឯកសារ។

## ១៤. សាក្សីនៃអង្គហេតុ

*(ក) ការកំណត់អត្តសញ្ញាណសាក្សីនៃអង្គហេតុ ទំនាក់ទាក់ទងជាមួយគូភាគី និងអ្នកតំណាងរបស់ពួកគេ*

(i) សេចក្តីថ្លែងរបស់សាក្សី និងការជូនដំណឹងជាមុន

៨៦. វេទិកាមជ្ឈត្តកម្មអាចធ្វើការបញ្ជាក់ជាមួយគូភាគីថាតើសាក្សីនៃអង្គហេតុនឹងត្រូវបានបង្ហាញខ្លួនឬទេ ហើយប្រសិនបើដូច្នេះ ថាតើសេចក្តីថ្លែងរបស់សាក្សីជាលាយលក្ខណ៍អក្សរនឹងត្រូវដាក់ជូនដែរ ឬទេ (សូមមើលខាងក្រោម កថាខណ្ឌទី ៨៨)។

៨៧. វេទិកាមជ្ឈត្តកម្មក៏អាចបញ្ជាក់ពីរបៀបដែលសាក្សី និងវិសាលភាពនៃសក្ខីកម្មដែលត្រូវបានរំពឹងទុករបស់ពួកគេនឹងត្រូវបានកំណត់មុនពេលសវនាការណាមួយ។ ជាពិសេស វេទិកាមជ្ឈត្តកម្មអាចស្នើសុំពីគូភាគីនូវព័ត៌មានខាងក្រោមទាក់ទងនឹងសាក្សីដែលបានស្នើបន្ថែមលើឈ្មោះ និងអាសយដ្ឋានរបស់ពួកគេ៖

(ក) ប្រធានបទ និងអង្គហេតុដែលសាក្សីនឹងផ្តល់សក្ខីកម្ម

(ខ) ភាសាដែលសាក្សីនឹងផ្តល់សក្ខីកម្ម

(គ) លក្ខណៈនៃទំនាក់ទំនងរបស់សាក្សីជាមួយភាគីណាមួយ និងវិវាទ

(ឃ) គុណវុឌ្ឍិ និងបទពិសោធន៍របស់សាក្សី ប្រសិនបើ និងក្នុងវិសាលភាពដែលពាក់ព័ន្ធនឹងវិវាទ ឬសក្ខីកម្ម និង

(ង) របៀបដែលសាក្សីបានដឹងពីអង្គហេតុដែលពួកគេនឹងផ្តល់សក្ខីកម្ម។

៨៨. សេចក្តីថ្លែងរបស់សាក្សីគឺជាឯកសារដែលអាចធ្វើជាភស្តុតាងពីសាក្សីនោះ ហើយជាធម្មតានឹងរួមបញ្ចូលព័ត៌មានដែលមាននៅក្នុងកថាខណ្ឌទី ៨៧។ វាមានសារៈប្រយោជន៍ប្រសិនបើសេចក្តីថ្លែងរបស់សាក្សីកំណត់ភស្តុតាងជាឯកសារទាំងអស់ដែលបានពឹងផ្អែកលើ។ ករណីដែលសេចក្តីថ្លែងរបស់សាក្សីត្រូវបានដាក់ជូន ជាទូទៅត្រូវបានគេទទួលយកថាសេចក្តីថ្លែងនេះមិនចាំបាច់ធ្វើឡើងម្តងទៀតដោយផ្ទាល់មាត់នៅពេលសវនាការនោះទេ។ ជារឿយៗសេចក្តីថ្លែងរបស់សាក្សីត្រូវបានទទួលយកជាសក្ខីកម្មផ្ទាល់ពេញលេញរបស់សាក្សី ហើយមានតែសេចក្តីថ្លែងផ្ទាល់មាត់ខ្លីមួយប៉ុណ្ណោះសម្រាប់បញ្ជាក់ (អាចបង្ហាញពីចំណុចជាក់លាក់) ឬ ធ្វើបច្ចុប្បន្នភាពសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ ត្រូវបានតម្រូវនៅក្នុងសវនាការ។សេចក្តីថ្លែងរបស់សាក្សីជាលាយលក្ខណ៍អក្សរអាចដកចេញនូវភាពចាំបាច់ក្នុងការស្តាប់សាក្សីលើអង្គហេតុដែលមិនមានវិវាទ ព្រោះថាមិនមែនសាក្សីទាំងអស់ដែលបានដាក់សេចក្តីថ្លែងសាក្សីចាំបាច់ត្រូវបានស្តាប់ចម្លើយនៅសវនាការនោះទេ (សូមមើលខាងក្រោមកថាខណ្ឌទី ១២៣)។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីនីមួយៗកំណត់អត្តសញ្ញាណសាក្សីណាមួយរបស់ភាគីម្ខាងទៀត ឬគូភាគីដែលខ្លួនចង់ពិនិត្យនៅក្នុងសវនាការ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

(ii) ថាតើភាគីណាមួយ ឬបុគ្គលដែលពាក់ព័ន្ធនឹងភាគីមួយអាចនឹងត្រូវបានស្ដាប់ក្នុងនាមជាសាក្សីដែរ ឬទេ

៨៩. មជ្ឈត្តការអន្តរជាតិអាចខុសពីការអនុវត្តរបស់តុលាការក្នុងស្រុកទាក់ទងនឹងថាតើភាគីមួយ ឬបុគ្គលដែលពាក់ព័ន្ធនឹងភាគីមួយអាចត្រូវបានស្ដាប់ចម្លើយក្នុងនាមជាសាក្សីដែរ ឬទេ (ឧទាហរណ៍ អ្នកប្រតិបត្តិ និយោជិត ឬភ្នាក់ងាររបស់ខ្លួន)។ នៅក្រោមប្រព័ន្ធច្បាប់មួយចំនួន ភាគីមួយ ឬបុគ្គលទាំងនោះអាចមិនត្រូវបានអនុញ្ញាតឱ្យផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីនៅក្នុងដំណើរការតុលាការនោះទេ ប៉ុន្តែអាចត្រូវបានស្ដាប់ចម្លើយក្នុងសមត្ថភាពផ្សេងគ្នា (ដូចជាភាគី ឬបុគ្គលដែលមានព័ត៌មានពាក់ព័ន្ធ)។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងមជ្ឈត្តការអន្តរជាតិ ភាពខុសគ្នានេះកម្រត្រូវបានគេសង្កេតឃើញណាស់ ហើយភាគច្រើនភាគី ឬបុគ្គលបែបនេះអាចត្រូវបានគេស្ដាប់ចម្លើយក្នុងនាមជាសាក្សី។

(iii) លក្ខណៈនៃទំនាក់ទំនងរបស់ភាគី ឬអ្នកតំណាងរបស់ខ្លួនជាមួយសាក្សី

៩០. ការអនុវត្តនៅក្នុងមជ្ឈត្តការអន្តរជាតិអាចខុសគ្នាពីតុលាការក្នុងស្រុក ចំពោះការអនុញ្ញាតនៃទំនាក់ទំនងមុនពេលផ្ដល់សក្ខីកម្មរវាងភាគី ឬអ្នកតំណាងរបស់ខ្លួន ជាមួយនឹងសាក្សីដែលបង្ហាញដោយភាគីនោះ និងលក្ខណៈនៃទំនាក់ទំនងបែបនេះ។ នៅក្នុងមជ្ឈត្តការអន្តរជាតិ ការទំនាក់ទំនងមុនពេលផ្ដល់សក្ខីកម្មត្រូវបានទទួលយកយ៉ាងទូលំទូលាយ ទោះបីជាមានវិធានគណៈមេធាវីមួយចំនួនហាមឃាត់ទីប្រឹក្សាផ្នែកច្បាប់ពីការពិភាក្សាសក្ខីកម្មរបស់សាក្សីមុនពេលសវនាការតុលាការ ឬមជ្ឈត្តការក៏ដោយ។ វេទិកាមជ្ឈត្តកម្មអាចពិចារណាការបញ្ជាក់នៅដើមដំបូងនៃដំណើរការមជ្ឈត្តការអំពីលក្ខណៈនៃទំនាក់ទំនងភាគី ឬអ្នកតំណាងរបស់ខ្លួន ដែលត្រូវបានអនុញ្ញាតជាមួយសាក្សីរបស់ខ្លួន នៅពេលសាកសួរអំពីអង្គហេតុនៃសំណុំរឿង នៅពេលរៀបចំសេចក្ដីថ្លែងរបស់សាក្សីជាលាយលក្ខណ៍អក្សរ និងនៅពេលដែលសាក្សីកំពុងផ្ដល់សក្ខីកម្មផ្ទាល់មាត់។ ខណៈដែលការអនុវត្តទូទៅមួយគឺអនុញ្ញាតគូភាគី ឬអ្នកតំណាងរបស់ពួកគេធ្វើការស្ដាប់ចម្លើយសាក្សីរបស់ពួកគេអំពីអង្គហេតុនៃវិវាទ និង/ឬជួយពួកគេក្នុងការរៀបចំសេចក្ដីថ្លែងរបស់សាក្សីនោះ មានការយល់ឃើញផ្សេងគ្នាអំពីថាតើភាគី ឬអ្នកតំណាងរបស់ខ្លួនអាចជួយសាក្សីបានត្រឹមកម្រិតណាក្នុងការត្រៀមខ្លួនសម្រាប់សវនាការ។

*(ខ) របៀបទទួលយកភស្តុតាងផ្ទាល់មាត់របស់សាក្សី*

៩១. ខណៈពេលដែលច្បាប់ស្ដីពីមជ្ឈត្តការ និងវិធានស្ដីពីជ្ឈត្តការភាគច្រើនផ្ដល់ឱ្យវេទិកាមជ្ឈត្តកម្មនូវឆន្ទានុសិទ្ធិទូលំទូលាយទាក់ទងនឹងរបៀបនៃការទទួលយកភស្តុតាងផ្ទាល់មាត់របស់សាក្សី (ការផ្ដល់សក្ខីកម្មផ្ទាល់មាត់) ការអនុវត្តមានភាពខុសប្លែកគ្នាត្រង់ចំណុចនេះ។ ដើម្បីជួយសម្រួលដល់ការត្រៀមខ្លួនរបស់គូភាគីសម្រាប់សវនាការ វេទិកាមជ្ឈត្តកម្មអាចពិចារណាបញ្ហាមួយចំនួន ឬទាំងអស់យោងទៅខាងក្រោមនៅក្នុងកំណត់ចំណាំទី ១៧។

## ១៥. អ្នកជំនាញ

*(ក) ប្រភេទនៃអ្នកជំនាញ និងការជ្រើសរើស*

៩២. ច្បាប់ស្ដីពីមជ្ឈត្តការ និងវិធានស្ដីពីមជ្ឈត្តការជាច្រើនផ្ដល់ឱ្យមានការចូលរួមពីអ្នកជំនាញម្នាក់ ឬច្រើននាក់ក្នុងដំណើរការមជ្ឈត្តការ។ ជាញឹកញាប់ គូភាគីនឹងបង្ហាញរបាយការណ៍មួយរបស់អ្នកជំនាញម្នាក់ ឬច្រើននាក់ដែលបានជ្រើសរើសដោយពួកគេ (ហៅថា "អ្នកជំនាញដែលបានតែងតាំងដោយភាគី" ឬ "សាក្សីជំនាញ") ដើម្បីដោះស្រាយវិវាទ។ វេទិកាមជ្ឈត្តកម្មអាចតែងតាំងអ្នកជំនាញរបស់ខ្លួន (ហៅថា "អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម") ដើម្បីបង្ហាញរបាយការណ៍



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

លើវិវាទដែលតម្រូវឱ្យមានការណែនាំរបស់អ្នកជំនាញ ឬជួយក្នុងកិច្ចការដែលត្រូវការចំណេះដឹង ឬជំនាញឯកទេស។

៩៣. ស្ថាប័នមជ្ឈត្តការ សភាពាណិជ្ជកម្ម និងស្ថាប័នឯកទេសផ្សេងទៀតអាចជាជំនួយដល់គូភាគី និងវេទិកាមជ្ឈត្តកម្មក្នុងការជ្រើសរើសអ្នកជំនាញ ប្រសិនបើចាំបាច់។ អ្នកជំនាញជាធម្មតាត្រូវបានតម្រូវឱ្យផ្ដល់ព័ត៌មានអំពីជំនាញ និងបទពិសោធន៍ថ្មីៗរបស់ខ្លួននៅក្នុងប្រវត្តិរូបសង្ខេប មុនពេលត្រូវបានជ្រើសរើស ឬតែងតាំង។

## *(ខ) អ្នកជំនាញដែលតែងតាំងដោយភាគី សាក្សីជំនាញ*

៩៤. ភាគីនីមួយៗអាចណែនាំអ្នកជំនាញរបស់ខ្លួន ("អ្នកជំនាញដែលតែងតាំងដោយភាគី" ឬ "សាក្សីជំនាញ") ទាក់ទងនឹងវិវាទដែលត្រូវឆ្លើយតបនៅក្នុងរបាយការណ៍របស់ពួកគេ ឬគូភាគីអាចយល់ព្រមលើបញ្ជីរួមនៃចំណុចវិវាទដែលត្រូវឆ្លើយតបដោយអ្នកជំនាញ។

៩៥. ក្រោយមកទៀត វេទិកាមជ្ឈត្តកម្មអាចអញ្ជើញអ្នកជំនាញដែលតែងតាំងដោយភាគីដែលកំពុងស្រាវជ្រាវពីបញ្ហាដូចគ្នាឱ្យដាក់របាយការណ៍រួមដែលកំណត់ចំណុចដែលពួកគេយល់ស្រប និងមិនយល់ស្របគ្នា ដែលអាចបង្រួមវិវាទដែលត្រូវដោះស្រាយនៅពេលក្រោយក្នុងដំណើរការនីតិវិធី។

៩៦. នៅពេលដែលអ្នកជំនាញដែលតែងតាំងដោយភាគីបញ្ចេញមតិផ្ទុយគ្នា វេទិកាមជ្ឈត្តកម្មអាចពិចារណាស្នើសុំរបាយការណ៍បន្ថែម ឬរបាយការណ៍រហ័សរបស់អ្នកជំនាញ ដើម្បីដោះស្រាយចំណុចដែលមានវិវាទ។

៩៧. វេទិកាមជ្ឈត្តកម្មក៏អាចស្នើសុំអ្នកជំនាញដែលតែងតាំងដោយភាគីដើម្បីផ្លាស់ប្ដូររបាយការណ៍របស់ពួកគេ ហើយបន្ទាប់មកបើកកិច្ចប្រជុំក្រៅផ្លូវការមួយ ដែលចំណុចដែលអ្នកជំនាញយល់ស្រប ឬមិនយល់ស្របត្រូវបានយកមកពិភាក្សា។ ជាមួយនឹងវិធីសាស្ត្រនេះ អ្នកជំនាញអាចឆ្លើយតបទៅនឹងសំណួររបស់គ្នាទៅវិញទៅមកកាន់តែមានប្រសិទ្ធភាព ស្វែងរកមូលដ្ឋានរួម និង/ឬចំណាយពេលដើម្បីពិភាក្សាអំពីបញ្ហាជាក់លាក់។ របាយការណ៍របស់អ្នកជំនាញអាចត្រូវបានកែប្រែទៅតាមនោះ ឬលទ្ធផលនៃនីតិវិធីអាចត្រូវបានទំនាក់ទំនងដោយអ្នកជំនាញនៅសវនាការ។

៩៨. ជួនកាល គូភាគីអាចព្រមព្រៀងលើអ្នកជំនាញរួមតែមួយ ឬព្រមព្រៀងថាអ្នកជំនាញដែលត្រូវបានតែងតាំងដោយពួកគេនឹងចេញរបាយការណ៍រួមតែមួយ ដែលគូភាគីមានសិទ្ធិក្នុងការបញ្ចេញមតិលើ។ វិធីសាស្ត្របែបនេះអាចមានអត្ថប្រយោជន៍ក្នុងការកាត់បន្ថយកម្រៃសេវាចំណាយ និងសម្រួលដល់ដំណើរការមជ្ឈត្តការ។ នៅពេលព្រមព្រៀងលើអ្នកជំនាញរួមតែមួយ ឬការចេញរបាយការណ៍រួមតែមួយ វាអាចចាំបាច់ក្នុងការបញ្ជាក់នៅដើមដំបូងថាតើគូភាគីនឹងត្រូវបានចងកាតព្វកិច្ចដោយការសន្និដ្ឋានរបស់អ្នកជំនាញរួម ឬអ្វីដែលមានចែងនៅក្នុងរបាយការណ៍រួមឬទេ។

៩៩. វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើរបាយការណ៍អ្នកជំនាញគួរតែត្រូវបានដាក់ជាបន្តបន្ទាប់គ្នា ឬក្នុងពេលដំណាលគ្នា ក៏ដូចជាពេលវេលានៃការដាក់ជូនរបស់ពួកគេ ជាពិសេសថាតើការដាក់ជូនបែបនេះគួរតែត្រូវបានធ្វើឡើងរួមជាមួយនឹងសេចក្ដីថ្លែងទាមទារ ឬសេចក្ដីថ្លែងដោះសារឬទេ។

១០០. បន្ថែមពីនេះ វេទិកាមជ្ឈត្តកម្មអាចបញ្ជាក់អំពីលក្ខណៈ និងទំហំនៃការទំនាក់ទំនងរវាងគូភាគីឬអ្នកតំណាង និងអ្នកជំនាញរបស់ពួកគេ ហើយថាតើភាគីណាមួយអាចត្រូវបានស្នើសុំឱ្យបញ្ចេញការទំនាក់ទំនងទាំងនេះឬទេ។

*(គ) អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម*

(i) មុខងាររបស់អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្ម

១០១. មុខងាររបស់អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មជាធម្មតាមានការរៀបចំរបាយការណ៍លើចំណុចជាក់លាក់មួយ ឬមួយចំនួនដែលត្រូវការចំណេះដឹងឯកទេស ឬជួយដល់វេទិកាមជ្ឈត្តកម្មក្នុងការស្វែងយល់អំពីបញ្ហាបច្ចេកទេសមួយចំនួន។ ក្នុងការសម្រេចចិត្តថាតើត្រូវតែងតាំងអ្នកជំនាញរបស់ខ្លួន ឬយ៉ាងណា វេទិកាមជ្ឈត្តកម្មជាធម្មតាគិតគូរអំពីប្រសិទ្ធភាពនៃដំណើរការមជ្ឈត្តការ។ ករណីមួយចំនួន វេទិកាមជ្ឈត្តកម្មអាចសម្រេច តែងតាំងអ្នកជំនាញនៅដំណាក់កាលក្រោយៗនៃដំណើរការមជ្ឈត្តការ ឧទាហរណ៍ ប្រសិនបើមតិយោបល់របស់អ្នកជំនាញដែលតែងតាំងដោយភាគីមិនអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មឈានដល់ការសន្និដ្ឋានចុងក្រោយមួយ។

១០២. មុននឹងតែងតាំងអ្នកជំនាញ វេទិកាមជ្ឈត្តកម្មជាធម្មតានឹងធានាថាអ្នកជំនាញមានគុណវុឌ្ឍិតាមលក្ខខណ្ឌ និងទទួលបានសេចក្តីថ្លែងការណ៍អំពីភាពមិនលំអៀង និងឯករាជ្យរបស់គាត់។ វេទិកាមជ្ឈត្តកម្មជាធម្មតាផ្តល់ឱកាសឱ្យគូភាគីនីមួយៗក្នុងការបញ្ចេញមតិអំពីអាណត្តិ គុណវុឌ្ឍិ ភាពមិនលម្អៀង និងឯករាជភាពដែលបានស្នើរបស់អ្នកជំនាញ។

១០៣. វេទិកាមជ្ឈត្តកម្មគួរតែពិគ្រោះយោបល់ជាមួយអ្នកជំនាញនៅពេលដែលខ្លួនទទួលបានការតែងតាំង ដើម្បីបញ្ជាក់ពីវិសាលភាពនៃរបាយការណ៍ និងវិវាទដែលត្រូវរ៉ាប់រង។ វេទិកាមជ្ឈត្តកម្មក៏អាចពិគ្រោះយោបល់ជាមួយអ្នកជំនាញមុនពេលបញ្ចប់របាយការណ៍របស់ខ្លួនផងដែរ ដើម្បីធានាថារបាយការណ៍ឆ្លើយតបទៅនឹងអាណត្តិដែលបានស្នើ។

១០៤. វេទិកាមជ្ឈត្តកម្មអាចពិចារណាបញ្ជាក់ពីលក្ខណៈ និងទំហំនៃការទំនាក់ទំនងដែលអ្នកជំនាញរបស់ខ្លួនអាចមានជាមួយគូភាគី និងអ្នកតំណាងរបស់ពួកគេ រួមគ្នា ឬដោយឡែកពីគ្នា និងរបៀបដោះស្រាយទំនាក់ទំនងលើបញ្ហាសម្ងាត់។

១០៥. ករណីដែលអ្នកជំនាញត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មបានបង្ហាញរបាយការណ៍របស់ខ្លួន ជាធម្មតាគូភាគីមានសិទ្ធិបញ្ចេញមតិលើរបាយការណ៍នោះតាមរយៈការដាក់សេចក្តីថ្លែងជាផ្លូវការ ឬក្រៅផ្លូវការ (រួមទាំងតាមរយៈរបាយការណ៍ដោយអ្នកជំនាញរបស់ខ្លួនផ្ទាល់) និងសាកសួរអ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មនៅសវនាការ។

(ii) លក្ខខណ្ឌយោងរបស់អ្នកជំនាញដែលតែងតាំងដោយវេទិកាមជ្ឈត្តកម្ម

១០៦. គោលបំណងនៃលក្ខខណ្ឌយោងរបស់អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មគឺដើម្បីបង្ហាញពីចម្ងល់ដែលអ្នកជំនាញត្រូវផ្តល់យោបល់របស់ខ្លួន ដោយហេតុនេះជៀសវាងការផ្តល់យោបល់លើចំណុចដែលមិនមែនសម្រាប់អ្នកជំនាញធ្វើការវាយតម្លៃ និងដើម្បីឱ្យអ្នកជំនាញប្តេជ្ញាឱ្យទាន់ពេលវេលា។ លក្ខខណ្ឌយោងក៏ធានានូវតម្លាភាពទាក់ទងនឹងទំនាក់ទំនងរវាងវេទិកាមជ្ឈត្តកម្ម និងអ្នកជំនាញដែលបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មផងដែរ។

១០៧. លក្ខខណ្ឌយោងជាធម្មតាកំណត់ព័ត៌មានលម្អិតទាក់ទងនឹងឯកសារ និងទីកន្លែង ទ្រព្យសម្បត្តិ ឬទំនិញដែលអ្នកជំនាញអាចចូលប្រើប្រាស់បាន និងរបៀបដែលអ្នកជំនាញនឹងទទួលបានព័ត៌មានដើម្បីរៀបចំរបាយការណ៍។ ដើម្បីជួយសម្រួលដល់ការវាយតម្លៃនៃរបាយការណ៍របស់អ្នកជំនាញគួរតែតម្រូវឱ្យអ្នកជំនាញបញ្ចូលក្នុងរបាយការណ៍នូវលក្ខខណ្ឌយោងព្រមទាំងព័ត៌មានអំពីវិធីសាស្ត្រដែល



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

ប្រើក្នុងការឈានមកដល់ការសន្និដ្ឋានរបស់ខ្លួន ប្រភពនៃព័ត៌មានដែលពឹងផ្អែកលើ និងការសន្មត់អង្គហេតុដែលសន្មត់ធ្វើឡើងក្នុងការរៀបចំរបាយការណ៍។ ប្រាក់ឈ្នួលរបស់អ្នកជំនាញដែលត្រូវបានតែងតាំងដោយវេទិកាមជ្ឈត្តកម្មជាធម្មតាមានបង្ហាញនៅក្នុងលក្ខខណ្ឌយោង។

## ១៦. ការត្រួតពិនិត្យទីតាំង ទ្រព្យសម្បត្តិ ឬទំនិញ

១០៨. នៅក្នុងមជ្ឈត្តការមួយចំនួន វេទិកាមជ្ឈត្តកម្មអាចត្រូវការការវាយតម្លៃភស្តុតាងជាក់ស្តែង ក្រៅពីភស្តុតាងជាឯកសារ ឧទាហរណ៍ តាមរយៈការត្រួតពិនិត្យទំនិញ ឬទ្រព្យសម្បត្តិ ឬទៅកាន់ទីតាំងជាក់លាក់ណាមួយ។ ការត្រួតពិនិត្យទីតាំងជាក់ស្តែង ឬពិចម្ងាយអាចជាភស្តុតាង ឬអាចជាមុខងារពន្យល់បង្ហាញ ដែលធ្វើឱ្យវេទិកាមជ្ឈត្តកម្មយល់ពីសំណុំរឿងប្រសើរជាងមុន។

*(ក) ភស្តុតាងជាក់ស្តែង*

១០៩. ប្រសិនបើភស្តុតាងជាក់ស្តែងនឹងត្រូវបានដាក់ជូន វេទិកាមជ្ឈត្តកម្មអាចកំណត់ពេលវេលានិងរបៀបនៃការបង្ហាញភស្តុតាង រៀបចំឱ្យភាគីម្ខាងទៀត ឬគូភាគីត្រៀមខ្លួនសម្រាប់ការបង្ហាញភស្តុតាង និងចាត់វិធានការសម្រាប់ការរក្សាទុកភស្តុតាង។

*(ខ) ការត្រួតពិនិត្យទីតាំង ទ្រព្យសម្បត្តិ ឬទំនិញ*

១១០. វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើការត្រួតពិនិត្យទីតាំង ទ្រព្យសម្បត្តិ ឬទំនិញមានប្រយោជន៍ ឬចាំបាច់ដែរ ឬទេ។ បើមានប្រយោជន៍ ឬចាំបាច់ វេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើការត្រួតពិនិត្យទីតាំងតម្រូវឱ្យមានវត្តមានដោយផ្ទាល់របស់មជ្ឈត្តករឬទេ ឬថាតើការត្រួតពិនិត្យដោយប្រយោលអាចធ្វើទៅបានឬគ្រប់គ្រាន់ឬទេ ដើម្បីផលប្រយោជន៍នៃប្រសិទ្ធភាព ឬការសន្សំសំចៃ។

១១១. ប្រសិនបើការត្រួតពិនិត្យជាក់ស្តែងនៃទីតាំង ទ្រព្យសម្បត្តិ ឬទំនិញធ្វើឡើង វេទិកាមជ្ឈត្តកម្មនឹងចាំបាច់ត្រូវពិចារណាលើបញ្ហាផ្សេងៗទៀត។ ទាំងនេះរួមមាន ការកំណត់ពេលវេលា ការបែងចែកកម្រៃសេវា ការរៀបចំចាំបាច់ដើម្បីធានាថាគូភាគីទាំងអស់អាចមានវត្តមាន ឬត្រូវបានតំណាងនៅពេលចុះពិនិត្យ និងការចង្អុលបង្ហាញថាតើអ្នកណានឹងដឹកនាំការត្រួតពិនិត្យ និងផ្តល់ការពន្យល់។ មុននឹងចុះពិនិត្យ វាអាចមានសារៈប្រយោជន៍សម្រាប់គូភាគី និងវេទិកាមជ្ឈត្តកម្មក្នុងការយល់ព្រមលើបែបបទចុះត្រួតពិនិត្យ និងវិសាលភាពនៃការចុះត្រួតពិនិត្យ។

១១២. ទីតាំង ទ្រព្យសម្បត្តិ ឬទំនិញដែលត្រូវត្រួតពិនិត្យ ជារឿយៗស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីមួយនៃគូភាគី។ ប្រសិនបើដូច្នេះ គួរតែអនុញ្ញាតឱ្យភាគីម្ខាងទៀតទៅមើលកន្លែងត្រូវត្រួតពិនិត្យមុនពេលវេទិកាមជ្ឈត្តកម្មចុះទៅ ដើម្បីផ្តល់ឱកាសឱ្យភាគីនោះមានឱកាសស្គាល់លក្ខណៈ និងស្ថានភាពនៃទីតាំង ទ្រព្យសម្បត្តិ ឬទំនិញ និងដើម្បីស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មពិនិត្យ ភស្តុតាងបន្ថែម ឬភស្តុតាងផ្សេងទៀតនៅកន្លែងចុះត្រួតពិនិត្យ។

១១៣. ករណីដែលនិយោជិត ឬអ្នកតំណាងភាគីមួយដែលគ្រប់គ្រងទីតាំង ទ្រព្យសម្បត្តិ ឬទំនិញផ្តល់ការណែនាំ ឬការពន្យល់ដល់វេទិកាមជ្ឈត្តកម្ម នេះជាធម្មតាធ្វើឡើងនៅចំពោះមុខភាគីម្ខាងទៀត ឬអ្នកតំណាងរបស់ពួកគេ។ គួរកត់ចំណាំថា ការពន្យល់បែបនេះ ជាធម្មតាមិនត្រូវបានចាត់ទុកជាភស្តុតាងនៅក្នុងដំណើរការមជ្ឈត្តការនោះទេ ដែលខុសគ្នាទៅនឹងសេចក្តីថ្លែងដែលបុគ្គលទាំងនោះអាចធ្វើជាសាក្សីនៃអង្គហេតុនៅក្នុងសវនាការ។

## ១៧. សវនាការ

### *(ក) សេចក្តីសម្រេចថាតើត្រូវបើកសវនាការ ឬទេ*

១១៤. ច្បាប់ស្តីពីមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការជារឿយៗអនុញ្ញាតឱ្យភាគីណាមួយស្នើសុំឱ្យមានសវនាការសម្រាប់ការបង្ហាញភស្តុតាងដោយសាក្សី និងអ្នកជំនាញ និង/ឬសម្រាប់ការទាញហេតុផលផ្ទាល់មាត់។ ករណីដែលគ្មានភាគីណាមួយស្នើសុំឱ្យមានសវនាកានោះទេ វេទិកាមជ្ឈត្តកម្មអាចកំណត់ថាតើត្រូវមានសវនាការដែរឬទេ។ ភាពចាំបាច់នៃសវនាការអាចនឹងត្រូវបានពិចារណាឡើងវិញនៅដំណាក់កាលក្រោយៗ ដោយពិចារណាលើការដាក់សេចក្តីថ្លែងរបស់គូភាគី។

១១៥. វាជាការអនុវត្តដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយក្នុងការតម្រូវឲ្យមានសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ សេចក្តីថ្លែងរបស់សាក្សី របាយការណ៍អ្នកជំនាញ និងភស្តុតាងជាឯកសារផ្សេងទៀតដែលត្រូវបានដាក់ជូនមុនពេលសវនាការ។ នេះអាចជួយក្នុងការផ្តោតលើវិវាទដែលត្រូវដោះស្រាយនៅពេលសវនាការ និងជៀសវាងសវនាការដែលចំណាយពេលយូរ។ ដើម្បីជួយសម្រួលដល់ការត្រៀមខ្លួនរបស់គូភាគី ដើម្បីជៀសវាងការយល់ច្រឡំណាមួយ និងដើម្បីការពារវិវាទដែលមិនបានរំពឹងទុកត្រូវបានលើកឡើង វេទិកាមជ្ឈត្តកម្មអាចពិភាក្សាចំណុចនេះជាមួយគូភាគីនៅដើមដំបូងនៃដំណើរការមជ្ឈត្តការ ក៏ដូចជាមុនពេលសវនាការណាមួយ។

### *(ខ) កាលវិភាគនៃសវនាការ*

១១៦. កាលបរិច្ឆេទសម្រាប់សវនាការជាធម្មតាត្រូវបានកំណត់នៅពេលមុនបំផុតតាមដែលអាចធ្វើទៅបានដើម្បីធានាពេលទំនេររបស់អ្នកចូលរួម។ ការអនុវត្តជាទូទៅគឺបើកសវនាការក្នុងរយៈពេលតែមួយជាប់ៗគ្នា។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន ការបើកសវនាការក្នុងអំឡុងពេលដាច់ដោយ ឡែកពីគ្នាគឺចាំបាច់ដើម្បីបំពេញតាមកាលវិភាគផ្សេងៗគ្នារបស់គូភាគី សាក្សី អ្នកជំនាញ និងវេទិកាមជ្ឈត្តកម្ម។

១១៧. រយៈពេលនៃសវនាការជាចម្បងអាស្រ័យលើភាពស្មុគស្មាញនៃវិវាទ និងភស្តុតាង ព្រមទាំងចំនួនសាក្សី និងអ្នកជំនាញដែលត្រូវស្តាប់ចម្លើយ។ រយៈពេលក៏អាស្រ័យលើបែបបទនីតិវិធីដែលប្រើក្នុងមជ្ឈត្តការផងដែរ។

១១៨. វាអាចមានសារៈប្រយោជន៍ក្នុងការកំណត់ចំនួនសរុបនៃពេលវេលាដែលភាគីនីមួយៗមានសម្រាប់ធ្វើសេចក្តីថ្លែងផ្ទាល់មាត់ ការសាកសួរសាក្សី និងអ្នកជំនាញដែលខ្លួនបង្ហាញ និងសាកសួរសាក្សីនិងអ្នកជំនាញនៃភាគីម្ខាងទៀត ឬគូភាគី។ ជាទូទៅ ភាគីនីមួយៗត្រូវបានបែងចែកចំនួនពេលដូចគ្នាលុះត្រាតែវេទិកាមជ្ឈត្តកម្មពិចារណាថាការបែងចែកផ្សេងគ្នាគឺមានភាពត្រឹមត្រូវ។ វាមានសារៈប្រយោជន៍ក្នុងការកំណត់ពីរបៀបដែលពេលវេលាត្រូវបានរាប់ក្នុងអំឡុងពេលសវនាការ។

១១៩. ប្រសិនបើវាមានភាពប្រាកដនិយម យុត្តិធម៌ និងជាកម្មវត្ថុនៃការណែនាំដោយវេទិកាមជ្ឈត្តកម្មការបែងចែកពេលវេលាបែបនេះនឹងធ្វើឱ្យកាន់តែងាយស្រួលសម្រាប់គូភាគីក្នុងការរៀបគម្រោងធ្វើបទបង្ហាញរបស់ខ្លួនអំពីវត្ថុតាង និងទឡ្ហីករណ៍ផ្សេងៗ កាត់បន្ថយលទ្ធភាពនៃការខើចពេលវេលានៅពេលជិតបញ្ចប់សវនាការ និងជៀសវាងភាពអយុត្តិធម៌ជាក់ស្តែង ឬតាមការយល់ឃើញណាមួយដែលបណ្តាលមកពីភាគីមានពេលវេលាមិនស្មើគ្នា។

១២០. វេទិកាមជ្ឈត្តកម្មជាធម្មតាកំណត់ពេលវេលាសម្រាប់ការពិភាក្សារបស់ខ្លួនក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ ក៏ដូចជាមុន និងក្នុងពេលដ៏ខ្លីបន្ទាប់ពីការបិទសវនាការ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

*(គ) របៀបនៃការធ្វើសវនាការ*

(i) ការអនុវត្តផ្សេងៗគ្នា

១២១. ដោយមើលឃើញពីសិទ្ធិទូលំទូលាយរបស់វេទិកាមជ្ឈត្តកម្មក្នុងការដំណើរការសវនាការ និងការអនុវត្តផ្សេងៗគ្នាទាក់ទងនឹងសវនាការ វាអាចជំរុញប្រសិទ្ធភាពនៃដំណើរការមជ្ឈត្តការ ប្រសិនបើវេទិកាមជ្ឈត្តកម្មធ្វើការបញ្ជាក់ដល់គូភាគីមុនសវនាការនូវរបៀបដែលសវនាការនឹងត្រូវបានធ្វើឡើង យ៉ាងហោចណាស់ក្នុងន័យទូលាយ។

(ii) ការធ្វើសវនាការដោយផ្ទាល់ ឬពីចម្ងាយ

១២២. សវនាការអាចធ្វើឡើងដោយផ្ទាល់ ឬពីចម្ងាយតាមរយៈមធ្យោបាយបច្ចេកវិទ្យា (សូមមើលខាងលើ កថាខណ្ឌទី ១៩)។ សេចក្តីសម្រេចថាតើត្រូវរៀបចំសវនាការដោយផ្ទាល់ ឬពីចម្ងាយ ទំនងជាត្រូវបានជះឥទ្ធិពលដោយកត្តាផ្សេងៗ ដូចជាសារៈសំខាន់នៃវិវាទ ការចង់បានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយសាក្សី កាលវិភាគទំនេររបស់គូភាគី សាក្សី និងអ្នកជំនាញ ក៏ដូចជាកម្រៃសេវា និងលទ្ធភាពពន្យារពេលនៃការបើកសវនាការដោយផ្ទាល់។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចនឹងត្រូវពិចារណាលើបញ្ហាបច្ចេកទេស ដូចជាភាពចុះសម្រុងនៃមធ្យោបាយបច្ចេកវិទ្យា ដែលត្រូវបានប្រើប្រាស់នៅទីតាំងផ្សេងៗគ្នា។

(iii) ការសម្រេចថាតើសាក្សីនៃអង្គហេតុ និងសាក្សីជំនាញ ("សាក្សី") មួយណានឹងផ្តល់សក្ខីកម្មផ្ទាល់មាត់

១២៣. ករណីដែលគូភាគីបានដាក់សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ ឬ របាយការណ៍ពីសាក្សីរបស់ពួកគេរួចហើយ វេទិកាមជ្ឈត្តកម្មអាចសាកសួរភាគីនីមួយៗ មុនពេលសវនាការ ថាតើសាក្សីណាមួយរបស់ភាគីម្ខាងទៀត ឬគូភាគី ដែលខ្លួនចង់សាកសួរនៅក្នុងសវនាការ (សូមមើលខាងលើ កថាខណ្ឌទី ៥៨)។ ជាធម្មតា ភាគីត្រូវទទួលខុសត្រូវក្នុងការធ្វើឱ្យសាក្សីរបស់ខ្លួនណាមួយអាចចូលរួមនៅក្នុងសវនាការបាន ប្រសិនបើភាគីម្ខាងទៀត ឬវេទិកាមជ្ឈត្តកម្មបានបញ្ជាក់ថាខ្លួនចង់សាកសួរសាក្សីនោះ។ ប្រសិនបើគ្មានភាគីណាមួយចង់សាកសួរសាក្សីទេ ហើយវេទិកាមជ្ឈត្តកម្មក៏មិនមានបំណងចង់ធ្វើដូច្នេះដែរ វេទិកាមជ្ឈត្តកម្មអាចសម្រេចថាសាក្សីមិនចាំបាច់ផ្តល់សក្ខីកម្មនៅក្នុងសវនាការនោះទេ។ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចស្រដៀងគ្នានេះ ទោះបីជាភាគីម្ខាងទៀតបានស្នើសុំឱកាស ដើម្បីសួរតទល់ជាមួយនឹងសាក្សី ឬភាគីបានស្នើសុំបង្ហាញសាក្សីរបស់ខ្លួនក៏ដោយ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាសក្ខីកម្មដែលបានស្នើឡើង ឧទាហរណ៍ មិនសំខាន់ ឬដដែលៗ ដោយពិចារណាពីឱកាសសមហេតុផលរបស់ភាគីស្នើសុំក្នុងការបង្ហាញសំណុំរឿងរបស់ខ្លួន។ ការសម្រេចមិនស្តាប់នូវសក្ខីកម្មផ្ទាល់មាត់ពីសាក្សីក្នុងកាលៈទេសៈទាំងនេះ មិនគួរផ្លាស់ប្តូរទំងន់ដែលនឹងត្រូវបានផ្តល់លើសេចក្តីថ្លែងជាលាយលក្ខណ៍អក្សររបស់សាក្សីនោះទេ។

(iv) ការមិនចូលបង្ហាញខ្លួនរបស់សាក្សី

១២៤. វេទិកាមជ្ឈត្តកម្មអាចពិចារណាផ្តល់ព័ត៌មានដល់គូភាគីអំពីផលវិបាកដែលអាចកើតមានរបស់សាក្សីដែលត្រូវបានអញ្ជើញឱ្យមកផ្តល់សក្ខីកម្មនៅសវនាការ ដែលមិនបានបង្ហាញខ្លួន។ វេទិកាមជ្ឈត្តកម្មជាធម្មតាមានភាពបត់បែនមួយចំនួនក្នុងការដោះស្រាយជាមួយនឹងការមិនចូលបង្ហាញខ្លួនបែបនេះ រួមមានទាក់ទងនឹងថាតើសេចក្តីថ្លែងជាលាយលក្ខណ៍អក្សររបស់សាក្សីនោះ អាចនៅតែត្រូវបានពិចារណាឬទេ ហើយប្រសិនបើដូច្នេះ តើត្រូវផ្តល់ទម្ងន់យ៉ាងណាចំពោះសេចក្តីថ្លែងនេះ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

(v) ការអញ្ជើញសាក្សីដោយវេទិកាមជ្ឈត្តកម្ម

១២៥. វេទិកាមជ្ឈត្តកម្មអាចត្រូវចាត់វិធានការសមស្រប ដើម្បីអញ្ជើញសាក្សី មកផ្តល់សក្ខីកម្ម ឧទាហរណ៍ ប្រសិនបើគូភាគីខកខានក្នុងការហៅសាក្សីដែលវេទិកាមជ្ឈត្តកម្មចង់សាកសួរ។ វេទិកាមជ្ឈត្តកម្មក៏អាចផ្តល់ជំនួយដល់គូភាគីដែលចង់សាកសួរសាក្សីដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេដោយអញ្ជើញសាក្សីនោះមកចូលរួម។

(vi) ថាតើសក្ខីកម្មផ្ទាល់មាត់នឹងត្រូវបានផ្តល់ក្រោមសម្បថ ឬការអះអាងឬទេ ហើយប្រសិនបើដូច្នេះ តើក្រោមទម្រង់បែបណា

១២៦. ច្បាប់ស្តីពីមជ្ឈត្តការ និងការអនុវត្តខុសគ្នាពាក់ព័ន្ធនឹងថាតើសក្ខីកម្មផ្ទាល់មាត់ត្រូវតែផ្តល់ក្រោមសម្បថ ឬការអះអាងស្រដៀងគ្នាក្នុងការផ្តល់ការពិតឬទេ។ នៅក្នុងប្រព័ន្ធច្បាប់មួយចំនួន វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យសាក្សីធ្វើសម្បថតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ នៅក្នុងប្រព័ន្ធច្បាប់ផ្សេងទៀត សក្ខីកម្មផ្ទាល់មាត់ក្រោមសម្បថគឺមិនត្រូវបានគេស្គាល់នៅក្នុងមជ្ឈត្តការទេ ឬសូម្បីតែអាចត្រូវបានគេចាត់ទុកថាមិនសមរម្យ ព្រោះមានតែមន្ត្រីដូចជាចៅក្រម ឬសារការីប៉ុណ្ណោះ ដែលមានអំណាចក្នុងការចាត់ចែងសម្បថ។ ក្នុងកាលៈទេសៈបែបនេះ សាក្សីអាចនឹងត្រូវបានសុំឱ្យអះអាងថាពួកគេនឹងធ្វើសក្ខីកម្មដោយការពិត។វាប្រហែលជាចាំបាច់ដើម្បីបញ្ជាក់ថាតើអ្នកណានឹងចាត់ចែងសម្បថណាមួយ។ក្នុងករណីដែលអាចអនុវត្តបាន វេទិកាមជ្ឈត្តកម្មអាចទាញចំណាប់អារម្មណ៍របស់សាក្សីចំពោះការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌសម្រាប់ការផ្តល់សក្ខីកម្មមិនពិត។

(vii) លំដាប់នៃការធ្វើបទបង្ហាញនៅសវនាការ

១២៧. វេទិកាមជ្ឈត្តកម្មមានសិទ្ធិទូលំទូលាយក្នុងការកំណត់ពីលំដាប់នៃការធ្វើបទបង្ហាញនៅសវនាការ។ ក្នុងដែនសិទ្ធិទូលំទូលាយនេះ ការអនុវត្តមានខុសគ្នា ជាឧទាហរណ៍ ថាតើសេចក្តីថ្លែងបើក ឬសេចក្តីថ្លែងបិទត្រូវបានស្តាប់ ឬទេ ហើយប្រសិនបើត្រូវស្តាប់ ត្រូវពិចារណាអំពីលំដាប់ និងរយៈពេល ហើយភាគីណាមួយនិយាយចុងក្រោយ។

១២៨. សិទ្ធិទូលំទូលាយរបស់វេទិកាមជ្ឈត្តកម្មក៏អនុវត្តផងដែរចំពោះរបៀប និងលំដាប់ដែលសាក្សីត្រូវបានស្តាប់ និងចំពោះវិវាទផ្សេងទៀតដែលត្រូវដោះស្រាយនៅក្នុងសវនាការណាមួយ។ នៅពេលដែលសាក្សីជាច្រើននឹងត្រូវបានស្តាប់ និងសក្ខីកម្មរយៈពេលវែងត្រូវបានគេរំពឹងទុក វាមានសារៈប្រយោជន៍ក្នុងការកំណត់ជាមុននូវលំដាប់ដែលពួកគេនឹងត្រូវបានហៅ។ ក្នុងកាលៈទេសៈជាក់លាក់ វេទិកាមជ្ឈត្តកម្មអាចនឹងចង់ស្តាប់សាក្សីមួយចំនួនជាមួយគ្នាលើកម្មវត្ថុតែមួយ។ នេះទំនងជាកាត់បន្ថយកម្រៃសេវា និងសម្រួលដល់ការកំណត់កាលវិភាគ។ ភាគីនីមួយៗអាចនឹងត្រូវបានអញ្ជើញឱ្យផ្តល់យោបល់លើលំដាប់ដែលខ្លួនស្នើឱ្យមានសាក្សីរបស់ខ្លួនផ្តល់សក្ខីកម្ម។

(viii) របៀបដែលសាក្សីនៃអង្គហេតុ និងសាក្សីជំនាញ ("សាក្សី") នឹងត្រូវបានស្តាប់

១២៩. សាក្សីអាចនឹងត្រូវបានសាកសួរជាមុនដោយវេទិកាមជ្ឈត្តកម្ម។ ករណីផ្សេងទៀត ការអនុវត្តជាទូទៅគឺសាក្សីត្រូវបានសាកសួរជាមុនដោយភាគីដែលហៅសាក្សី (ក្នុងវិសាលភាពដែលអនុញ្ញាត និងប្រសិនបើចាំបាច់ សូមមើលខាងលើ កថាខណ្ឌទី ៨៨ និង ១២៣) ហើយបន្ទាប់មកសាកសួរតទល់ដោយភាគីម្ខាងទៀត ឬគូភាគី។ នៅក្នុងបរិបទនេះ សំណួរអាចកើតមានថាតើការសាកសួរតទល់ត្រូវបានកម្រិតក្នុងវិសាលភាពនៃសេចក្តីថ្លែងរបស់សាក្សី និងសក្ខីកម្មផ្ទាល់មាត់ដែរឬទេ។ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចបញ្ជាក់បញ្ហានេះមុនពេលការដាក់សេចក្តីថ្លែងរបស់សាក្សី និងសវនាការ។

បន្ទាប់ពីការសាកសួរតទល់ សាក្សីអាចនឹងត្រូវបានសាកសួរឡើងវិញដោយភាគីដែលហៅសាក្សីជាមួយនឹងសំណួរដែលកម្រិតចំពោះបញ្ហាដែលបានលើកឡើងក្នុងអំឡុងពេលសាកសួរតទល់។ ក្រោយមក ភាគី ឬគូភាគីដែលសាកសួរតទល់អាចសួរសាក្សីបន្ថែម។ ជាធម្មតា វេទិកាមជ្ឈត្តកម្មអាចសួរសំណួរបានគ្រប់ពេល។

១៣០. ច្បាប់ស្តីពីមជ្ឈត្តការ និងការអនុវត្តខុសគ្នាពាក់ព័ន្ធនឹងកម្រិតនៃការគ្រប់គ្រងការអនុវត្តរបស់វេទិកាមជ្ឈត្តកម្មលើការសាកសួរសាក្សីដោយគូភាគី។ ជាឧទាហរណ៍ មជ្ឈត្តករមួយចំនួនអនុញ្ញាតឱ្យគូភាគីសួរសំណួរដោយសេរី និងដោយផ្ទាល់ទៅកាន់សាក្សី។ មជ្ឈត្តករផ្សេងទៀតអនុវត្តវិធាន និងការកម្រិតតឹងរ៉ឹងជាងទាក់ទងនឹងទម្រង់នៃការសាកសួរផ្ទាល់ ឬសាកសួរតទល់ ដែលប្រហាក់ប្រហែលទៅនឹងការអនុវត្តនៅតុលាការ។

(ix) ថាតើសាក្សីនៃអង្គហេតុអាចស្ថិតនៅក្នុងបន្ទប់សវនាការនៅពេលដែលពួកគេមិនផ្តល់សក្ខីកម្មដែរឬទេ

១៣១. ការអនុវត្តមានភាពខុសប្លែកគ្នាទាក់ទងនឹងវត្តមានសាក្សីនៃអង្គហេតុនៅក្នុងបន្ទប់សវនាការមុន និងក្រោយពេលដែលពួកគេបានផ្តល់សក្ខីកម្ម។ ជាវិធានទូទៅ មជ្ឈត្តករមួយចំនួនពិចារណាថា សាក្សីនៃអង្គហេតុមិនគួរត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការទេ លើកលែងតែនៅពេលដែលពួកគេកំពុងផ្តល់សក្ខីកម្ម។ គោលបំណងគឺដើម្បីការពារសាក្សីនៃអង្គហេតុពីឥទ្ធិពលនៃសេចក្តីថ្លែងរបស់សាក្សីផ្សេងទៀត និងដើម្បីការពារលទ្ធភាពនៃវត្តមានរបស់សាក្សីម្នាក់មានឥទ្ធិពលលើសក្ខីកម្មរបស់សាក្សីផ្សេងទៀត។ នៅពេលដែលសាក្សីនៃអង្គហេតុមិនត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការ ជាធម្មតាវិធានការនឹងត្រូវធ្វើឡើង ដើម្បីជៀសវាងថាពួកគេបានទទួលប្រតិចារិកណាមួយនៅពេលដំណាលគ្នានៃសវនាការ។ មជ្ឈត្តករផ្សេងទៀតពិចារណាថាវាមានសារៈប្រយោជន៍សម្រាប់សាក្សីនៃអង្គហេតុក្នុងការបង្ហាញខ្លួននៅពេលដែលសាក្សីផ្សេងទៀតកំពុងផ្តល់សក្ខីកម្ម ដើម្បីរារាំងសេចក្តីថ្លែងដែលមិនពិត និងដើម្បីបញ្ជាក់ ឬកាត់បន្ថយភាពផ្ទុយគ្នារវាងសាក្សី។ ជាវិធានទូទៅ សាក្សីនៃអង្គហេតុគួរតែត្រូវបានរារាំងពីការពិភាក្សាអំពីសក្ខីកម្មរបស់ពួកគេក្នុងអំឡុងពេលសម្រាកណាមួយនៅក្នុងការផ្តល់សក្ខីកម្មរបស់ពួកគេ។ វេទិកាមជ្ឈត្តកម្មអាចផ្តល់ការណែនាំអំពីសំណួរទាំងនេះជាមុន ព្រោះវាអាចប៉ះពាល់ដល់ការរៀបចំសវនាការ។

១៣២. វេទិកាមជ្ឈត្តកម្មអាចសម្រេចថាតើត្រូវប្រើវិធីសាស្ត្រណាសម្រាប់សាក្សីនៃអង្គហេតុនីមួយៗ។ ជាឧទាហរណ៍ វិធានដាច់ដោយឡែកមួយអាចមានលក្ខណៈសមស្របសម្រាប់សាក្សីនៃអង្គហេតុដែលបង្ហាញខ្លួនជាអ្នកតំណាងរបស់ភាគីមួយ ( ឧទាហរណ៍ នាយកគ្រប់គ្រង នាយកប្រតិបត្តិ ឬទីប្រឹក្សាផ្ទៃក្នុង ) ព្រោះអ្នកតំណាងបែបនេះអាចនឹងត្រូវមានវត្តមានពេញមួយសវនាការដើម្បីត្រួតពិនិត្យការបង្ហាញអំពីសំណុំរឿងរបស់ពួកគេ។

(x) ការដាក់ភស្តុតាងថ្មី

១៣៣. វេទិកាមជ្ឈត្តកម្មអាចបញ្ជាក់ដល់គូភាគីថា ជាធម្មតាភស្តុតាងថ្មីនឹងមិនត្រូវបានទទួលយកក្នុងអំឡុងពេលសវនាការនោះទេ។ ក្នុងកាលៈទេសៈពិសេសដែលវេទិកាមជ្ឈត្តកម្មទទួលយកភស្តុតាងថ្មីបែបនេះ វាអាចនឹងត្រូវពិចារណាថាតើត្រូវអនុញ្ញាតឱ្យមានការដាក់ភស្តុតាងបន្ថែមដែរឬទេ ដើម្បីឱ្យភាគីម្ខាងទៀតឆ្លើយតប។

### *(ឃ) ការរៀបចំសម្រាប់កំណត់ហេតុនៃសវនាការ*

១៣៤. វេទិកាមជ្ឈត្តកម្មអាចពិចារណាអំពីវិធីសាស្ត្រនៃការរៀបចំកំណត់ត្រានៃសេចក្តីថ្លែងផ្ទាល់មាត់ និងសក្ខីកម្មក្នុងអំឡុងពេលសវនាការ ព្រមទាំងអ្នកដែលនឹងត្រូវទទួលខុសត្រូវក្នុងការរៀបចំជាចាំបាច់។ ការថតសំឡេង និងប្រតិចារឹកត្រូវបានប្រើប្រាស់ជាទូទៅ។

១៣៥ គូភាគី និងវេទិកាមជ្ឈត្តកម្មអាចពិចារណាថាតើការថតសំឡេងគួរត្រូវបានធ្វើទៅជាប្រតិចារិក និងបញ្ជាក់ថាតើកំណត់ហេតុសំឡេង នឹងបង្កើតជាកំណត់ហេតុផ្លូវការនៃសវនាការ ឬទេ (សូមមើលខាងលើ កថាខណ្ឌទី ១៦)។ ប្រសិនបើប្រតិចារិកនឹងត្រូវធ្វើឡើង វេទិកាមជ្ឈត្តកម្មអាចពិចារណាថាគូភាគីនឹងត្រូវបានផ្តល់ឱកាសឱ្យពិនិត្យប្រតិចារិកយ៉ាងដូចម្តេច។ ឧទាហរណ៍ វាអាចត្រូវបានកំណត់ថា ការផ្លាស់ប្តូរណាមួយចំពោះកំណត់ត្រាត្រូវតែបានឯកភាពដោយគូភាគី ហើយប្រសិនបើខកខានដោយគូភាគី បញ្ជូនទៅវេទិកាមជ្ឈត្តកម្មដើម្បីធ្វើការសម្រេច។

### *(ង) ការដាក់ឯកសារក្រោយសវនាការ*

១៣៦. មុន ឬក្នុងអំឡុងពេលសវនាការ គូភាគី និងវេទិកាមជ្ឈត្តកម្មជាធម្មតាសម្រេចថាតើការដាក់ឯកសារបន្ថែមណាមួយត្រូវធ្វើឡើងដោយគូភាគីបន្ទាប់ពីសវនាការដែរឬទេ ហើយប្រសិនបើដូច្នេះ កាលវិភាគដែលស្របគ្នានេះជាធម្មតាត្រូវបានធ្វើឡើង។ ការដាក់ឯកសារក្រោយសវនាការបែបនេះអាចជាការចាំបាច់ដើម្បីអនុញ្ញាតឱ្យគូភាគីផ្តល់សេចក្តីសង្ខេបនៃសំណុំរឿង ដើម្បីលើកបញ្ហាជាក់លាក់ដែលបានកើតឡើងក្នុងអំឡុងពេលសវនាការ ឬលើកឡើងពីផលប៉ះពាល់លើសំណុំរឿងរបស់ពួកគេពីភស្តុតាងដែលបានលេចឡើងក្នុងអំឡុងពេលសវនាការ។

## ១៨. មជ្ឈត្តការពហុភាគី

១៣៧. នៅពេលដែលមជ្ឈត្តការមួយពាក់ព័ន្ធនឹងគូភាគីច្រើនជាងពីរ (មជ្ឈត្តការពហុភាគី) បញ្ហានីតិវិធីជាច្រើននៅតែមានដូចគ្នានឹងមជ្ឈត្តការដែលមានពីរភាគីផងដែរ។ ទោះយ៉ាងណាក៏ដោយ ការលំបាកអាចកើតឡើងនៅក្នុងមជ្ឈត្តការពហុភាគី។ ឧទាហរណ៍ វេទិកាមជ្ឈត្តកម្មគួរតែប្រុងប្រយ័ត្ន មិនត្រូវសន្មត់ថាគូភាគីដែលនៅក្រុមជាមួយគ្នាជាភាគីប្តឹងទាមទារឬភាគីឆ្លើយតបនឹងចាំបាច់ត្រូវមានផលប្រយោជន៍ដូចគ្នា នឹងធ្វើការដាក់សេចក្តីថ្លែងស្រដៀងគ្នា ឬនឹងទាមទារការសង្គ្រោះដូចគ្នា។

១៣៨. លើសពីនេះទៀត ការលំបាកបន្ថែមទៀតគឺការធានានូវយុត្តិធម៌នៃដំណើរការនីតិវិធី ហើយធានាថាគូភាគីផ្សេងទៀតមានឱកាសស្មើគ្នាក្នុងការចូលរួមក្នុងការតែងតាំងវេទិកាមជ្ឈត្តកម្ម។ កំណត់ចំណាំដែលកំណត់ចំណុចសំខាន់ដែលអាចត្រូវបានពិចារណាក្នុងការរៀបចំដំណើរការមជ្ឈត្តការជាទូទៅ មិនគ្របដណ្តប់លើសេចក្តីព្រាងកិច្ចព្រមព្រៀងមជ្ឈត្តការ ឬការបង្កើតវេទិកាមជ្ឈត្តកម្មនោះទេ។ ចំណុចសំខាន់ទាំងនោះបង្កឱ្យមានសំណួរពិសេសនៅក្នុងមជ្ឈត្តការពហុភាគី បើប្រៀបធៀបទៅនឹងមជ្ឈត្តការដែលមានតែពីរភាគី ហើយត្រូវបានលើកឡើងក្រោមវិធានស្តីពីមជ្ឈត្តការជាក់លាក់។[១២]

[១២] សូមមើល ឧទាហរណ៍ មាត្រា ១០(១) នៃវិធានស្តីពីមជ្ឈត្តការរបស់ UNCITRAL (ដែលបានកែសម្រួលក្នុងឆ្នាំ២០១០) ដែលចែងថា "(...) ករណីមជ្ឈត្តករបីនាក់នឹងត្រូវបានតែងតាំង ហើយមានពហុភាគីដែលជាភាគីប្តឹងទាមទារ ឬជាភាគីឆ្លើយតប លុះត្រាតែគូភាគីបានយល់ព្រមលើវិធីសាស្ត្រមួយផ្សេងទៀតនៃការតែងតាំងមជ្ឈត្តករ ពហុភាគីត្រូវតែងតាំងមជ្ឈត្តកររួមគ្នា មិនថាជាភាគីប្តឹងទាមទារ ឬភាគីឆ្លើយតបនោះទេ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

## ១៩. ការចូលរួមពីតតិយជន និងការរួមបញ្ចូលមជ្ឈត្តការ

### *(ក) ការចូលរួមពីតតិយជន*

១៣៩. ការចូលរួមពីតតិយជន មានន័យថាការបន្ថែមភាគីថ្មីមួយ ឬច្រើនក្នុងមជ្ឈត្តការដែលមានស្រាប់។ មិនមែនគ្រប់ពាក្យសុំការចូលរួមពីតតិយជនទាំងអស់ចាំបាច់តម្រូវឱ្យមានការយល់ព្រមពីគ្រប់គូភាគីទាំងអស់នោះទេ (ពោលគឺ គូភាគីនៃមជ្ឈត្តការ និងភាគីថ្មី)។ ភាគីថ្មីអាចត្រូវបានចងកាតព្វកិច្ចដោយកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការរួចហើយ ហើយដំណើរការចូលរួមពីតតិយជនអាចត្រូវបានអនុញ្ញាតដោយកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ ច្បាប់ស្តីពីមជ្ឈត្តការ និង/ឬវិធានស្តីពីមជ្ឈត្តការជាធរមាន។

១៤០. គូភាគីអាចបញ្ចូលភាគីថ្មីក្នុងមជ្ឈត្តការក្នុងស្ថានភាពដែលពួកគេនឹងមិនអាចបង្ហាញការទាមទាររបស់ពួកគេបានពេញលេញដោយមិនមានការចូលរួមពីភាគីថ្មីនោះ ឬមានបំណងចង់ជៀសវាងសេចក្តីសម្រេចដែលផ្ទុយគ្នាពាក់ព័ន្ធនឹងភាគីផ្សេងៗ។ វិធានស្តីពីមជ្ឈត្តការមួយចំនួន បានលើកឡើងពីការចូលរួមពីតតិយជន ដោយចែងថា វេទិកាមជ្ឈត្តកម្មអាច តាមសំណើរបស់ភាគីមួយ អនុញ្ញាតឱ្យភាគីថ្មីមួយ ឬច្រើនចូលរួមក្នុងមជ្ឈត្តការ ក្នុងលក្ខខណ្ឌដែលថាភាគីថ្មីត្រូវបានចងកាតព្វកិច្ចដោយកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការ។[១៣] វិធានស្តីពីមជ្ឈត្តការផ្សេងទៀតមិនតម្រូវឱ្យភាគីដែលត្រូវចូលរួមត្រូវបានចងកាតព្វកិច្ចដោយកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដែលការទាមទារកើតឡើងនោះទេ ប្រសិនបើវាត្រូវបានចងកាតព្វកិច្ចដោយកិច្ចព្រមព្រៀងមជ្ឈត្តការពាក់ព័ន្ធមួយផ្សេងទៀតដែលចងកាតព្វកិច្ចគូភាគីដែលមានស្រាប់ផងដែរ។ ក្នុងការសម្រេចថាតើត្រូវទទួលយកការចូលរួមតតិយជនដែរឬទេ វេទិកាមជ្ឈត្តកម្មអាចពិចារណាលើប្រសិទ្ធភាព ឬអប្រសិទ្ធភាពនៃនីតិវិធី (រួមទាំងការពន្យារពេលដែលអាចកើតមាន) ដែលអាចបណ្តាលមកពីភាពពាក់ព័ន្ធនៃភាគីថ្មីដែលត្រូវចូលរួម យុត្តិធម៌ចំពោះគូភាគីដែលមានស្រាប់ ឬមានភាពលំអៀងចំពោះភាគីណាមួយ។ វេទិកាមជ្ឈត្តកម្មក៏អាចពិចារណាអំពីអំណាចរបស់ខ្លួន និងលក្ខណៈដែលខ្លួនត្រូវបានបង្កើតឡើងផងដែរ។

១៤១. វាត្រូវបានផ្តល់អនុសាសន៍ថាភាគីថ្មីណាមួយគួរត្រូវបានបញ្ចូលឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបានក្នុងដំណើរការមជ្ឈត្តការ។ វិធានស្តីពីមជ្ឈត្តការជាច្រើនដែលដោះស្រាយបញ្ហានៃការចូលរួមពីតតិយជននេះ ដាក់កម្រិតលើលទ្ធភាពក្នុងការស្នើសុំការចូលរួមតតិយជន បន្ទាប់ពីវេទិកាមជ្ឈត្តកម្មត្រូវបានតែងតាំង។ ឧទាហរណ៍ ភាគីមួយអាចស្នើសុំបញ្ចូលតតិយជន នៅពេលដាក់សេចក្តីឆ្លើយតបចំពោះសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មរបស់ខ្លួន។[១៤] ក្នុងករណីបែបនេះ ភាគីថ្មីអាចត្រូវបានបញ្ចូលក្នុងនីតិវិធីមុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានតែងតាំង។ អាស្រ័យលើច្បាប់ស្តីពីមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការជាធរមាន តតិយជនក៏អាចត្រូវបានចូលរួមផងដែរបន្ទាប់ពីការតែងតាំងវេទិកាមជ្ឈត្តកម្មរួច ប្រសិនបើលក្ខខណ្ឌជាក់លាក់ត្រូវបានបំពេញ។

### *(ខ) ការរួមបញ្ចូលមជ្ឈត្តការ*

១៤២. បញ្ហានៃការរួមបញ្ចូលមជ្ឈត្តការកើតឡើងនៅក្នុងស្ថានភាពដែលមជ្ឈត្តការផ្សេងគ្នាជាច្រើនត្រូវបានផ្តួចផ្តើមឡើងនៅក្រោមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដូចគ្នា ឬផ្សេងគ្នា។ ការរួមបញ្ចូលមជ្ឈត្តការសំដៅលើការរួមបញ្ចូលគ្នានៃមជ្ឈត្តការដាច់ដោយឡែកពីគ្នាដោយមិនគិតថាតើមជ្ឈត្តការពាក់ព័ន្ធត្រូវបានចាប់ផ្តើមដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដូចគ្នា ឬខុសគ្នានោះទេ។ ការរួមបញ្ចូលមជ្ឈត្តការអាចបង្កើនប្រសិទ្ធភាព និងជៀសវាងលទ្ធផលមិនស្របគ្នាលើវិវាទពាក់ព័ន្ធ។ ទោះជា

[១៣] សូមមើល ឧទាហរណ៍ មាត្រា ១៧(៥) នៃវិធានស្តីពីមជ្ឈត្តការរបស់ UNCITRAL (ដែលបានកែសម្រួលក្នុងឆ្នាំ២០១០)។

[១៤] សូមមើល ឧទាហរណ៍ មាត្រា ៤(២)(ច) នៃវិធានស្តីពីមជ្ឈត្តការរបស់ UNCITRAL (ដែលបានកែសម្រួលក្នុងឆ្នាំ២០១០)។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com

Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

យ៉ាងណាក៏ដោយ ភាគីមួយ ឬច្រើនអាចមានផលប្រយោជន៍ត្រឹមត្រូវ ក្នុងការដោះស្រាយវិវាទដោយឡែកពីគ្នា ឧទាហរណ៍ ដោយសារវិវាទណាមួយមានអាទិភាព ឬការរួមបញ្ចូលនៃសំណុំរឿងច្រើននឹងធ្វើឱ្យដំណើរការមជ្ឈត្តការកាន់តែស្មុគស្មាញ និងចំណាយពេលវេលាច្រើន។ វាប្រហែលជាមិនអាចរួមបញ្ចូលមជ្ឈត្តការគ្រប់ពេលទេ ប្រសិនបើស្ថាប័នមជ្ឈត្តការមិនពាក់ព័ន្ធ។

១៤៣. ការកើនឡើងចំនួននៃវិធានស្តីពីមជ្ឈត្តការដែលលើកឡើងពីការរួមបញ្ចូលមជ្ឈត្តការ។វិធានស្តីពីមជ្ឈត្តការដែលអនុញ្ញាតឱ្យមានការរួមបញ្ចូលនៃមជ្ឈត្តការដែលមិនទាន់បញ្ចប់ពីរ ឬច្រើននោះ ធ្វើឡើងដោយពិចារណាលើកត្តាផ្សេងៗ ដូចជាថាតើ៖ (ក) ការរួមបញ្ចូលមជ្ឈត្តការត្រូវបានស្នើសុំដោយភាគីទេ (ខ) រាល់គូភាគីទាំងអស់យល់ព្រមលើការរួមបញ្ចូលមជ្ឈត្តការទេ (គ) វិវាទកើតឡើងទាក់ទងនឹងទំនាក់ទំនងផ្លូវច្បាប់ ឬក្រោមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដូចគ្នា ហើយបើមិនដូច្នេះទេ ថាតើកិច្ចព្រមព្រៀងទាំងនោះចុះសម្រុងគ្នាដែរឬទេ និង (ឃ) វេទិកាមជ្ឈត្តកម្មត្រូវបានតែងតាំងនៅក្នុងមជ្ឈត្តការណាមួយនៃមជ្ឈត្តការទាំងអស់។

## ២០. តម្រូវការដែលអាចមានពាក់ព័ន្ធនឹងទម្រង់ ខ្លឹមសារ ការដាក់ឯកសារ ការចុះឈ្មោះ និងការប្រគល់មជ្ឈត្តវិនិច្ឆ័យ

១៤៤. ភាគី និងវេទិកាមជ្ឈត្តកម្មគួរតែចងចាំអំពីច្បាប់មជ្ឈត្តការជាធរមាន និងច្បាប់នៅកន្លែងដែលមានសក្តានុពលក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ក៏ដូចជាវិធានមជ្ឈត្តការជាធរមាន ក្នុងការពិចារណាលើលក្ខខណ្ឌទាក់ទងនឹងទម្រង់ ខ្លឹមសារ ការដាក់ឯកសារ ការចុះឈ្មោះ ឬការប្រគល់មជ្ឈត្តវិនិច្ឆ័យ។

១៤៥. ច្បាប់មួយចំនួនតម្រូវថា មជ្ឈត្តវិនិច្ឆ័យត្រូវដាក់ ឬចុះបញ្ជីជាមួយតុលាការ ឬអាជ្ញាធរដែលស្រដៀងគ្នា ឬត្រូវប្រគល់ឱ្យក្នុងលក្ខណៈជាក់លាក់ ឬតាមរយៈអាជ្ញាធរមានសមត្ថកិច្ច។ ច្បាប់ទាំងនោះមានភាពខុសប្លែកគ្នាទាក់ទងនឹង ឧទាហរណ៍ ប្រភេទនៃមជ្ឈត្តវិនិច្ឆ័យដែលលក្ខខណ្ឌត្រូវបានអនុវត្ត (ឧទាហរណ៍ ចំពោះមជ្ឈត្តវិនិច្ឆ័យទាំងអស់ ឬសម្រាប់តែមជ្ឈត្តវិនិច្ឆ័យដែលមិនត្រូវបានចេញក្រោមការគាំទ្ររបស់ស្ថាប័នមជ្ឈត្តការ) រយៈពេលសម្រាប់ការដាក់ឯកសារ ការចុះឈ្មោះ ឬការប្រគល់មជ្ឈត្តវិនិច្ឆ័យ (ករណីមួយចំនួនរយៈពេលទាំងនោះអាចខ្លី) និងការលំបាកនៃការខកខានក្នុងការអនុលោមតាមលក្ខខណ្ឌបែបនេះ។

១៤៦. ប្រសិនបើមានលក្ខខណ្ឌបែបនេះ វាមានសារៈប្រយោជន៍មុនពេលចេញមជ្ឈត្តវិនិច្ឆ័យក្នុងការកំណត់ថាតើនរណានឹងចាត់វិធានការចាំបាច់ដើម្បីបំពេញតាមលក្ខខណ្ឌ និងដើម្បីសម្រេចថាតើការចំណាយត្រូវបែងចែកយ៉ាងដូចម្តេច។ ការខកខានក្នុងការអនុលោមតាមលក្ខខណ្ឌបែបនេះអាចប៉ះពាល់ដល់សុពលភាព និង/ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។



#308B, Street 62, Sangkat Steung Meanchey, Khan Meanchey, Phnom Penh, 12352
Tel: +855 (0) 86 56 9666
Email: services@din-co.com
Website: www.din-co.com
Project No. 5992983
Translation: English to Khmer
Types: Legal document
Verified by: Panha NORN
Version: 01
Date: 19 February 2023

ឌិន & សហការី

DIN & Co.

២០២៣